

ឧបត្ថម្ភដោយ

អ្នកឧកញ៉ា អ៊ុង ប៊ុនហ៊ួរ
CHIP MONG GROUP
R.L.G ក្រុមមេធាវី នីតិរដ្ឋ RULE OF LAW LAW GROUP
ខេមរៈ KHEMARA NOTARY
HBS NOTARY

ក្រសួងយុត្តិធម៌

ព្រឹត្តិបត្រ

ច្បាប់ និងយុត្តិធម៌

លេខ ១



ខែមករា
ឆ្នាំ២០២៥

ព្រឹត្តិបត្រ

ច្បាប់ និតយុត្តិធម៌

លេខ ១

សេចក្តីបញ្ជាក់

«រាល់ទស្សនៈ និងការវិភាគនៅក្នុងព្រឹត្តិបត្រនេះ គឺជាគំនិត និងការយល់ឃើញផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈ ឬគោលជំហររបស់ក្រសួងយុត្តិធម៌នោះទេ។»

ក្រសួងយុត្តិធម៌

© រក្សាសិទ្ធិគ្រប់បែបយ៉ាង ខែមករា ឆ្នាំ២០២៥

ដោយអនុលោមតាមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨

ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០០៣

លេខ ISBN: 978-9924-9987-0-9

មាតិកា

អារម្ភកថា ០៤

ផ្នែកទី១-បច្ចុប្បន្នភាពក្នុងវិស័យច្បាប់និងយុត្តិធម៌

ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ០៨

- ១- សារបាននៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ០៩
- ២-សមិទ្ធផលនៃការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល ពីនីតិកាលទី១ដល់នីតិកាលទី៦ នៃរដ្ឋសភា ១២
- ៣-ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ ២០

ផ្នែកទី២-អត្ថបទស្រាវជ្រាវនិងវិភាគផ្នែកច្បាប់ ៥០

១- អំណាចតុលាការនៅក្នុងច្បាប់កម្ពុជា ៥១

ដោយឯកឧត្តម សន សោភ័ណ, ឯកឧត្តម ចាយ ច័ន្ទតារាវណ្ណ និងឯកឧត្តម ម៉ុង មុនីចរិយា

២-រចនាសម្ព័ន្ធតុលាការកម្ពុជា ៦០

ដោយឯកឧត្តម សេង ឌីណា

៣-អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ៧៣

ដោយឯកឧត្តម ញ៉ាន វណ្ណៈ និង ឯកឧត្តម តាន់ហ៊ាង ដាវ៉ណ្ណ

៤-ទម្រង់ក្រុមហ៊ុនពាណិជ្ជកម្មក្នុងច្បាប់កម្ពុជា ៩០

ដោយឯកឧត្តម ញ៉ាន វណ្ណៈ និង លោក សាន ប៊ុនធឿន

ច្បាប់ ត្រូវតែយុត្តិធម៌ និងស្មើភាព



ចៅចំពោះមុខចៅក្រម គឺនិយាយពីច្បាប់
ចៅចំពោះមុខច្បាប់ គឺនិយាយពីយុត្តិធម៌
ចៅចំពោះមុខយុត្តិធម៌ គឺនិយាយពីភាពត្រឹមត្រូវ
ចៅចំពោះមុខភាពត្រឹមត្រូវ គឺនិយាយពីសច្ចធម៌៕

អនុសាសន៍ដ៏ខ្ពង់ខ្ពស់ឯកឧត្តម កើត រិទ្ធ
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អារម្ភកថា



ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស ត្រូវបានចាត់ទុកជាអាទិភាពគោលនយោបាយដ៏សំខាន់របស់រាជរដ្ឋាភិបាលនៅគ្រប់ដំណាក់កាលនៃការកសាងនិងការអភិវឌ្ឍជាតិសំដៅកសាងបានធនធានមនុស្សដែលប្រកបដោយសមត្ថភាព, ជំនាញ និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់។ សម្រាប់វិស័យយុត្តិធម៌, ការពង្រឹង និងលើកកម្ពស់សមត្ថភាពធនធានមនុស្ស នៅតែជាទិសដៅអាទិភាពដែលក្រសួងយុត្តិធម៌ត្រូវបន្តអនុវត្តជាប់ជាប្រចាំឥតដាច់សម្រាប់គាំទ្រដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌ សំដៅលើកកម្ពស់គុណភាពនៃការផ្តល់សេវាយុត្តិធម៌និងគុណភាពនៃយុត្តិធម៌នៅក្នុងដំណើរឈានឡើងជាបន្តបន្ទាប់របស់កម្ពុជាក្នុងការកសាងនូវសង្គមនីតិរដ្ឋក្រោមដំបូលនៃរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ។ក្នុងការអនុវត្តកិច្ចការអាទិភាពដ៏សំខាន់នេះកន្លងមក, ក្រសួងយុត្តិធម៌បានយកចិត្តទុកដាក់ខ្ពស់លើការប្រឡងប្រជែងជ្រើសរើសការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្តដល់ចៅក្រម, ព្រះរាជអាជ្ញា, ក្រឡាបញ្ជី, អាជ្ញាសាលា និងសារការី និងមន្ត្រីក្នុងវិស័យយុត្តិធម៌ ឱ្យឆ្លើយតបបានទៅនឹងការរីវត្តីរកចម្រើនឥតឈប់ឈរនៃវិស័យច្បាប់ និងសង្គមជាតិ។ ទន្ទឹមនេះ, ក្រសួងយុត្តិធម៌ ក៏បានរៀបចំបង្កើត និងដាក់ឱ្យដំណើរការនូវថ្នាលអេឡិចត្រូនិច (Virtual Platform) ដែលបានក្លាយជាឧបករណ៍ស្រាវជ្រាវ និងជាបណ្ណាល័យដ៏សំខាន់សម្រាប់អ្នកច្បាប់ អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទូទៅដែលមានបំណងស្វែងរកនូវអត្ថបទច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានក្នុងវិស័យយុត្តិធម៌ និងវិស័យផ្សេងៗទៀត ក៏ដូចជាស្វែងយល់អំពីបច្ចុប្បន្នភាពនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។

ម៉្យាងទៀត, ដើម្បីលើកកម្ពស់ការយល់ដឹង និងជំរុញការសិក្សាស្រាវជ្រាវផ្នែកច្បាប់ឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត, ក្រសួងយុត្តិធម៌ បានបង្កើតក្រុមការងាររៀបចំព្រឹត្តិបត្រច្បាប់និងយុត្តិធម៌ តាមសេចក្តីសម្រេចលេខ ០២២ កយ.សសរ/២៤ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ ដែលមានបេសកកម្ម រៀបចំនូវ «**ព្រឹត្តិបត្រច្បាប់និងយុត្តិធម៌**» សម្រាប់ផ្សព្វផ្សាយព័ត៌មានបច្ចុប្បន្នភាពអំពីវិស័យច្បាប់ និងយុត្តិធម៌ និងលើកកម្ពស់ចំណេះដឹងពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌។ ជាលទ្ធផល, ក្រុមការងារនេះ បានរៀបចំរួចរាល់នូវព្រឹត្តិបត្រលេខ១ របស់ខ្លួន ដែលមានខ្លឹមសារមួយផ្នែកផ្តោតសំខាន់លើការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាតាំងពីដំណាក់កាលដំបូងរហូតដល់បច្ចុប្បន្ន និងមួយ ផ្នែកទៀត គឺ ជាអត្ថបទស្រាវជ្រាវ និងវិភាគពាក់ព័ន្ធនឹងប្រធានបទសំខាន់ៗមួយចំនួនក្នុងវិស័យច្បាប់ និងយុត្តិធម៌។

ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រុមការងារដែលដឹកនាំដោយ ឯកឧត្តម **ញ៉ាន ឥណ្ណៈ** រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ ដែលបានខិតខំប្រឹងប្រែងយ៉ាងមោះមុត និងសហការគ្នាបានយ៉ាងល្អក្នុងការរៀបចំព្រឹត្តិបត្រនេះឱ្យលេចចេញជារូបរាងជាក់ស្តែងតាមការរំពឹងទុក។ ទន្ទឹមនេះ, ខ្ញុំក៏សូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអ្នកពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែក ក្នុងការតាក់តែង និងផ្តល់អត្ថបទស្រាវជ្រាវសម្រាប់ដាក់បញ្ចូលក្នុងព្រឹត្តិបត្រនេះ។ ការចូលរួមវិភាគទាន នេះមិនត្រឹមតែជាការរួមចំណែកជាមួយក្រសួងយុត្តិធម៌ក្នុងការអភិវឌ្ឍសមត្ថភាព ធនធានមនុស្សក្នុងវិស័យច្បាប់និងយុត្តិធម៌នៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែគឺជាការបន្សល់ទុកស្នាដៃជាកេរ្តិ៍តំណែលដែលមិនអាចកាត់ថ្លៃបានសម្រាប់ជាប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវរបស់យុវជនជំនាន់ក្រោយ។ ទន្ទឹមនេះ, ខ្ញុំសូមលើកទឹកចិត្តដល់ឥស្សរជន ថ្នាក់ដឹកនាំ មន្ត្រីរាជការចៅក្រម ព្រះរាជអាជ្ញា អ្នកវិជ្ជាជីវៈច្បាប់ ផ្សេងទៀត សាស្ត្រាចារ្យ ឬគ្រូបង្គោល ដែលមានចំណេះដឹងជ្រៅជ្រះ និងបទពិសោធន៍ទូលំទូលាយក្នុងវិស័យច្បាប់ និងយុត្តិធម៌ ចូលរួមក្នុងការរៀបចំ និងតាក់តែងនូវអត្ថបទវិភាគ ផ្សេងៗដែលមានសារៈប្រយោជន៍ដល់វិស័យយុត្តិធម៌សម្រាប់ចុះផ្សាយក្នុងព្រឹត្តិបត្រច្បាប់និងយុត្តិធម៌លេខបន្តបន្ទាប់នាពេលខាងមុខ។

ខ្ញុំសង្ឃឹម និងជឿជាក់ថាព្រឹត្តិបត្រច្បាប់ និងយុត្តិធម៌នេះ នឹងក្លាយជាឃ្លាំងពុទ្ធិសកលដែលប្រមូលផ្តុំនូវមេរៀន ចំណេះដឹង និងចំណេះធ្វើកើតចេញពីការវិភាគទ្រឹស្តីច្បាប់ និងការអនុវត្តការងារជាក់ស្តែងនៅក្នុងវិស័យច្បាប់ និងយុត្តិធម៌ ដែលនឹងផ្តល់នូវអត្ថប្រយោជន៍ជាហូរហែរប្រៀបប្រដូចទៅនឹងចំណីដ៏មានឱជារសឈ្ងុយឆ្ងាញ់នៃបញ្ញាញាណសម្រាប់អ្នកអាន សិស្ស និស្សិត និងអ្នកសិក្សា ស្រាវជ្រាវក្នុងវិស័យច្បាប់និងយុត្តិធម៌៕

ផ្នែកទី ១

បច្ចុប្បន្នភាពក្នុង វិស័យច្បាប់ និងយុត្តិធម៌



ការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា

វិស័យយុត្តិធម៌ គឺជាសសរស្តម្ភមួយដ៏សំខាន់ក្នុងការកសាង និងពង្រឹង "សង្គមនីតិរដ្ឋ" រឹងមាំមួយ និងការលើកកម្ពស់ "**អភិបាលកិច្ចល្អ**" សម្រាប់គ្រប់គ្រង និងដឹកនាំរដ្ឋ ស្របតាមគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ សម្រាប់ដំណើរឈានឡើងជាបន្តបន្ទាប់របស់កម្ពុជា។ វិស័យយុត្តិធម៌ បានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹង វប្បធម៌នៃការគោរពច្បាប់, វប្បធម៌សន្តិភាព, ស្ថិរភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ដែលជាគ្រឹះសម្រាប់វិបុលភាព និងភាពសុខសាន្តរបស់ប្រទេសជាតិ និងប្រជាជន ប្រកបដោយចីរភាព និងនិរន្តរភាព។ ផ្អែកលើសារសំខាន់នេះ រាជរដ្ឋាភិបាល បានចាត់ទុកការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គឺជាអាទិភាពដ៏សំខាន់នៅក្នុងរបៀបវារៈ និងកម្មវិធីនយោបាយរបស់ខ្លួននៅគ្រប់ដំណាក់កាល។

តើការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា មានសវតា និងបច្ចុប្បន្នភាពយ៉ាងដូចម្តេចខ្លះដែលតួរអង្គដែលមានការពាក់ព័ន្ធទាំងអស់ក្នុងវិស័យយុត្តិធម៌ ក៏ដូចជាសិស្ស និស្សិត និងអ្នកស្រាវជ្រាវផ្នែកច្បាប់ទាំងអស់ គួរស្វែងយល់? តើអ្វីខ្លះជាគោលដៅជាយុទ្ធសាស្ត្រ និងជាវិធានការអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលត្រូវសម្រេចឱ្យចេញជាលទ្ធផលជាក់ស្តែងសំដៅពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា?



១-សារបាននៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា បានចាប់ផ្តើមដំបូងនៅឆ្នាំ ២០០៣ តាមរយៈការអនុម័តនូវ **"យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥"** ដែលបានកំណត់យកការកែទម្រង់ច្បាប់និងតុលាការជាអាទិភាពមួយក្នុងចំណោមអាទិភាពផ្សេងទៀតក្នុង**"ការពង្រឹងស្ថាប័ន និងធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច"** ដែលជាសកម្មភាពអាទិភាពក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

បន្ទាប់មក, **"ឯកសារការកែទម្រង់ច្បាប់ និងតុលាការ"** ត្រូវបានអនុម័តជាផ្លូវការដោយកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងចក្ខុវិស័យ **"បង្កើតនូវវិស័យ ច្បាប់ និងតុលាការមួយដែលអាចជឿទុកចិត្តបាន និងមានស្ថិរភាព សម្រាប់ទ្រទ្រង់គោលការណ៍សិទ្ធិរបស់បុគ្គល ការបែងចែកអំណាចដាច់ពីគ្នា និងនីតិរដ្ឋនៅក្នុងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស តាមរយៈការលើកស្ទួយនូវការរីកចម្រើនសេដ្ឋកិច្ច នាំមុខដោយវិស័យឯកជន"**។

ដើម្បីសម្រេចនូវចក្ខុវិស័យវែងឆ្ងាយប្រកបដោយភាពប្រាកដនិយម និងគ្រប់ជ្រុងជ្រោយនេះ ឯកសារកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការនេះ បានកំណត់នូវទិសដៅជាយុទ្ធសាស្ត្រចំនួន ៧ រួមមានៈ

(ទី១)-ការពង្រឹងការការពារសិទ្ធិនិងសេរីភាពបុគ្គល,

(ទី២)-ការធ្វើទំនើបកម្មនៃក្របខ័ណ្ឌច្បាប់,

(ទី៣)-ការផ្តល់លទ្ធភាពឱ្យទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការកាន់តែប្រសើរឡើង,

(ទី៤)-ការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃដំណើរការរឿងក្តី និងសេវាកម្មពាក់ព័ន្ធ,

(ទី៥)-ការពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មផ្នែកអយ្យការ,

(ទី៦)-ការបញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និង

(ទី៧)-ការពង្រឹងស្ថាប័នវិស័យច្បាប់ និងតុលាការឱ្យបំពេញអាណត្តិរបស់ខ្លួនបានសម្រេច។

ទិសដៅជាយុទ្ធសាស្ត្រទាំងនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើទស្សនទាន និងគុណតម្លៃជាមូលដ្ឋានចំនួន ៤ នៃវិស័យច្បាប់ និងយុត្តិធម៌ ដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជារួមមាន "សិទ្ធិបុគ្គល ប្រជាធិបតេយ្យ ការបែងចែកអំណាចដាច់ពីគ្នា និងនីតិរដ្ឋ"។ ក្រោយមក ដើម្បីបង្កើនល្បឿនការកែទម្រង់ច្បាប់និងតុលាការ,រាជរដ្ឋាភិបាលបានអនុម័តនូវ**"កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ"** នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ដែលបានកំណត់លម្អិតអំពីសកម្មភាពអាទិភាព ដែលត្រូវអនុវត្តទាំងសម្រាប់រយៈពេលខ្លី ទាំងសម្រាប់រយៈពេលមធ្យម និងសម្រាប់រយៈពេលវែង។

បន្ទាប់មក ការកែទម្រង់ច្បាប់ និងតុលាការ ត្រូវបានប្តូរឈ្មោះទៅជា **"ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌"** វិញ ហើយត្រូវបានបន្តចាត់ទុកថាជាមុំមួយដ៏សំខាន់នៃយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាលទាំងអស់របស់រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ប៉ិនប្រសព្វប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដើម្បីលើកមគ្គសំ **"អភិបាលកិច្ចល្អ"** ដែលជាស្នូលនៃយុទ្ធសាស្ត្រទាំងនេះ។ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានបន្តអនុវត្តស្របតាមទិសដៅយុទ្ធសាស្ត្រទាំង៧ ដែលបានកំណត់ខាងលើ ដោយគ្រាន់តែមានការផ្លាស់ប្តូរនូវលំដាប់អាទិភាពជាជំហានៗ ទៅតាមដំណាក់កាលនីមួយៗនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលតែប៉ុណ្ណោះ។

ការកែទម្រង់ច្បាប់ និងតុលាការ បានចាប់ផ្តើមដំបូង ក្នុងស្ថានភាពដែលកម្ពុជាខ្វះខាតនូវក្របខ័ណ្ឌច្បាប់ ដើម្បីគ្រប់គ្រងកិច្ចដំណើរការសង្គម-សេដ្ឋកិច្ច និងកិច្ចដំណើរការនីតិវិធីរបស់តុលាការ, ខ្វះខាតនូវយន្តការការងារ, ខ្វះខាតនូវហេដ្ឋារចនាសម្ព័ន្ធនិងខ្វះខាតនូវធនធានមនុស្សដែលមានសមត្ថភាពក្នុងវិស័យយុត្តិធម៌ ដើម្បីផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរ។ នៅក្នុងបរិការណ៍នោះ ការងារកែទម្រង់ច្បាប់ និងតុលាការ ត្រូវបានអនុវត្តជាជំហានៗ ដោយផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការរៀបចំក្របខ័ណ្ឌច្បាប់ឱ្យបានគ្រប់គ្រាន់ និងរឹងមាំ និងការធ្វើទំនើបកម្មច្បាប់, ការកសាង និងពង្រឹងសមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌, ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យយុត្តិធម៌ និងការដាក់ឱ្យដំណើរការសាលាជម្រះក្តីនៅទូទាំងប្រទេសដើម្បីបង្កើតសេវាយុត្តិធម៌ឱ្យមកកៀកប្រជាពលរដ្ឋ, ការកែលម្អប្រព័ន្ធតុលាការជាបណ្តើរៗ ដោយផ្តោតលើការពង្រឹងសមត្ថភាពចៅក្រម-ព្រះរាជអាជ្ញា ឯករាជ្យភាព វិធានការវិន័យ និងការទទួលខុសត្រូវរបស់ចៅក្រម-ព្រះរាជអាជ្ញា ដើម្បីលើកកម្ពស់គុណភាពនៃសេវាយុត្តិធម៌ និងពង្រឹងជំនឿទុកចិត្តពីសាធារណជន, ការធ្វើស្ថាបនូបនីយកម្មនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, ការផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រដើម្បីធានាបាននូវសិទ្ធិទទួលបានយុត្តិធម៌និងការពារផលប្រយោជន៍ស្របច្បាប់របស់ពួកគេនិងការលើកកម្ពស់វប្បធម៌នៃការគោរពច្បាប់។

ដំបូងឡើយ ការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវបានដឹកនាំដោយ **"ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌"** ដែលត្រូវបានបង្កើតឡើងដំបូងនៅឆ្នាំ ២០០២ ដើម្បីដឹកនាំការងារកែទម្រង់ច្បាប់និងតុលាការក្នុងក្របខ័ណ្ឌនៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និងអង្គភាពគ្រប់គ្រងគម្រោងជាសេនាធិការ ដែលក្រោយមកនៅឆ្នាំ ២០០៩ អង្គភាពទាំងពីរនេះ ត្រូវបានកែសម្រួលជាអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ នៅឆ្នាំ ២០១៣ បន្ទាប់ពីការរំសាយឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ, ការងារកែទម្រង់ច្បាប់និងតុលាការត្រូវបានផ្ទេរឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងយុត្តិធម៌ផ្ទាល់ ហើយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ត្រូវបានកែសម្រួលទៅជាគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដែលមានលេខាធិការដ្ឋានអចិន្ត្រៃយ៍ជំនួសឱ្យអគ្គលេខាធិការដ្ឋាន ជាសេនាធិការឱ្យក្រសួងយុត្តិធម៌ក្នុងការជួយសម្របសម្រួល និង បន្តអនុវត្តការកែទម្រង់ច្បាប់និងតុលាការ និងកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ។

២-សមិទ្ធផលនៃការងារ
កែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
របស់រាជរដ្ឋាភិបាល ពីនីតិកាលទី១ ដល់នីតិកាលទី៦ នៃរដ្ឋសភា









ក្នុងរយៈពេលជាង ២០ ឆ្នាំ រាជរដ្ឋាភិបាល ពីនីតិកាលទី១ ដល់នីតិកាលទី៦ ក្រោមការដឹកនាំដ៏ប៉ិនប្រសព្វ ប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានអនុវត្តប្រកបដោយជោគជ័យនូវការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ជាក់ស្តែង កម្ពុជាដែលពីមុនល្បីក្នុងការប្រើប្រាស់អាវុធនិងការអន្តរាគមន៍ក្នុងការដោះស្រាយទំនាស់ ឥឡូវបានក្លាយទៅជានីតិរដ្ឋដែលគោរពគោលការណ៍ច្បាប់ដោយឥតងាករេ។

តាមរយៈការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, វប្បធម៌នៃការគោរពច្បាប់ បានចាក់គ្រឹះជ្រៅចូលទៅក្នុងសង្គមកម្ពុជានៅគ្រប់វិស័យ និងទៅក្នុងជីវភាពរស់នៅរបស់ប្រជាជនគ្រប់ស្រទាប់។ ប្រសិទ្ធភាពនៃសេវាយុត្តិធម៌ដែលងាយស្រួលប្រើ និងឆាប់រហ័ស និងគុណភាពនៃការដោះស្រាយវិវាទជូនប្រជាពលរដ្ឋដោយត្រឹមត្រូវ និងយុត្តិធម៌ស្របតាមច្បាប់ ត្រូវបានពង្រឹង និងលើកកម្ពស់ជាបន្តបន្ទាប់។ សមិទ្ធផលធំៗ ដែលសម្រេចបាន រួមមានជាអាទិ៍៖

(ទី១)-ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត៖ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនត្រូវបានអនុម័ត និងបង្កើតឡើងជាបន្តបន្ទាប់ ដើម្បីធានាដល់ការគ្រប់គ្រងទំនាក់ទំនងសង្គមឱ្យមានសណ្តាប់ធ្នាប់ និងស្ថិរភាព ក៏ដូចជាដើម្បីបំពេញតម្រូវការជាក់ស្តែង និងការវិវត្តឥតឈប់ឈររបស់សង្គមជាតិលើគ្រប់វិស័យ។ ច្បាប់គ្រឹះធំៗដែលបម្រើឱ្យវិស័យយុត្តិធម៌រួមមាន៖ ក្រមព្រហ្មទណ្ឌ, ក្រមនីតិវិធីព្រហ្មទណ្ឌ, ក្រមរដ្ឋប្បវេណី, ក្រមនីតិវិធីរដ្ឋប្បវេណី, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់សម្រាប់បម្រើឱ្យវិស័យផ្សេងទៀតចំនួនប្រមាណ ៦១០ច្បាប់ ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើ។

(ទី២)-ការកសាងនិងពង្រឹងសមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌៖ នៅមុនឆ្នាំ ២០០២, កម្ពុជា ពុំមានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការនោះទេ ដោយនៅពេលនោះ ចៅក្រម, ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ត្រូវបានជ្រើសចេញពីធនធានមនុស្សដែលនៅរស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត រួចបញ្ជូនទៅបណ្តុះបណ្តាលនៅក្រៅប្រទេស ឬបំពាក់បំប៉នជំនាញរយៈពេលខ្លីមុននឹងត្រូវជ្រើសឱ្យចូលបំពេញការងារនៅតាមសាលាជម្រះក្តីនិងអង្គការអយ្យការអមសាលាជម្រះក្តីនានា។

ជាលទ្ធផលនៃការអនុវត្តការងារកែទម្រង់ច្បាប់ និងតុលាការ, គិតត្រឹមឆ្នាំ ២០២៤នេះ, បណ្តិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ផលិតបានធនធានជាចៅក្រម, ព្រះរាជអាជ្ញា, ក្រឡាបញ្ជី, អាជ្ញាសាលា និងសារការី សរុបចំនួន ១ ៩៨៦នាក់ ក្នុងនោះចៅក្រម និងព្រះរាជអាជ្ញា សរុបចំនួន ៥៥៧នាក់, ក្រឡាបញ្ជី សរុបចំនួន ១ ៣៣៦នាក់ (ក្នុងនោះមន្ត្រីសុក្រឹតការក្រឡាបញ្ជីមានចំនួន ៦១៦នាក់), អាជ្ញាសាលា សរុបចំនួន ៥៦រូប, សារការី សរុបចំនួន ៣៧នាក់។





បច្ចុប្បន្ន, សិស្សវិជ្ជាជីវៈតុលាការទាំងអស់ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យបាននិងកំពុងបំពេញមុខងារជាចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និង ជាអាជ្ញាសាលា នៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ហើយមួយចំនួនទៀតកំពុងបំពេញការងារនៅក្នុងរដ្ឋបាលសាធារណៈផងដែរ។





តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០៣២៣/៥២០ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣, **"រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ"** ត្រូវបានប្តូរឈ្មោះមកជា **"បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា"** ដែលជាផ្នែកមួយនៃការកែទម្រង់ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកច្បាប់និងតុលាការរបស់កម្ពុជាមួយនេះសំដៅ៖

(១)- ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម ព្រះរាជអាជ្ញា, ក្រឡាបញ្ជីអាជ្ញាសាលា និងសារការីសំដៅធ្វើយ៉ាងណាឱ្យធនធានមនុស្សដែលផលិតបានមានសមត្ថភាពគ្រប់គ្រាន់និងប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ជាកត្តាដ៏សំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់, និងប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ និងគុណភាពនៃយុត្តិធម៌;

(២)-ពង្រីកសក្តានុពលភាពនៃស្ថាប័ននេះ ដើម្បីបណ្តុះបណ្តាលពង្រឹងសមត្ថភាពផ្នែកបច្ចេកទេសដល់មន្ត្រីក្នុងវិស័យយុត្តិធម៌ និងមន្ត្រីកាន់ការងារផ្នែកច្បាប់ផ្សេងទៀត;

(៣)-លើកកម្ពស់សមត្ថភាពផ្នែកសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយនូវស្មារដៃផ្សេងៗដែលជាឧត្តមប្រយោជន៍ដល់វិស័យច្បាប់ និងយុត្តិធម៌នៅកម្ពុជា។

(ទី៣)-ការកសាង និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបម្រើឱ្យវិស័យយុត្តិធម៌៖ ពីមុនសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីភាគច្រើនមិនមានទីតាំង និងហេដ្ឋារចនាសម្ព័ន្ធសមរម្យសម្រាប់អនុវត្តមុខងាររបស់ខ្លួននោះទេ ដោយសាលាជម្រះក្តីមួយចំនួនត្រូវដំណើរការលើទីតាំងជួលពីឯកជនដែលមានលក្ខណៈតូចចង្អៀត។ បច្ចុប្បន្ន អគារ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់នានារបស់សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីនៅទូទាំងប្រទេសត្រូវបានកសាងនិងកែលម្អដែលនេះគឺជាផ្នែកមួយនៃការពង្រឹងសមត្ថភាពស្ថាប័ន សំដៅពង្រឹងប្រសិទ្ធភាពការងារ និងប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ។





(ទី៤)-ការបង្កើតសេវាយុត្តិធម៌ឱ្យកាន់តែកៀកជិតប្រជាពលរដ្ឋ៖ រាជរដ្ឋាភិបាល បានដាក់ឱ្យដំណើរការនូវសាលាដំបូង និងអយ្យការអមសាលាដំបូងនៅគ្រប់បណ្តារាជធានី-ខេត្តនៅទូទាំងប្រទេស និងបានបង្កើតនិងដាក់ឱ្យដំណើរការនូវសាលាឧទ្ធរណ៍ នៅតាមតំបន់ចំនួន៣ បន្ថែមលើសាលាឧទ្ធរណ៍និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញរួមមានៈសាលាឧទ្ធរណ៍និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ, សាលាឧទ្ធរណ៍ និងមហាអយ្យ ការអមសាលាឧទ្ធរណ៍បាត់ដំបង និងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍តួ្បងឃ្មុំ សំដៅបង្កើតសេវាយុត្តិធម៌ ឱ្យកាន់តែចិតជិតប្រជាពលរដ្ឋ។

(ទី៥)-ការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌៖ ការដាក់ឱ្យដំណើរការនូវអង្គភាពរដ្ឋបាលតុលាការនៅតាមសាលាដម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីជួយគាំទ្រលើការងាររដ្ឋបាល ហិរញ្ញវត្ថុ និងទំនាក់ទំនងសាធារណៈរបស់សាលាដម្រះក្តីទាំងអស់ ក្នុងគោលបំណងកែលម្អការបម្រើសេវាជូរមុខនៅតាមសាលាដម្រះក្តី និងអង្គការអយ្យការអមសាលាដម្រះក្តី និងលើកកម្ពស់ការយកចិត្តទុកដាក់លើចំណាត់ការសំណុំរឿងរបស់ចៅក្រម និងព្រះរាជអាជ្ញា។ ទន្ទឹមនេះ, ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសំណុំរឿងតាមប្រព័ន្ធបច្ចេកវិទ្យាក៏ត្រូវបានរៀបចំដាក់ឱ្យដំណើរការនៅតាមសាលាដំបូងរាជធានី ខេត្តមួយចំនួនផងដែរ។



(ទី៦)-ការលើកកម្ពស់សិទ្ធិទទួលបានយុត្តិធម៌តាមរយៈការលើកកម្ពស់យន្តការនៃការផ្តល់សេវាជំនួយផ្នែកច្បាប់៖ កន្លងមក,រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋក្រីក្រដែលមិនមានលទ្ធភាពផ្នែកហិរញ្ញវត្ថុ ក្នុងការពឹងពាក់រកមេធាវី តាមរយៈយន្តការប្រតិភូគណៈមេធាវីប្រចាំការនៅតាមសាលាដំបូងរាជធានី-ខេត្ត ដែលជាយន្តការបង្កើតឡើងដោយកិច្ចសហការរវាងក្រសួងយុត្តិធម៌និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានានូវសិទ្ធិទទួលបានយុត្តិធម៌ (Access to Justice) របស់ប្រជាពលរដ្ឋក្រីក្រនៅក្នុងសង្គម។ យន្តការនេះទទួលបានកញ្ចប់ថវិកាពីរាជរដ្ឋាភិបាលជារៀងរាល់ឆ្នាំ ហើយដែលកញ្ចប់ថវិកាប្រចាំឆ្នាំនេះកើនឡើងជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំពីចំនួនទឹកប្រាក់ ២០០ លានរៀល នៅឆ្នាំ ២០០៣ រហូតដល់ចំនួនទឹកប្រាក់ ២ ៦០០ លានរៀល នៅឆ្នាំ២០២៤នេះ។ បន្ថែមពីលើយន្តការនេះ, រាជរដ្ឋាភិបាលក៏បានបង្កើតឱ្យមាននូវយន្តការមេធាវីស្ម័គ្រចិត្តផ្សេងៗដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី, ក្រុមមេធាវីរាជរដ្ឋាភិបាល, ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ព្រមទាំងយន្តការនៃការផ្តល់សេវាមេធាវីដោយឥតគិតកម្រៃជូនដល់ជនក្រីក្ររបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

(ទី៧)-ការពង្រឹងប្រសិទ្ធភាពនៃយន្តការអធិការកិច្ច៖ ទន្ទឹមនឹងការគិតគូយកចិត្តទុកដាក់ លើការលើកកម្ពស់ជីវភាព និងកិត្តិយសរបស់ចៅក្រម និងព្រះរាជអាជ្ញា, យន្តការអធិការកិច្ចរបស់ក្រសួងយុត្តិធម៌ និងយន្តការវិន័យរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានពង្រឹងជាបន្តបន្ទាប់សំដៅលើកកម្ពស់វិន័យការងារ ក្រមសីលធម៌ និងសេចក្តីថ្លៃថ្នូររបស់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការផ្សេងទៀត។

(ទី៨)-ការរៀបចំដាក់ឱ្យដំណើរការនិងការលើកកម្ពស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ៖ យន្តការដោះ ស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងវិស័យនានាជាពិសេសវិស័យពាណិជ្ជកម្ម, វិស័យការងារ, វិស័យជីធ្លី ត្រូវបានដាក់ឱ្យដំណើរការ និងទទួលបានការគាំទ្រជាបន្តបន្ទាប់។ ទន្ទឹមនេះ, អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ត្រូវបានបង្កើតឡើងកាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលជាយន្តការដោះស្រាយវិវាទថ្មីមួយបន្ថែមលើយន្តការដោះស្រាយវិវាទដែលមានស្រាប់នៅកម្ពុជាសំដៅកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមតុលាការ, បង្កើតយន្តការដោះស្រាយវិវាទឱ្យកៀកប្រជាជន និង ធានាបាននូវភាពសុខដុមរមនានៅក្នុងសហគមន៍ និងមូលដ្ឋាន។

ទន្ទឹមនឹងសមិទ្ធផល និងជោគជ័យខាងលើ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅជួបប្រទះបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលធ្វើឱ្យការពង្រឹងការអនុវត្តច្បាប់និងការផ្តល់សេវាយុត្តិធម៌ នៅមិនទាន់ទទួលបានជំនឿទុកចិត្តទាំងស្រុងពីសំណាក់មហាជនដែលបញ្ហាប្រឈមទាំងនោះ រួមមានជាអាទិ៍៖ (១)-សមត្ថភាពស្ថាប័ននិងធនធានមនុស្សក្នុងវិស័យយុត្តិធម៌នៅមានកម្រិតហើយមិនទាន់ឆ្លើយតបបានទាំងស្រុងទៅនឹងតម្រូវការការងារនិងចំនួននៃសំណុំរឿងដែលកើនឡើងជាលំដាប់ជារៀងរាល់ឆ្នាំ, (២)-ការយល់ដឹងអំពីច្បាប់នៅមានកម្រិតដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងការចូលរួមគោរពច្បាប់ពីសាធារណជន, (៣)-សមត្ថភាពឆ្លើយតបក្នុងការផ្តល់សេវាកម្មច្បាប់ និងជំនួយផ្នែកច្បាប់នៅមានកម្រិត, (៤)-ការកសាងក្របខណ្ឌច្បាប់ នៅមិនទាន់គ្រប់ជ្រុងជ្រោយ ហើយក្របខណ្ឌច្បាប់ចាំបាច់មួយចំនួនលែងឆ្លើយតបទៅនឹងស្ថានភាពវិវត្តជាក់ស្តែងរបស់សង្គម-សេដ្ឋកិច្ច និង(៥)-ការពង្រឹងយន្តការវិន័យការងារ និងការពង្រឹងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីក្នុងការអនុវត្តច្បាប់នៅមានកម្រិត។

៣- ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
របស់រាជរដ្ឋាភិបាល
នីតិកាលទី ៧





សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា, ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានឈានដល់ដំណាក់កាល**"ប្រែប្រួលថ្មី"**ដែលនឹងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើ **"ប្រសិទ្ធភាពនៃសមិទ្ធកម្ម"** សំដៅពង្រឹង និងលើកកម្ពស់ទាំងគុណភាពនិងប្រសិទ្ធភាពនៃច្បាប់, ទាំងគុណភាព និងប្រសិទ្ធភាពនៃសេវាយុត្តិធម៌ និងទាំងគុណភាពនៃយុត្តិធម៌ដើម្បី (ម្យ៉ាង) អាចឆ្លើយតបបានប្រកបដោយប្រសិទ្ធភាពខ្ពស់ចំពោះក្តីរំពឹងទុក សេចក្តីត្រូវការ និងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាពលរដ្ឋក្នុងសង្គមនីតិរដ្ឋ និងសង្គមដែលមានសន្តិភាពពេញបរិបូរណ៌និង(ម្យ៉ាងទៀត)ដើម្បីរួមចំណែកក្នុងការសម្រេចឱ្យបាននូវ **"ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០"** ក្នុងការកសាងជាតិមួយឱ្យរឹងមាំ រស់រវើក រុងរឿង និងមានវិបុលភាព ឱ្យក្លាយជាប្រទេសមានចំណូលខ្ពស់នៅត្រឹមឆ្នាំ ២០៥០។

ផ្នែកតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល, រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា នៅតែបន្តចាត់ទុក **"ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌"** ជា អាទិភាពមួយដ៏សំខាន់របស់ខ្លួនសំដៅពង្រឹង និងលើកកម្ពស់ "**នីតិរដ្ឋ**" នៅកម្ពុជា ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការធានាថែរក្សាស្ថិរភាពសង្គម សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ, ការលើកកម្ពស់ការគោរពសិទ្ធិមនុស្ស និងការពង្រឹង **"យុត្តិធម៌នៅក្នុងសង្គមជាតិ"**ដែលជាគ្រឹះសម្រាប់ភាពសុខសាន្តរបស់ប្រជាជន និងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

"**ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**" ត្រូវបានរៀបចំបញ្ចូលជាមុំមួយដ៏សំខាន់ក្នុងចំណោមមុំទាំង៥ដែលបង្កើតបានជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល សំដៅ **"ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌"** នៅកម្ពុជា។ដើម្បីសម្រេចឱ្យបាននូវគោល-ដៅយុទ្ធសាស្ត្រនៃមុំទី៤ នេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលដៅជាអាទិភាពចំនួនខួរមានៈ

(ទី១)-ការលើកកម្ពស់សមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌, ទាំងបរិមាណនិងគុណភាព,ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យយុត្តិធម៌ និងប្រសិទ្ធភាព និងភាពរហ័សនៃការដោះស្រាយវិវាទ ទាំងក្នុងប្រព័ន្ធតុលាការ ទាំងក្រៅប្រព័ន្ធតុលាការ។

(ទី២)-ការលើកកម្ពស់ប្រសិទ្ធភាព, សង្គតិភាព និងអនុលោមភាពគតិយុត្តនៃការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំដៅធានាឆ្លើយតបបានទៅនឹងចក្ខុវិស័យនិងសេចក្តីត្រូវការនានារបស់សង្គមជាតិ។

(ទី៣)-ការលើកកម្ពស់ការគោរពច្បាប់ និងការផ្តល់សេវាជំនួយផ្នែកច្បាប់តាមរយៈការបន្តជំរុញការអប់រំនិងផ្សព្វផ្សាយច្បាប់,ការផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងការផ្តល់ការការពារក្តីនៅចំពោះមុខតុលាការសំដៅធានាសិទ្ធិទទួលបានយុត្តិធម៌ជាពិសេសសម្រាប់ប្រជាពលរដ្ឋ ក្រីក្រ និងជនងាយរងគ្រោះ។

(ទី៤)-ការលើកកម្ពស់ភាពត្រឹមត្រូវ និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ពីសំណាក់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការ ជាពិសេសការពង្រឹងប្រសិទ្ធភាពនៃចំណាត់ការលើសំណុំរឿង, ការពង្រឹងភាពសុចរិត ភាពស្អាតស្អំ និងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់និងមន្ត្រីតុលាការ ព្រមទាំងការពង្រឹងយន្តការអធិការកិច្ច និងការដាក់វិន័យ សំដៅពង្រឹងជំនឿទុកចិត្តលើការអនុវត្តច្បាប់។

(ទី៥)-ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធតុលាការ តាមរយៈការបន្តធ្វើទំនើបកម្មរដ្ឋបាលតុលាការ ដើម្បីលើកកម្ពស់គុណភាពនៃការផ្តល់សេវាយុត្តិធម៌ឱ្យកាន់តែប្រសើរ និងការពង្រឹងគុណភាពនៃយុត្តិធម៌។

(ទី៦)-ការជំរុញរៀបចំក្របខ័ណ្ឌគតិយុត្តិនិងយន្តការសម្រុះសម្រួល និងផ្សះផ្សាវិវាទទាំងក្នុងប្រព័ន្ធតុលាការ ទាំងក្រៅប្រព័ន្ធតុលាការសំដៅលើកកម្ពស់ប្រសិទ្ធភាព និងភាពរហ័សនៃការដោះស្រាយវិវាទ និងបង្កើតសេវានៃការដោះស្រាយវិវាទឱ្យកៀកនឹងប្រជាពលរដ្ឋ។

ទន្ទឹមនឹងការប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣, **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក៏បានប្រកាសដាក់ចេញនូវវិធានការគន្លឹះចំនួន៥ ដែលជាកិច្ចការអាទិភាពដ៏សំខាន់របស់រាជរដ្ឋាភិបាលដែលត្រូវសម្រេចឱ្យចេញជាលទ្ធផលជាក់ស្តែងក្នុងនីតិកាលទី៧ នេះ។ ក្នុងចំណោមវិធានការគន្លឹះទាំង៥នេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានប្រកាសយក **"ការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌"** ជាវិធានការគន្លឹះទី៥ហើយ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានប្រគល់ភារកិច្ចឱ្យ **ក្រសួងយុត្តិធម៌** ដើម្បីរៀបចំផែនការសកម្មភាពជាក់ស្តែងសំដៅធ្វើយ៉ាងណាសម្រេចឱ្យបាននូវកិច្ចការអាទិភាពសំខាន់ចំនួន៣ នៃវិធានការគន្លឹះទី៥ នេះ ដែលកិច្ចការអាទិភាពទាំង៣ នេះរួមមានៈ

(ទី១)-ការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បន្ថែមលើយន្តការដែលមានស្រាប់ដើម្បីជួយសម្រុះសម្រួលដោះស្រាយវិវាទឱ្យបានឆាប់រហ័សជាពិសេសវិវាទរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

(ទី២)-ការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការឱ្យបានឆាប់រហ័ស សំដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ជូនប្រជាជន និង

(ទី៣)-ការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ សំដៅជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋក៏ដូចជាលើកកម្ពស់តម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវនៅក្នុងការអនុវត្តច្បាប់ និងចំណាត់ការរឿងក្តីដោយតុលាការ។

ផ្អែកតាម **"យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១"** និង **"វិធានការគន្លឹះទី៥"** ខាងលើនេះ, ជាទិសដៅការងារទៅមុខ, ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ នឹងត្រូវប្រមូលផ្តុំការយកចិត្តទុកដាក់ទៅលើ **"សសរស្តម្ភ"** សំខាន់ចំនួន ២ គឺ៖

(សសរស្តម្ភទី១)-គឺការកែទម្រង់ប្រព័ន្ធតុលាការ សំដៅខិតខំធ្វើឱ្យប្រសើរឡើងជាលំដាប់ជាបន្តទៀតនូវគុណភាព និងប្រសិទ្ធភាពទាំងលើការផ្តល់ **"សេវាយុត្តិធម៌"** ប្រកបដោយភាពឆាប់រហ័សទាំងលើ**"គុណភាពនៃយុត្តិធម៌"** ប្រកបដោយភាពសុក្រឹតនិងភាពត្រឹមត្រូវនិង

(សសរស្តម្ភទី២)-គឺការកែទម្រង់ប្រព័ន្ធដោះស្រាយវិវាទនៅកម្ពុជា តាមរយៈការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ សំដៅបង្កើតសេវានៃការដោះស្រាយវិវាទដែលមានលក្ខណៈងាយស្រួល និងសម្បូរបែបឱ្យទៅជិតប្រជាពលរដ្ឋនៅមូលដ្ឋាន, ជួយសម្រុះសម្រួល ផ្សះផ្សាដោះស្រាយបញ្ចប់វិវាទឱ្យបានឆាប់រហ័សជូនប្រជាពលរដ្ឋ ព្រមទាំងរួមចំណែកលើកកម្ពស់វប្បធម៌សន្តិភាពនិយមក្នុងសង្គមកម្ពុជា។

សសរស្តម្ភ ទី១
ការកែទម្រង់ប្រព័ន្ធតុលាការ



បេសកកម្មជាអាទិភាពនៃការកែទម្រង់ប្រព័ន្ធតុលាការស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល គឺការធានានិងការសម្រេចឱ្យបាននូវគោលដៅចម្បងយ៉ាងតិចចំនួន ២ គឺ៖ *(ទី១)*-គុណភាពនៃយុត្តិធម៌កាន់តែសុក្រឹត្យ និង *(ទី២)*-ការផ្តល់សេវាយុត្តិធម៌ឱ្យកាន់តែល្អប្រសើរ(ងាយស្រួលប្រើប្រាស់, ឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព)។ ដើម្បីសម្រេចបាននូវបេសកកម្មជាអាទិភាព និងគោលដៅនៃការកែទម្រង់ប្រព័ន្ធតុលាការខាងលើនេះ, និងបន្ទាប់ពីទទួលបានគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចធិបតីនាយករដ្ឋមន្ត្រី**, ក្រសួងយុត្តិធម៌បានសម្រេចដាក់ចេញជាយុទ្ធនាការចំនួន ២ ព្រមពេលជាមួយគ្នា ដើម្បីអនុវត្តកិច្ចការអាទិភាពទី២ និងកិច្ចការអាទិភាពទី៣ នៃវិធានការគន្លឹះទី៥ របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក្នុងនោះ **យុទ្ធនាការទី១** គឺ “**យុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ**” និង **យុទ្ធនាការទី២** គឺ “**យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ**”។

យុទ្ធនាការទាំង ២ នេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីពង្រឹង និងលើកកម្ពស់សេវាយុត្តិធម៌ និងគុណភាពនៃយុត្តិធម៌ ដែលជាបំណងប្រាថ្នារបស់**សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក្នុងការលើកកម្ពស់ "**គោលការណ៍នីតិរដ្ឋ**" និង"**យុត្តិធម៌នៅក្នុងសង្គមជាតិ**" ដែលកិច្ចការនេះត្រូវបានចាត់ទុកជាអាទិភាពនយោបាយដ៏សំខាន់មួយដែលត្រូវអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្តែងសម្រាប់នីតិកាលទី៧ នៃរដ្ឋសភានេះ ក្នុងនោះ **យុទ្ធនាការទី១** នឹងជួយលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ជូនប្រជាជនប្រកបដោយភាពឆាប់រហ័ស ហើយ **យុទ្ធនាការទី២** នឹងជួយដោះស្រាយរកយុត្តិធម៌ឱ្យបានត្រឹមត្រូវជូនប្រជាពលរដ្ឋ ក៏ដូចជាលើកកម្ពស់តម្លាភាពសុចរិតភាពនិងភាពត្រឹមត្រូវនៅក្នុងការអនុវត្តច្បាប់ និងចំណាត់ការរឿងក្តីដោយតុលាការ។

ការសម្រេចចិត្តអនុវត្តកិច្ចការអាទិភាពទាំង ២ នេះ ក្នុងទម្រង់ជាយុទ្ធនាការទាំង ២ ខាងលើនេះគឺមាន**គោលបំណងសំខាន់២**គឺ៖ *(ម្យ៉ាង)*- ដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្ត និងសម្រេចឱ្យបាននូវលទ្ធផលជាក់ស្តែងតាមអាទិភាពនយោបាយរបស់**សម្តេចធិបតីនាយករដ្ឋមន្ត្រី** និង *(ម្យ៉ាងទៀត)*-ដើម្បីជាការក្រើនរំលឹកដល់សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់, ដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជីអាជ្ញាសាលា និងមន្ត្រីតុលាការទាំងអស់ត្រូវចងចាំក្នុងចិត្តថាការជំរុញនិងពន្លឿនការដោះស្រាយសំណុំរឿងឱ្យបាន **(ទី១)-លឿនឆាប់រហ័ស, (ទី២)- ត្រឹមត្រូវ និង (ទី៣)-យុត្តិធម៌ស្របតាមច្បាប់** គឺជាកិច្ចការចាំបាច់ដែលត្រូវបន្តអនុវត្តជាប់ប្រចាំទាំងក្នុងក្របខ័ណ្ឌនៃការអនុវត្តការងាររបស់ខ្លួនក្នុងការបម្រើសេវាយុត្តិធម៌ជូនប្រជាជន ទាំងក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ប្រព័ន្ធតុលាការនៅកម្ពុជា។

១ - យុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ



យុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ (យុទ្ធនាការទី១) នេះធ្វើឡើងក្នុងគោលបំណងដើម្បីជំរុញនិងពន្លឿនការដោះស្រាយសំណុំរឿងនៅតាមតុលាការឱ្យបានលឿនឆាប់រហ័ស ត្រឹមត្រូវ និងយុត្តិធម៌ ដែលកិច្ចការនេះនៅតែជាទិសដៅអាទិភាពដ៏សំខាន់ក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់ប្រព័ន្ធតុលាការ ដែលត្រូវបន្តយកចិត្តទុកដាក់អនុវត្តជាប់ជាប្រចាំ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់សំដៅពង្រឹងនិងលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ជូនប្រជាជន។

យុទ្ធនាការទី១ នេះនឹងជួយលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ ជូនប្រជាជនប្រកបដោយភាពឆាប់រហ័ស និងងាយស្រួល។ ការអនុវត្តយុទ្ធនាការនេះនឹងជំរុញឱ្យសាលាជម្រះក្តី និងអង្គការអយ្យការអមសាលា ជម្រះក្តីគ្រប់ជាន់ថ្នាក់ត្រូវយកចិត្តទុកដាក់ដោះស្រាយសំណុំរឿងគ្រប់ប្រភេទឱ្យបានលឿន។ យុទ្ធនាការទី១នេះ ក៏ជាការក្រើនរំលឹកដល់មន្ត្រីតុលាការទាំងអស់ត្រូវចងចាំក្នុងចិត្តថា ការជំរុញ និងពន្លឿនការដោះស្រាយសំណុំរឿងឱ្យបានឆាប់រហ័ស និងងាយស្រួល គឺជាកិច្ចការចាំបាច់ដែលត្រូវបន្តអនុវត្តជាប់ប្រចាំ ក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់ប្រព័ន្ធតុលាការនៅកម្ពុជាព្រមទាំងជាការបន្តលើកកម្ពស់សមត្ថភាពស្ថាប័នតុលាការក្នុងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋផងដែរ។

- **វិសាលភាព:** យុទ្ធនាការទី១ នេះមានវិសាលភាពគ្របដណ្តប់ទៅលើរឿងក្តីគ្រប់ប្រភេទទាំងអស់ ទាំងរឿងក្តីរដ្ឋប្បវេណី ទាំងរឿងក្តីព្រហ្មទណ្ឌ ទាំងរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីផ្សេងទៀតនៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ ផ្អែកតាមការវាយតម្លៃលើចំនួនសំណុំរឿងនៅសល់កំពុងចាត់ការនៅទូទាំងប្រទេស និងផ្អែកលើបទពិសោធន៍ក្នុងការអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងព្រហ្មទណ្ឌនៅតាមសាលាដំបូងរាជធានី-ខេត្ត នាពេលកន្លងមក, ក្រសួងយុត្តិធម៌ បានវាយតម្លៃថា ការអនុវត្តយុទ្ធនាការទី១ អាចនឹងត្រូវបញ្ចប់ក្នុងរយៈពេលយ៉ាងយូរ ៣ឆ្នាំ **គិតចាប់ពីថ្ងៃប្រកាសបើកយុទ្ធនាការនៅថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤** តទៅ។

- **អតិក្រមការងារសម្រាប់ការអនុវត្តយុទ្ធនាការទី១:** យុទ្ធនាការទី១ នេះត្រូវអនុវត្តដោយត្រូវគោរពឱ្យបានម៉ឺងម៉ាត់នូវអភិក្រម ***"លឿន ត្រឹមត្រូវ និងយុត្តិធម៌ ដោយផ្អែកលើច្បាប់"*** ដោយត្រូវជៀសវាងឱ្យបានជាដាច់ខាតនូវស្ថានភាព***"ត្រីងៀតឆ្លៀតពង"*** តាមរយៈការប្រើប្រាស់យុទ្ធនាការនេះដើម្បីស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន ឬប្រព្រឹត្តអំពើពុករលួយណាមួយ។

២ - យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ





យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ (យុទ្ធនាការទី២) គឺធ្វើឡើងក្នុងគោលបំណងសំខាន់ៗចំនួន២គឺ៖**(ទី១)**-ដើម្បីជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋដែលរងគ្រោះដោយអយុត្តិធម៌ឬដោយការរំលោភបំពានដោយខុសច្បាប់នៅក្នុងសង្គម និង**(ទី២)**-ដើម្បីលើកកម្ពស់តម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវនៅក្នុងការអនុវត្តច្បាប់ និងក្នុងចំណាត់ការរឿងក្តីដោយតុលាការ ប៉ុន្តែការកំណត់ថា **"យុត្តិធម៌ ឬ អយុត្តិធម៌"** គឺមិនចំណុះទៅលើត្រឹមការលើកឡើង របស់ភាគីណាមួយឡើយ ប៉ុន្តែចំណុះលើអង្គហេតុ អង្គច្បាប់ និងភស្តុតាង ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ត្រួតពិនិត្យឱ្យបានជិតដល់។ ក្នុងន័យនេះយុទ្ធនាការទី២នឹងជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋក៏ដូចជាលើកកម្ពស់តម្លាភាពសុចរិតភាពនិងភាពត្រឹមត្រូវនៅក្នុងការអនុវត្តច្បាប់ និងចំណាត់ការរឿងក្តីដោយតុលាការ។

យុទ្ធនាការទី២ នេះ នឹងផ្តោតលើបញ្ហាសំខាន់ចំនួន ២ គឺ៖ (ទី១)-ពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីលើផ្នែកអភិបាលកិច្ចនៅតាមសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីនានា និង (ទី២)-ពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីលើចំណាត់ការសំណុំរឿង និងក្នុងការសម្រេចសេចក្តីរបស់តុលាការ។

យុទ្ធនាការទី២ នេះ នឹងក្លាយជាច្រកផ្លូវការ មួយសម្រាប់ប្រជាពលរដ្ឋដែលរងគ្រោះដោយអយុត្តិធម៌ដោយការរំលោភបំពានដោយខុសច្បាប់ នៅក្នុងសង្គម ឬដោយសារមានភាពមិនប្រក្រតីនៅតាមតុលាការ អាចដាក់ពាក្យបណ្តឹងអំពីភាពមិនប្រក្រតីក្នុងចំណាត់ការរបស់តុលាការ ដើម្បីឱ្យយន្តការទទួលបន្ទុកជួយត្រួតពិនិត្យ និងជួយដោះស្រាយរកយុត្តិធម៌។ **យុទ្ធនាការទី២ នេះនឹងក្លាយជាកញ្ចក់ឆ្លុះឱ្យឃើញការពិត នៅពេល មានបណ្តឹងអំពីភាពមិនប្រក្រតីណាមួយនៅតាមតុលាការ**។ ក្នុងករណីដែលរកឃើញការពិត ថាពិតជាមានភាពមិនប្រក្រតីកើតឡើងមែននោះ យើងត្រូវហ៊ានទទួលស្គាល់ការពិត ហើយត្រូវខិតខំស្វែងរកនូវដំណោះស្រាយមួយដែលត្រឹមត្រូវ និងយុត្តិធម៌ជូនប្រជាពលរដ្ឋដែលរងគ្រោះ។ផ្ទុយទៅវិញប្រសិនបើការប្តឹងអំពីភាពមិនប្រក្រតីនេះមិនមានមូលដ្ឋានត្រឹមត្រូវនិងខុសពីការពិតជាក់ស្តែងហើយតុលាការបានសម្រេចសេចក្តីយ៉ាងត្រឹមត្រូវនិងយុត្តិធម៌តាមច្បាប់រួចហើយនោះ យើងក៏ត្រូវការពារកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អង្គចៅក្រម និងផ្តល់យុត្តិធម៌ដល់ចៅក្រមដែលទទួល បន្ទុកដោះស្រាយសំណុំរឿងហើយរងការ ចោទប្រកាន់ដោយមិនត្រឹមត្រូវនោះវិញដែរ។

-វិសាលភាព៖ យុទ្ធនាការទី២ នេះ នឹងផ្តោតលើបញ្ហាសំខាន់ចំនួន ២ គឺ៖ **(ទី១)**- ពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីលើផ្នែកអភិបាល កិច្ចនៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីនានា និង**(ទី២)**-ពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីលើចំណាត់ការសំណុំរឿង និងក្នុងការសម្រេចសេចក្តីរបស់តុលាការក្នុងសំណុំរឿងគ្រប់ប្រភេទ។ យុទ្ធនាការនេះ មានរយៈពេល ៥ឆ្នាំ គិតចាប់ពីថ្ងៃប្រកាសបើកយុទ្ធនាការ នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤ តទៅ។

-អតិក្រមការងារសម្រាប់ការអនុវត្តយុទ្ធនាការទី២៖ ដើម្បីធានាឱ្យការអនុវត្តយុទ្ធនាការទី២នេះប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនិងស្របតាមគោលការណ៍ច្បាប់, គណៈបញ្ជាការដឹកនាំយុទ្ធនាការ, គណៈកម្មការដឹកនាំនិងអនុវត្តយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ(គ.ត.ម.)និងយន្តការដែលមានការពាក់ព័ន្ធត្រូវប្រកាន់ខ្ជាប់នូវអភិក្រមការងារដូចខាងក្រោម៖

-អតិក្រមការងារសម្រាប់ការអនុវត្តយុទ្ធនាការទី២៖

អតិក្រមទី១៖
មិនត្រូវធ្វើឱ្យ
ប៉ះពាល់ដល់ឯករាជ្យនៃ
អំណាចតុលាការ

អតិក្រមទី២៖
មិនត្រូវធ្វើបុរេវិនិច្ឆ័យលើ
ការសម្រេចសេចក្តីរបស់
តុលាការថា មិនប្រក្រតី

អតិក្រមទី៣៖
ត្រូវអនុវត្តប្រកបដោយ
តម្លាភាពតាមច្បាស់លាស់តាម
ត្រឹមត្រូវ និងយុត្តិធម៌

៣ - យន្តការដឹកនាំសម្របសម្រួលរួម សម្រាប់ធានាដល់ការអនុវត្ត យុទ្ធនាការទាំង ២



ដើម្បីជំរុញឱ្យយុទ្ធនាការទាំង ២ នេះ អាចអនុវត្តទៅបានប្រកបដោយប្រសិទ្ធភាព និងភាពជោគជ័យ **"គណៈបញ្ជាការដឹកនាំយុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការនិងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ"** ហៅកាត់ថា**"គណៈបញ្ជាការដឹកនាំយុទ្ធនាការ"**ជាអង្គដឹកនាំរួមលើការអនុវត្តយុទ្ធនាការទាំង២ដែលត្រូវបានបង្កើតឡើងតាមសេចក្តីសម្រេចលេខ ០១ កយ.សសរ/២៤ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ របស់ក្រសួងយុត្តិធម៌។ គណៈបញ្ជាការដឹកនាំយុទ្ធនាការនេះ មានតួនាទី និងភារកិច្ចសំខាន់ៗ ក្នុងការដាក់ចេញគោលការណ៍ណែនាំ និងវិធានចាំបាច់នានា និងដំណោះស្រាយចំពោះបញ្ហាប្រឈមនានាដែលកើតចេញពីការអនុវត្តយុទ្ធនាការទាំងនេះ,សម្របសម្រួលជាមួយក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធ ព្រមទាំងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធនាការទាំង២ ដើម្បីធានាឱ្យយុទ្ធនាការទាំង២នេះ អាចដំណើរ ការទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាព។

ក្នុងការអនុវត្តការងារនេះ, គណៈបញ្ជាការដឹកនាំយុទ្ធនាការ មានយន្តការចំណុះចំនួន ២ ដែលជាសេនាធិការប្រតិបត្តិការរួមមាន៖**(១)-គណៈកម្មការដឹកនាំនិងអនុវត្តយុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ** និង **(២)-គណៈកម្មការដឹកនាំ និងអនុវត្តយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ។**

ទន្ទឹមនេះ, គណៈបញ្ជាការដឹកនាំយុទ្ធនាការនេះ មានយន្តការសម្របសម្រួលនិងគាំទ្រចំនួន៣ ដូចខាងក្រោម៖

ទី១-ក្រុមវិភាគ និងប្រឹក្សាយោបល់ មានតួនាទីជាសារវន្តក្នុងការពិនិត្យ និងផ្តល់យោបល់ជាដំណោះស្រាយលើបញ្ហាប្រឈមនានាក្នុងការអនុវត្តយុទ្ធនាការ ទាំង២, ការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងគោលការណ៍ណែនាំ ឬវិធាននានា និងការពិនិត្យ និងផ្តល់យោបល់លើទិដ្ឋភាពច្បាប់ និងនីតិវិធីចំពោះសំណុំរឿងដែលមានលក្ខណៈស្មុគស្មាញ និងអាច មានភាពមិនប្រក្រតីក្នុងចំណាត់ការរបស់តុលាការតាមការប្រគល់ពីប្រធានគណៈបញ្ជាការដឹកនាំយុទ្ធនាការ។

ទី២-ក្រុមការងារព័ត៌មាននិងទំនាក់ទំនងសាធារណៈ:ទទួលបន្ទុកលើការងារព័ត៌មានការងារនាំពាក្យ និងទំនាក់ទំនងសាធារណៈ, ការប្រមូល ការតាមដាន និងការវិភាគព័ត៌មាន និងឯកសារពាក់ព័ន្ធ សម្រាប់ធ្វើការឆ្លើយតបជូនសាធារណជន និង/ឬ បណ្តាញផ្សព្វផ្សាយនានា ក៏ដូចជាទំនាក់ទំនងនិងការសម្របសម្រួលការងារជាមួយបណ្តាញសារព័ត៌មាន។

ទី៣-លេខាធិការដ្ឋាន គឺជាសេនាធិការរបស់ **គណៈបញ្ជាការដឹកនាំយុទ្ធនាការ និងយន្តការ** ចំណុះគណៈបញ្ជាការដឹកនាំយុទ្ធនាការ ក្នុងការគាំទ្រផ្នែករដ្ឋបាល និងផ្នែកបរិក្ខារវត្ថុ។ ទន្ទឹមនេះ, លេខាធិការដ្ឋានមានតួនាទីទទួលពាក្យបណ្តឹងនានារបស់ប្រជាពលរដ្ឋក្នុងក្របខ័ណ្ឌនៃយុទ្ធនាការទាំង ២នេះ, ពិនិត្យបែងចែក និងបញ្ជូនពាក្យបណ្តឹងទាំងនោះទៅគណៈកម្មការដឹកនាំ និងអនុវត្តយុទ្ធនាការនីមួយៗ និងសម្រប សម្រួលជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នពាក់ព័ន្ធដើម្បីផ្តល់មេធាវីស្ម័គ្រចិត្តក្នុងសំណុំរឿងនានា តាមការចាំបាច់ ក្នុងក្របខ័ណ្ឌនៃយុទ្ធនាការទាំង ២នេះ។

៤ - យន្តការសហការ និងគាំទ្រដល់យុទ្ធនាការទាំង ២



ដោយទទួលបានការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល និងដើម្បីធានាឱ្យយុទ្ធនាការទាំង ២ ប្រព្រឹត្តទៅដោយរលូន ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមានការចូលរួមការយល់គ្នា និងកិច្ចសហការពីស្ថាប័នអនុវត្តច្បាប់, **ក្រសួងយុត្តិធម៌** ក៏បានរៀបចំកិច្ចប្រជុំមួយជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, ថ្នាក់ដឹក នាំនៃសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់, អគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានរដ្ឋបាលតុលាការ ដើម្បីផ្សព្វផ្សាយ និងណែនាំអំពីការអនុវត្តយុទ្ធនាការទាំង ២ ខាងលើ ពិសេសការប្រកាន់យកអភិក្រមម៉ឺងម៉ាត់ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តយុទ្ធនាការទាំងនេះ ដែលជាកិច្ចការអាទិភាពខ្ពស់របស់**សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**។ ទន្ទឹមនេះដើម្បីទទួលបានការចូលរួមកិច្ចសហការ និងការគាំទ្រពីសំណាក់ស្ថាប័ន និងតួអង្គដែលមានការពាក់ព័ន្ធ, ក្រសួងយុត្តិធម៌ ក៏បានជួបប្រជុំជាមួយអង្គភាពប្រឆាំងអំពើពុករលួយ និងតួអង្គដែលមានការពាក់ព័ន្ធ ផ្សេងទៀតផងដែរ។



៥ - អភិក្រមក្នុងការដឹកនាំយុទ្ធនាការ ពន្យឺត និងលើកកម្ពស់សេវាយុត្តិធម៌ និងគុណភាពនៃយុត្តិធម៌



ក្នុងការដឹកនាំយុទ្ធនាការទាំង២នេះគណៈបញ្ជាការដឹកនាំយុទ្ធនាការនឹងប្រកាន់ខ្ជាប់នូវអភិក្រមចំនួន២ ៖ **អភិក្រមទី១** ជាអភិក្រមដ៏ថ្លៃថ្លារបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ពាក់ព័ន្ធនឹងការងារកែទម្រង់និង**អភិក្រមទី២**ជាអភិក្រមដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ពាក់ព័ន្ធនឹងការពង្រឹងអភិបាលកិច្ច។

- អភិក្រមរបស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** ៖ **“គ្មានការកែទម្រង់ណាមួយដែលងាយស្រួលនោះទេ ការកែទម្រង់ដែលជោគជ័យត្រូវផ្អែកលើកត្តាសំខាន់ៗចំនួន៤៖ (ទី១)- ត្រូវមានចក្ខុវិស័យច្បាស់លាស់, (ទី២)-ត្រូវមានការប្តេជ្ញាចិត្តខ្ពស់, (ទី៣)-ត្រូវមានការចូលរួមដោយស្មោះត្រង់ និង (ទី៤)-ត្រូវមានការលះបង់”**។

-អភិក្រមរបស់ **សម្តេចតេជោ ហ៊ុន សែន** គឺមាន៥ចំណុចៈ**(ទី១)-ឆ្ពុះកញ្ចក់**,(ទី២)-**ងូតទឹក**, (ទី៣)-**ដុសភ្លែ**, **(ទី៤)-ព្យាបាល** និង (ទី៥)-**វះកាត់**។



សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ផ្អែកលើអភិក្រមទាំងនេះ ច្បាស់ណាស់, សម្រាប់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលានិងមន្ត្រីតុលាការព្រមទាំងតួអង្គដែលមានការពាក់ព័ន្ធណាដែលប្រព្រឹត្តកំហុសក្នុងអំឡុងយុទ្ធនាការ ឬដែលបានឆ្លៀតយកឱកាសនៃយុទ្ធនាការនេះ ដើម្បីស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួនតាមរបៀប **“ត្រីងៀតឆ្លៀតពង”** នឹងត្រូវកត់ត្រាទុកជាកំហុស ដែលត្រូវឆ្លើយតបយ៉ាងម៉ឺងម៉ាត់ជាមួយនឹងការទទួលខុសត្រូវទាំងផ្នែកវិជ្ជាជីវៈទាំងផ្នែកផ្លូវច្បាប់ជាពិសេសការប្រើប្រាស់នូវអភិក្រមទី៥ របស់ សម្តេចតេជោ ហ៊ុន សែន គឺ **"ការវះកាត់"** និងអភិក្រមទី៤ របស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** គឺ **"ការលះបង់"**។ **“ការលះបង់”** និង **“ការវះកាត់”** គឺធ្វើឡើងតាមរយៈការអនុវត្តវិធានការវិន័យតឹងរឹង និងការអនុវត្តវិធានការច្បាប់ម៉ឺងម៉ាត់ ចំពោះចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងមន្ត្រីតុលាការ ព្រមទាំងតួអង្គពាក់ព័ន្ធទាំងអស់។ ផ្ទុយទៅវិញគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ រួមទាំង ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជីអាជ្ញាសាលា និងមន្ត្រីតុលាការ ដែលបានចូលរួមអនុវត្តការងារក្នុងក្របខ័ណ្ឌនៃយុទ្ធនាការនេះ បានត្រឹមត្រូវ និងទទួលបានលទ្ធផលល្អ នឹងត្រូវបានកត់ត្រាទុកជាគុណសម្បត្តិការងារដែលនឹងក្លាយជាមូលដ្ឋានសម្រាប់ការលើកទឹកចិត្តនាពេលខាងមុខស្របតាមគោលការណ៍ **"គុណាធិបតេយ្យ"**។

ជារួម ការដាក់ចេញនូវយុទ្ធនាការទាំង ២ ខាងលើនេះ នឹងជំរុញឱ្យសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ យកចិត្តទុកដាក់ដោះស្រាយវិវាទនានាឱ្យបានលឿន និងឱ្យបានត្រឹមត្រូវដោយធានាបានទាំងគុណភាពនៃការផ្តល់សេវាទាំងគុណភាពនៃការសម្រេចសេចក្តីរបស់តុលាការ។ ការដោះស្រាយវិវាទប្រកបដោយភាពឆាប់រហ័ស ត្រឹមត្រូវនិងយុត្តិធម៌នឹងពង្រឹងបាននូវជំនឿទុកចិត្តលើការអនុវត្តច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ចនិងប្រព័ន្ធតុលាការនៅកម្ពុជាដែលនឹងរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់ **"គោលការណ៍នីតិរដ្ឋ"** និង **"យុត្តិធម៌នៅក្នុងសង្គមជាតិ"** ស្របតាមទិសដៅកែទម្រង់ប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល ជាពិសេសបំណងប្រាថ្នារបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ នីតិកាលទី៧ នៃរដ្ឋសភា ក្នុងការយកចិត្តទុកដាក់ដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋដែលរងគ្រោះដោយអយុត្តិធម៌ ឬដោយការរំលោភបំពានដោយខុសច្បាប់នៅក្នុងសង្គម។

សសរស្តម្ភ ទី២-

ការកែទម្រង់ប្រព័ន្ធដោះស្រាយវិវាទនៅកម្ពុជា តាមរយៈការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការសម្រេចឱ្យបានជោគជ័យនូវកិច្ចការអាទិភាពទី១ក្នុងវិធានការគន្លឹះទី៥របស់**សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**, អាជ្ញាធរថ្នាក់ជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ហៅកាត់ថា "អ.ដ.ក." ត្រូវបានបង្កើតឡើងជាផ្លូវការដោយព្រះរាជក្រឹត្យលេខ នស/រកត/ ១១២៣/ ២៣៨១ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការបង្កើតការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

ការបង្កើតបាននូវអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះគឺជា **"ការបោះជំហានថ្មីមួយដ៏សំខាន់"** នៅក្នុងកិច្ចការកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។ អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះជាយន្តការថ្មីមួយបំពេញបន្ថែមឱ្យយន្តការដោះស្រាយវិវាទដែលមានស្រាប់បច្ចុប្បន្ននៅកម្ពុជា សំដៅចូលរួមចំណែកអភិវឌ្ឍប្រព័ន្ធយុត្តិធម៌និងលើកកម្ពស់សិទ្ធិទទួលបានយុត្តិធម៌សម្រាប់បុគ្គលគ្រប់រូបនៅមូលដ្ឋាន និងសហគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យកាន់តែប្រសើរឡើងតាមរយៈ៖ **(១)**-ការរក្សាបាននូវចរិតនៃការដោះស្រាយវិវាទក្នុងមូលដ្ឋានស្របតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ,**(២)**-ការបញ្ចប់វិវាទឬរំលត់វិវាទដែលកើតមាននៅមូលដ្ឋានជាក់ស្តែង សំដៅចូលរួមកាត់បន្ថយនូវសំណុំរឿងនៅតាមសាលាជម្រះក្តីបានមួយចំនួនផងដែរ និង **(៣)**-ធានាបាននូវភាពសុខដុមរមនារបស់ប្រជាជនដែលជាកោសិការបស់សង្គម និងធានាបាននូវស្ថិរភាពតាមរយៈការលើកកម្ពស់វប្បធម៌សន្តិភាពនិយមនិងការពន្លត់បាននូវភ្លើងវិវាទនៅក្នុងសង្គម។

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះមានលក្ខណៈស្របទៅនឹងប្រពៃណីនៃការដោះស្រាយវិវាទនៅក្នុងសង្គមកម្ពុជា។ ការប្រើប្រាស់យន្តការសម្របសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះមិនមែនត្រឹមតែពេញនិយមនៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែប្រទេសនានា ក៏បាននិងកំពុងប្រើប្រាស់យន្តការនេះផងដែរ ព្រោះជាយន្តការដោះស្រាយវិវាទមួយដែលធានាបានភាពឆាប់រហ័សហើយធានាបានភាពឈ្នះ-ឈ្នះ។ សម្រាប់កម្ពុជា, ការដោះស្រាយវិវាទតាមការសម្របសម្រួលគ្នាដោយធានាបានភាពឈ្នះ-ឈ្នះនេះ គឺមានមូលដ្ឋានគ្រឹះនៅក្នុង **"ន‌យោបាយ ឈ្នះ-ឈ្នះ"** របស់ **សម្តេចតេជោ ហ៊ុន សែន** ដែលមិនមែនត្រឹមតែជាការដោះស្រាយវិវាទធម្មតានោះទេ ប៉ុន្តែ **"ន‌យោបាយឈ្នះ-ឈ្នះ"** នេះគឺជារូបមន្តដ៏ស័ក្តិសិទ្ធិក្នុងការដោះស្រាយផ្សះផ្សាបាននូវការបែកបាក់ជាតិ និងការពន្លត់បានទាំងស្រុងនូវភ្លើងសង្គ្រាមដ៏រាំរៃនៅកម្ពុជា ហើយបាននាំមកនូវការបង្រួបបង្រួមជាតិ,ការឯកភាពជាតិ និង សន្តិភាពពេញបរិបូរណ៍ជូនជាតិ មាតុភូមិ និង ប្រជាជនកម្ពុជារហូតមកដល់ពេលបច្ចុប្បន្ន។

រូបភាពកិច្ចប្រជុំលើកទី១ របស់ អ.ដ.ក.











ការបង្កើតយន្តការ **អ.ដ.ក.** នេះ នឹងផ្តល់ជាជម្រើសថ្មីមួយដែល **"កាន់តែងាយស្រួល, កាន់តែសម្បូរបែប,កាន់តែទិតជិតប្រជាពលរដ្ឋនៅមូលដ្ឋាននិងកាន់តែមានប្រសិទ្ធភាពក្នុងការដោះស្រាយវិវាទ"** ជូនប្រជាពលរដ្ឋដែលមានបំណងស្វែងរកការសម្រុះសម្រួលដោះស្រាយបញ្ហាប់វិវាទរបស់ខ្លួនឱ្យបានឆាប់។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទរបស់ **អ.ដ.ក.** នឹងក្លាយ ទៅជាភ្នាក់ងារដ៏សំខាន់ដើម្បីរួមចំណែកក្នុងការជួយពន្លត់ភ្លើងនៃវិវាទនៅក្នុងសង្គមកម្ពុជាដោយមិនទុកឱ្យវិវាទក្លាយទៅជាវិវាទរ៉ាំរ៉ៃពិបាកដោះស្រាយ។ ដើម្បីធានាបាននូវជំនឿទុកចិត្ត និងប្រសិទ្ធភាពនៃការសម្រុះសម្រួលផ្សះផ្សាវិវាទដោយ **អ.ដ.ក.**, ព្រះរាជក្រឹត្យបង្កើត **អ.ដ.ក.** បានបង្កើតនូវរបបគតិយុត្តពិសេស ដោយផ្តល់ឱ្យ **"កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ"** ដែលធ្វើឡើងត្រឹមត្រូវស្របតាមព្រះរាជក្រឹត្យនេះនូវតម្លៃជាភស្តុតាងផ្លូវច្បាប់រឹងមាំនៅចំពោះមុខតុលាការផង និងមានអានុភាពអនុវត្តដូចសាលក្រមស្ថាពររបស់តុលាការផង។

បច្ចុប្បន្ន **អ.ដ.ក.** បានជ្រើសរើស និងផ្តល់នីតិសម្បទាដល់មន្ត្រីសម្រុះសម្រួលវិវាទនៃ **អ.ដ.ក.** ដែលបានទទួលការបណ្តុះបណ្តាលដោយជោគជ័យ ហើយ **អ.ដ.ក.** ក៏បានរៀបចំរួចរាល់នូវរាល់បែបបទនិងនីតិវិធីសម្រាប់ដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខណ្ឌ**អ.ដ.ក.**រួចរាល់ផងដែរ។

ការសម្រុះសម្រួលផ្សះផ្សារវិវាទដោយ **អ.ដ.ក.** បានចាប់ផ្តើមដំណើរការ និងទទួលបានជោគជ័យជាបន្តបន្ទាប់ផងដែរ។ ជាជំហានបន្ទាប់**អ.ដ.ក.**នឹងបន្តចុះដោះស្រាយសម្រុះសម្រួលផ្សះផ្សាវិវាទរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ជាពិសេស នៅតំបន់ដាច់ស្រយ៉ាល។



រូបភាពនៃកិច្ចប្រជុំសម្រុះសម្រួលវិវាទដោយ អ.ដ.ក.

ការកែទម្រង់យន្តការដឹកនាំ ការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌



សម្រាប់នីតិកាលទី៧ នៃរដ្ឋសភានេះ ដើម្បីធានានិរន្តភាព និងលើកកម្ពស់ប្រសិទ្ធភាព នៃការកែទម្រង់ច្បាប់ និងការកែទម្រង់ប្រព័ន្ធយុត្តិធម៌, រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបំបែកការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជា២ ដាច់ដោយឡែកពីគ្នាគឺ **"ការកែទម្រង់ច្បាប់"** និង **"ការទម្រង់ប្រព័ន្ធយុត្តិធម៌"** ហើយបានរំលាយគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នេះ ដោយបង្កើតជាយន្តការទទួលបន្ទុកចំនួន២គឺ**(ទី១)-"គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌"** ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល ជាសហប្រធាន ដើម្បីជាយន្តការទទួលបន្ទុកលើ**"ការទម្រង់ប្រព័ន្ធយុត្តិធម៌"** និង **(ទី២)-"គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់"** ដែលដឹកនាំដោយរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជាយន្តការទទួលបន្ទុកលើ**"ការកែទម្រង់ច្បាប់"**។

គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/២៦៨២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីជាយន្តការដឹកនាំសម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សំដៅពង្រឹង និងលើកកម្ពស់គោលការណ៍នីតិរដ្ឋ ព្រមទាំងគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌នៅព្រះរាជាណាចក្រកម្ពុជា។ បេសកកម្មរបស់គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌នឹងផ្តោតសំខាន់លើ**"ការកែទម្រង់ច្បាប់ក្នុងវិស័យយុត្តិធម៌"** និង **"ការទម្រង់ប្រព័ន្ធយុត្តិធម៌"**។

ដោយឡែក **គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់** ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី ០៣ ខែកុម្ភៈឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ដើម្បីជាយន្តការដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ច្បាប់ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណងដើម្បីពង្រឹង និងលើកកម្ពស់គោលការណ៍នីតិរដ្ឋសន្តិសុខគតិយុត្តព្រមទាំងគុណភាព និងប្រសិទ្ធភាពនៃច្បាប់។

គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ បានចាប់ផ្តើមដំណើរការកិច្ចប្រជុំលើកទី១ របស់ខ្លួននៅថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០២៤ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** និង **ឯកឧត្តមបណ្ឌិត ជិន ភេង ប្រធានតុលាការកំពូល** ជាសហប្រធាន។

ជាលទ្ធផល គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ បានឯកភាពគាំទ្រយ៉ាងពេញលេញចំពោះយុទ្ធនាការសំខាន់ទាំង២ដែលត្រូវបានប្រកាសដាក់ចេញដោយក្រសួងយុត្តិធម៌ កាលពីថ្ងៃទី ៩ ខែមករា ឆ្នាំ ២០២៤ កន្លងទៅ។

ទន្ទឹមនេះដោយពិនិត្យឃើញថាយុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាពជាច្រើនសម្រាប់អនុវត្តយុទ្ធសាស្ត្រកែទម្រង់ច្បាប់ និងតុលាការ ដែលត្រូវបានដាក់ចេញតាំងពីឆ្នាំ ២០០៣ និង ២០០៥ ត្រូវបានអនុវត្តប្រកបដោយជោគជ័យ ប៉ុន្តែឯកសារ**"ការកែទម្រង់ច្បាប់ និងតុលាការ"** និងឯកសារ **"កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និងតុលាការ"** មិនធ្លាប់ត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីសមិទ្ធផលការងារដែលសម្រេចបាន និងឱ្យស្របតាមបរិការណ៍នៃតម្រូវការជាក់ស្តែងបច្ចុប្បន្នរបស់សង្គម-សេដ្ឋកិច្ច និងបរិការណ៍នៃឱជីថលូបនីយកម្មនៅឡើយទេ និងជាពិសេសដើម្បីបង្កើនល្បឿន នៃការកែទម្រង់វិស័យយុត្តិធម៌ឱ្យកាន់តែសកម្មម៉ឺងម៉ាត់ និងមុតស្រួចឆ្លើយតបបានទៅនឹងស្ថានភាពវិវត្តផ្នែកសង្គម-សេដ្ឋកិច្ចនិងបច្ចេកវិទ្យា ស្របតាមទិសដៅដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ព្រមទាំងដើម្បីរួមចំណែកក្នុងការសម្រេចឱ្យបាននូវ**"ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"**ក្នុងការប្រែក្លាយខ្លួនជាប្រទេសដែលមានចំណូលខ្ពស់នៅត្រឹមឆ្នាំ ២០៥០, គណៈកម្មាធិការដឹកនាំការ កែទម្រង់ប្រព័ន្ធយុត្តិធម៌ក៏បានសម្រេចឱ្យមានការរៀបចំឡើងនូវផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌រយៈពេល ១០ឆ្នាំ ដោយប្រគល់ភារកិច្ចជូនអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌** ដើម្បីដឹកនាំរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រនេះ។







រូបភាពនៃកិច្ចប្រជុំលើកទី១ របស់គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌

ផ្នែកទី ២

អត្ថបទស្រាវជ្រាវ
និង
វិភាគផ្នែកច្បាប់

អំណាចតុលាការ នៅក្នុងច្បាប់កម្ពុជា



ដោយ៖

-ឯកឧត្តម **សន សោភ័ណ** អនុរដ្ឋលេខាធិការ

-ឯកឧត្តម **ចាយ ច័ន្ទសារាវឌ្ឍ** ចៅក្រមតុលាការកំពូល

-ឯកឧត្តម **ម៉ុង មុនីចរិយា** ប្រធានសាលាឧទ្ធរណ៍ឃ្លាំង

នៅក្នុងការគ្រប់គ្រងរដ្ឋតាមបែប**"នីតិរដ្ឋ"**និង**"ប្រជាធិបតេយ្យ"**,អំណាចកំពូលទាំង៣ដែលតែងត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ រួមមាន **អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ** និង **អំណាចតុលាការ**។ ស្របតាមគោលការណ៍នៃការបែងចែកអំណាចសំដៅធានាបានតុល្យភាពនៃការប្រើប្រាស់អំណាចក្នុងការគ្រប់គ្រងរដ្ឋ, អំណាចកំពូលទាំង ៣ នេះត្រូវបានចែកដាច់ពីគ្នា និងមានឯករាជ្យភាពពីគ្នាទៅវិញទៅមក ដែលមានន័យថាអំណាចទាំង៣នេះមិនចំណុះឱ្យគ្នាទៅវិញទៅមកនោះទេ ពោលគឺអំណាចតុលាការមិនចំណុះឱ្យ ឬមិនស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់អំណាចនីតិប្បញ្ញត្តិឬអំណាចនីតិប្រតិបត្តិនិងបញ្ច្រាសមកវិញ។នៅក្នុងសង្គមនីតិរដ្ឋ, អំណាចតុលាការ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់, ការការពារប្រឆាំងនឹងការរំលោភបំពានដោយអយុត្តិធម៌ក្នុងសង្គម និងបានចូលរួមចំណែកក្នុងការធានាថែរក្សានូវសន្តិសុខ, សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម ដែលជាគ្រឹះសម្រាប់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានអនុម័តនូវគោលការណ៍នៃការបែងចែកអំណាចនេះ ហើយអំណាចតុលាការត្រូវបានកំណត់នៅក្នុងជំពូកទី១១ ថ្មី នៃរដ្ឋធម្មនុញ្ញ។ ផ្អែកតាមមាត្រា១២៨ ថ្មី (មាត្រា១០៩ ចាស់) នៃរដ្ឋធម្មនុញ្ញ, អំណាចតុលាការ ជាអំណាចឯករាជ្យ ហើយអំណាចតុលាការធានារក្សាអនាគតិនិងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។តើអ្វីទៅជាអំណាចតុលាការ? តើស្ថាប័នណាជាអ្នកប្រតិបត្តិអំណាចតុលាការ? តើឯករាជ្យភាពនៃអំណាចតុលាការមានន័យដូចម្តេច និងត្រូវបានការពារដោយរបៀបណា?

ជាទ្រឹស្តីពាក្យថាអំណាចតុលាការអាចមានអត្ថន័យ២យ៉ាងគឺ(១)-អំណាចតុលាការក្នុងន័យស្ថាប័ន ដែលសំដៅដល់ស្ថាប័នតុលាការ និង (២)-អំណាចតុលាការ ក្នុងន័យជាសិទ្ធិអំណាចដែលសំដៅដល់អំណាចក្នុងការជម្រះក្តីផ្តល់យុត្តិធម៌។

I- អំណាចតុលាការក្នុងន័យជាអង្គការតុលាការ

ក្នុងន័យស្ថាប័នអំណាចតុលាការគឺជាអំណាចឯករាជ្យ ហើយគ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការនេះបានឡើយ[1]។ អំណាចតុលាការ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។ អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។ការរៀបចំអង្គការតុលាការត្រូវកំណត់ក្នុងច្បាប់។

1. មាត្រា១៣០ ថ្មី (មាត្រា ១១១ ចាស់) នៃរដ្ឋធម្មនុញ្ញ។

បច្ចុប្បន្ន ការរៀបចំអង្គការតុលាការនៅកម្ពុជា ដែលជាសាលាជម្រះក្តីទទួលបន្ទុកអនុវត្តនូវអំណាចតុលាការ (១) ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤[2]។ ច្បាប់នេះ និងច្បាប់ផ្សេងទៀត ក៏កំណត់ផងដែរអំពីវិធានដើម្បីធានា និងការពារនូវឯករាជ្យភាពនៃអំណាចតុលាការ (២)។

១- សាលាជម្រះក្តីជាស្ថាប័នដែលអនុវត្តអំណាចតុលាការ

ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ បានកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការតុលាការគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ដែលជាសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា។ យោងតាមមាត្រា៤ នៃច្បាប់នេះ, សាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់អនុវត្តអំណាចតុលាការ។ ផ្នែកតាមច្បាប់នេះ សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជារួមមានៈ សាលាដំបូង, សាលាឧទ្ធរណ៍ និងតុលាការកំពូល។ សាលាដំបូង ជាសាលាជម្រះក្តីជាន់ទាប ហើយសាលាឧទ្ធរណ៍ និងតុលាការកំពូល ជាសាលាជម្រះក្តីជាន់ខ្ពស់។ សាលាដំបូង ត្រូវបានបង្កើតឡើងនៅគ្រប់រាជធានី-ខេត្ត។ ចំពោះសាលាឧទ្ធរណ៍រួមមាន សាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់ ដែលបច្ចុប្បន្នរួមមាន សាលាឧទ្ធរណ៍បាត់ដំបង, សាលាឧទ្ធរណ៍ព្រះសីហនុ និងសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ ដោយឡែក តុលាការកំពូល មានតែមួយគត់នៅរាជធានីភ្នំពេញ[3]។

យោងតាមមាត្រា១២៨ ថ្មី កថាខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញ អំណាចតុលាការ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ហើយផ្នែកតាមមាត្រា ៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, សាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ អនុវត្តអំណាចតុលាការ។ ផ្នែកតាមបទប្បញ្ញត្តិទាំងនេះ មានតែសាលាជម្រះក្តីទេដែលអនុវត្តអំណាចតុលាការ។ ប៉ុន្តែ នៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ មានអង្គការអយ្យការមួយផងដែរ។ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ក៏បានកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការអយ្យការនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ដូច្នេះ បញ្ហាអាចចោទឡើងថា តើអង្គការអយ្យការជាផ្នែកមួយនៃអំណាចតុលាការដែរឬទេ? បើបកស្រាយតឹងរឹងតាមស្មារតីនៃមាត្រា១២៨ ថ្មីខាងលើ អំណាចតុលាការ ត្រូវប្រគល់ឱ្យតែតុលាការកំពូល

2. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ត្រូវបានអនុម័តនៅឆ្នាំ ២០១៤ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។
3. ដើម្បីយល់ច្បាស់អំពីរចនាសម្ព័ន្ធអង្គការតុលាការនៅកម្ពុជា, សូមអានអត្ថបទបន្ទាប់របស់ ឯកឧត្តម សេង ឌីណា នៅក្នុងព្រឹត្តិប័ត្រនេះ ដែលសរសេរអំពីរចនាសម្ព័ន្ធតុលាការនៅកម្ពុជា។

និងសាលាជម្រះក្តីប៉ុណ្ណោះ ពោលគឺ អង្គការអយ្យការមិនមែនជាស្ថាប័នអនុវត្តនូវអំណាចតុលាការនោះទេ។ ប៉ុន្តែ ផ្ទុយទៅវិញ អង្គការអយ្យការ និងព្រះរាជអាជ្ញា ក៏ត្រូវបានបញ្ជូតនៅក្នុងមាត្រា ១៣១ថ្មី (មាត្រា១១២ចាស់), មាត្រា១៣៤ថ្មី (មាត្រា១១៥ចាស់) និងមាត្រា១៣៥ថ្មី (មាត្រា ១១៦ចាស់) ក្រោមជំពូកទី១១ ថ្មី ស្តីពីអំណាចតុលាការផងដែរ។ មាត្រា១៣១ថ្មីនេះ កំណត់ថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ មាត្រា១៣២ថ្មី (មាត្រា១១៣ចាស់) បានកំណត់ថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជួយព្រះមហាក្សត្រក្នុងការធានាឯករាជ្យភាពនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសំណើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជម្រះក្តីទាំងអស់។ បន្ថែមពីនេះឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានមុខងារក្នុងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញាផងដែរ។ ប្រសិនបើអង្គការអយ្យការ ជាផ្នែកមួយនៃអំណាចតុលាការដែលជាអំណាចឯករាជ្យ នោះអង្គការអយ្យការក៏គួរត្រូវបានកំណត់ថា ជាអំណាចឯករាជ្យ ដូចនឹងសាលាជម្រះក្តីផងដែរ។

ប៉ុន្តែជាក់ស្តែងអង្គការអយ្យការ គឺជាតំណាងឱ្យអំណាចសាធារណៈដែលធ្វើបណ្តឹងអាជ្ញានិងសុំឱ្យអនុវត្តច្បាប់ ដើម្បីការពារផលប្រយោជន៍សាធារណៈ។ ផ្នែកតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, អង្គការអយ្យការជាអង្គឯកភាពដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។ នៅតាមអយ្យការអមសាលាដំបូងរាជធានី-ខេត្តព្រះរាជអាជ្ញាមានអំណាចលើព្រះរាជអាជ្ញារងទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួននិងមានសិទ្ធិធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ឬក៏ចាត់ឱ្យចោទ ប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ។ ដូចគ្នាផងដែរចំពោះ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់[4] ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់[5]។ ទន្ទឹមនេះការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាចាំបាច់ជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

4. មាត្រា៣១, មាត្រា៥១ និងមាត្រា៧០ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។
5. មាត្រា៧៥ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ ២០១៤។

ជាអ្នកលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ។ ក្នុងន័យនេះ អង្គការអយ្យការមិនមែនជាអំណាចឯករាជ្យនោះទេ តែជាអំណាចដែលស្ថិតក្រោមឋានានុក្រមច្បាស់លាស់ និងជាតំណាងឱ្យអំណាចសាធារណៈក្នុងការការពារផលប្រយោជន៍សាធារណៈ។ នៅបណ្តាប្រទេសផ្សេងៗអង្គការអយ្យការក៏មិនមែនជាអំណាចឯករាជ្យដែរ ដូចជាករណីនៅប្រទេសបារាំង ប្រទេសជប៉ុន និងប្រទេសកូរ៉េជាដើមដែលអយ្យការស្ថិតក្រោមឋានានុក្រមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

មាត្រា១២៨ថ្មីកថាខណ្ឌទី៣នៃរដ្ឋធម្មនុញ្ញនិងមាត្រា៤នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ បានកំណត់ថា អំណាចតុលាការ គ្របដណ្តប់លើរឿងក្តីទាំងអស់រួមទាំងរឿងក្តី រដ្ឋបាលផងដែរ។ ដោយអំណាចតុលាការគ្របដណ្តប់លើរឿងក្តីទាំងអស់,តើការបង្កើតឡើងនូវយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដោយស្ថាប័ននីតិប្រតិបត្តិ(ការសម្រុះសម្រួលឬការផ្សះផ្សាវិវាទ)ឬយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលមានសិទ្ធិសម្រេចក្តីតាមវិធីកាត់ក្តីដោយផ្អែកទាំងលើអង្គហេតុ និងអង្គច្បាប់ (អាជ្ញាកណ្តាល ឬមជ្ឈត្តការ) អាចត្រូវចាត់ទុកថាជាការរំលោភបំពានលើអំណាចតុលាការដែរឬទេ? ចំពោះបញ្ហានេះ យើងអាចគូសបញ្ជាក់បានថា ទោះបីអំណាចតុលាការគ្របដណ្តប់លើគ្រប់រឿងក្តីទាំងអស់ក៏ដោយ ប៉ុន្តែមិនមែនមានន័យថាច្បាប់បង្ខំឱ្យភាគីវិវាទត្រូវតែប្តឹងទៅតុលាការដើម្បីដោះស្រាយវិវាទរបស់ខ្លួននោះទេ។ ការសម្រេចប្តឹង ឬមិនប្តឹងទៅតុលាការឬការសម្រេចចិត្តស្វែងរកការសម្រុះសម្រួលផ្សះផ្សាវិវាទក្រៅប្រព័ន្ធតុលាការ គឺជាសិទ្ធិសម្រេចរបស់ភាគីវិវាទ លើកលែងតែចំពោះបទល្មើសព្រហ្មទណ្ឌ ដែលច្បាប់កំណត់ថាមិនអាចជាកម្មវត្ថុនៃការសម្រុះសម្រួលបញ្ចប់ក្រៅប្រព័ន្ធតុលាការតែប៉ុណ្ណោះ។ លើការជាក់ស្តែង ការស្វែងរកដំណោះស្រាយចំពោះវិវាទ តាមរយៈការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ បានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមនិងបានរួមចំណែកយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ចប់វិវាទបានឆាប់រហ័សព្រមទាំងអាចជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះក្តីផងដែរ។

២- ការធានាការពារឯករាជ្យភាពនៃអំណាចតុលាការ

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យភាពនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។ នៅប្រទេសបារាំង ផ្អែកតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៨ ប្រធានាធិបតីបារាំងដែលជាប្រមុខរដ្ឋក៏បំពេញតួនាទីជាអ្នកធានាឯករាជ្យនៃអាជ្ញាធរតុលាការ

ដោយមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយប្រធានាធិបតីក្នុងការងារនេះផងដែរ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមព្រះរាជធិបតីភាពនៃព្រះមហាក្សត្រ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខ័ណ្ឌ ការដាក់ឱ្យនៅទំនេរ និងការលុបឈ្មោះចៅក្រម និងព្រះរាជអាជ្ញាទាំងអស់។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យ និងសម្រេចលើក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា និងដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា។ មុខងារទាំងនេះ ជាមុខងារដ៏សំខាន់ក្នុងការធានានូវឯករាជ្យភាពនៃអំណាចតុលាការ។ ចៅក្រម ព្រះរាជអាជ្ញាទាំងអស់ ដែលប្រព្រឹត្តខុសនឹងក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា ក្នុងការអនុវត្តនូវមុខងាររបស់ខ្លួន អាចត្រូវស្ថិតក្រោមការសម្រេចដាក់វិន័យដោយក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ក្នុងករណីរកឃើញកំហុសក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចដាក់ទណ្ឌកម្មវិន័យ ដូចមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។ សេចក្តីសម្រេចនេះ ត្រូវមានសំអាងហេតុ និងសំអាងច្បាប់។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីពិនិត្យនិងសម្រេច។សេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។ប៉ុន្តែការសម្រេចអំពីទណ្ឌកម្មវិន័យនេះមិនរារាំងការចោទប្រកាន់តាមផ្លូវតុលាការនោះទេ ប្រសិនបើចៅក្រម ឬព្រះរាជអាជ្ញា បានប្រព្រឹត្តបទល្មើសណាមួយ។

ក្រៅពីមុខងារទាំងនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានសមត្ថកិច្ចផ្សេងទៀតផងដែរ ដែលរួមមានការផ្តល់យោបល់ចំពោះការដំឡើងថ្នាក់ និងការដំឡើងឋានន្តរស័ក្តិ ឬចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ តាមបែបបទ និងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងការពិគ្រោះយោបល់ជាចាំបាច់ដើម្បីផ្តល់យោបល់លើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ដែលទាក់ទងដល់ការរៀបចំវិស័យតុលាការ និងការប្រព្រឹត្តទៅនៃវិស័យនេះ។

II- អំណាចតុលាការក្នុងន័យជាអំណាចក្នុងការជម្រះក្តីផ្តល់យុត្តិធម៌

ក្នុងន័យទី២ អំណាចតុលាការ សំដៅដល់អំណាចក្នុងការជម្រះក្តីផ្តល់យុត្តិធម៌ជូនភាគីវិវាទ។ មាត្រា១២៨ថ្មីកថាខណ្ឌទី៣នៃរដ្ឋធម្មនុញ្ញនិងមាត្រា ៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ បានកំណត់ថា អំណាចតុលាការ គ្របដណ្តប់លើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។ ដោយបច្ចុប្បន្ន កម្ពុជាមិនទាន់មានតុលាការរដ្ឋបាល, រឿងក្តីរដ្ឋបាលទាំងអស់ ត្រូវស្ថិតក្រោមសមត្ថកិច្ច

ជំនុំជម្រះរបស់តុលាការរដ្ឋប្បវេណីដែលជាតុលាការនៃនីតិរួម។ មាត្រា១២៩ ថ្មី (មាត្រា១១០ ចាស់) កថាខណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ បានបញ្ជូតថា មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី (១)។ ក្នុងការជម្រះក្តីនេះចៅក្រមមានកាតព្វកិច្ចក្នុងការអនុវត្តនូវមុខងាររបស់ខ្លួនដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ ដើម្បីធានានូវឯករាជ្យភាពរបស់ចៅក្រមក្នុងការសម្រេចក្តី, ច្បាប់បានផ្តល់ឱ្យចៅក្រមនូវអំណាចឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយ។ ប៉ុន្តែ ការបំពានទឹងឆន្ទានុសិទ្ធិដោយខុសនឹងក្រមសីលធម៌ ឬខុសច្បាប់ ចៅក្រមអាចនឹងត្រូវប្រឈមមុខទាំងទណ្ឌកម្មខាងវិន័យ ទាំងទោសទណ្ឌផ្សេងទៀត ស្របតាមការកំណត់របស់ច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន (២)។

១- សិទ្ធិជម្រះក្តីរបស់ចៅក្រម និងឯករាជ្យភាពរបស់ចៅក្រម

មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី។ ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយឯករាជ្យ ដោយគោរពតាមច្បាប់ យ៉ាងម៉ត់ចត់ និងឱ្យអស់ពីដួងចិត្តនិងសតិសម្បជញ្ញៈរបស់ខ្លួន[6]។ ចៅក្រមទាំងឡាយ ត្រូវសម្រេចសេចក្តីដោយមិនលំអៀង ដោយឈរលើគោលការណ៍គោរពច្បាប់ ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីភាគីណាមួយក្នុងរឿងក្តីឬពីបុគ្គលណាមួយឡើយ[7]។ចៅក្រមត្រូវច្រានចោលនូវការប៉ុនប៉ងទាំងឡាយណាដែលធ្វើឱ្យមានឥទ្ធិពលដល់ការវិនិច្ឆ័យសេចក្តីរបស់ខ្លួន។ ប្រធានសាលាជម្រះក្តីនីមួយៗ មិនមានអំណាចហានានុក្រមលើការជម្រះក្តីរបស់ចៅក្រមក្នុងដែនសមត្ថកិច្ចរបស់ខ្លួននោះទេ។ ប្រធានសាលាជម្រះក្តីមានត្រឹមតែអំណាចហានានុក្រមផ្នែករដ្ឋបាលលើចៅក្រមតែប៉ុណ្ណោះ។

ក្នុងការជម្រះក្តី ចៅក្រមត្រូវស្វែងយល់ឱ្យបានច្បាស់អំពីអង្គហេតុ និងអង្គច្បាប់ មុននឹងធ្វើការសម្រេចសេចក្តីចំពោះសំណុំរឿងនីមួយៗ។សេចក្តីសម្រេចរបស់តុលាការ ត្រូវតែមានសំអាងហេតុ។ ចៅក្រមប្រើប្រាស់នូវឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការវាយតម្លៃអំពីអង្គហេតុ និងក្នុងការបកស្រាយច្បាប់ ក្នុងករណីដែលច្បាប់ចែងមិនច្បាស់។ ឆន្ទានុសិទ្ធិនេះគឺជាអំណាចដែលប្រគល់ឱ្យចៅក្រម អាចជ្រើសរើស យកមធ្យោបាយណាមួយ តាមការវាយតម្លៃរបស់ខ្លួន

6. មាត្រា៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។
7. មាត្រា៨ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា។

ដើម្បីដោះស្រាយបញ្ហាណាមួយ[8]។ ជារឿយៗ ច្បាប់តែងផ្តល់សិទ្ធិក្នុងការវាយតម្លៃដោយឆន្ទានុសិទ្ធិនេះឱ្យទៅចៅក្រមដើម្បីអាចផ្តល់នូវដំណោះស្រាយទៅតាមករណីជាក់ស្តែងនីមួយៗ។ ការវាយតម្លៃដោយឆន្ទានុសិទ្ធិនេះខុសពីការបកស្រាយច្បាប់។ក្នុងការជម្រះក្តីចៅក្រមនៃបណ្តាសាលាជម្រះក្តីមានស្វ័យភាពក្នុងការបកស្រាយច្បាប់។ ផ្នែកតាមគោលការណ៍ស្វ័យភាពយុត្តាធិការ, ការបកស្រាយរបស់ចៅក្រមនៃសាលាជម្រះក្តីជាន់ខ្ពស់ មិនមានអានុភាពចាប់បង្ខំឱ្យចៅក្រមនៃសាលាជម្រះក្តីជាន់ទាបត្រូវតែគោរពតាមនោះទេ លើកលែងតែចំពោះការសម្រេចអំពីវិវាទច្បាប់ដែលធ្វើឡើងដោយសភារួមក្រុមរបស់តុលាការកំពូល ដែលជាការសម្រេចបិទផ្លូវតវ៉ា។ ប៉ុន្តែលើការជាក់ស្តែងការមិនគោរពតាមការបកស្រាយច្បាប់របស់តុលាការកំពូលអាចធ្វើឱ្យសាលក្រមរបស់សាលាដំបូង ឬសាលដីការបស់សាលាឧទ្ធរណ៍ ត្រូវបានបដិសេធដោយតុលាការកំពូល[9]។ ក្នុងរឿងរដ្ឋប្បវេណី បើច្បាប់ចែងមិនច្បាស់ ឬច្បាប់មិនបានចែង ចៅក្រមត្រូវជំនុំជម្រះ ដោយផ្នែកតាមទំនៀមទំលាប់ ប្រពៃណី វិចារណញ្ញាណ ឬសមធម៌[10]។

២- ដែនកំណត់នៃឯករាជ្យភាព និងឆន្ទានុសិទ្ធិរបស់ចៅក្រម

ទោះបីចៅក្រម មានឯករាជ្យភាព និងឆន្ទានុសិទ្ធិក្នុងការជម្រះក្តីក៏ដោយ, ប៉ុន្តែ ចៅក្រមត្រូវគោរពច្បាប់ឱ្យបានម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ ទន្ទឹមនេះ ចៅក្រមត្រូវគោរពនូវក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា ក្នុងការបំពេញមុខងាររបស់ខ្លួន។ ក្រមសីលធម៌របស់ចៅក្រមនិងព្រះរាជអាជ្ញាមានគោលបំណងពង្រឹងនូវឯករាជ្យភាពនិងសេចក្តីថ្លៃថ្នូររបស់អង្គចៅក្រមក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនសំដៅលើកកម្ពស់ជំនឿទុកចិត្តលើប្រព័ន្ធតុលាការ និងកេរ្តិ៍ឈ្មោះរបស់ចៅក្រម។ ក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញានេះ បានកំណត់នូវគោលការណ៍ដែលអង្គចៅក្រមត្រូវប្រតិបត្តិតាម និងត្រូវចៀសវាង។ ផ្នែកតាមក្រមសីលធម៌នេះ, ក្នុងពេលបំពេញមុខងារ ចៅក្រមត្រូវប្រកាន់ខ្ជាប់នូវសុគតិធម៌ទាំង៥ រួមមាន ***វិរិយសម្បយុត្ត*** (ការបំពេញកិច្ចប្រកបដោយវិរិយភាព), ***សុចរិតយុត្តិធម៌*** (ភាពទៀងត្រង់ និងយុត្តិធម៌), ***បញ្ញត្តិការវោ*** (ការប្រតិបត្តិតាមច្បាប់ឱ្យបានម៉ឺងម៉ាត់), ***សមទណ្ឌោ*** (សមភាពនៃទណ្ឌកម្មទៅលើជនដែលប្រព្រឹត្តអំពើល្មើសដូចគ្នា) និង **បញ្ញាវុធវិនិច្ឆ័យ** (ការសម្រេចសេចក្តីប្រកបដោយ

8. សន្ធានុក្រមពាក្យច្បាប់ដែលរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី, ប្តោះពុម្ពលើកទី១ ឆ្នាំ២០០៧ ទំព័រទី ១០។
9. ញាន វណ្ណៈ, មូលដ្ឋានគ្រឹះនៃភាពជាអ្នកច្បាប់៖ បច្ចេកទេសគតិយុត្ត, ឆ្នាំ ២០១៤ ទំព័រ ២៥
10. មាត្រា៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជាឆ្នាំ ១៩៩៣។

បញ្ហា និងភាពឆ្លាតវៃ) និងត្រូវវៀចាកនូវអគតិធម៌ទាំង ៤ គឺ ***ឆន្ទាគតិ*** (លំអៀងព្រោះស្រលាញ់), ***ទោសាគតិ*** (លំអៀងព្រោះទោសៈ ឬស្អប់), ***ភយាគតិ*** (លំអៀងព្រោះភ័យខ្លាច) និង ***មោហាគតិ*** (លំអៀងព្រោះមោហៈ ល្ងង់ ឬអវិជ្ជា)។

ផ្អែកតាមមាត្រា ៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, ជាគោលការណ៍ ចៅក្រម និងព្រះរាជអាជ្ញា មិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬផ្នែករដ្ឋប្បវេណី ចំពោះការសម្រេចដែលបានធ្វើក្នុងក្របខ័ណ្ឌសមត្ថកិច្ច និងមុខងាររបស់ខ្លួនក្នុងឋានៈជាចៅក្រម ឬព្រះរាជអាជ្ញាឡើយ។ ប៉ុន្តែ គោលការណ៍នេះ មិនត្រូវយកមកអនុវត្តឡើយ ក្នុងករណីដែលចៅក្រម ឬព្រះរាជអាជ្ញា ប្រើប្រាស់ការសម្រេចរបស់ខ្លួនដោយរំលោភបំពានធ្ងន់ធ្ងរក្នុងចេតនាទុច្ចរិតលើសមត្ថកិច្ច និងមុខងារដែលច្បាប់ប្រគល់ឱ្យ។ ក្នុងន័យនេះ ការរំលោភអំណាច ឬការប្រព្រឹត្តខុសច្បាប់របស់ចៅក្រម ឬការប្រើឆន្ទានុសិទ្ធិរបស់ចៅក្រមដោយបំពាន គឺជាកំហុសដែលអាចត្រូវប្រឈមទាំងទណ្ឌកម្មខាងវិន័យ ទាំងទណ្ឌកម្មព្រហ្មទណ្ឌ និងទណ្ឌកម្មផ្នែករដ្ឋប្បវេណីផ្សេងទៀត តាមការកំណត់របស់ច្បាប់ជាធរមាន និងតាមអង្គហេតុជាក់ស្តែង។

ពាក្យបណ្តឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា ត្រូវដាក់នៅអគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬនៅក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់ឱ្យពិនិត្យ និងស្រាវជ្រាវបឋមលើពាក្យបណ្តឹងទាំងនេះ ដើម្បីកសាងសំណុំរឿងវិន័យ មុននឹងបញ្ជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីចាត់នីតិវិធីបន្ត។ បន្ទាប់ពីទទួលបានសំណុំរឿងវិន័យក្នុងករណីចាំបាច់ ប្រធានក្រុមប្រឹក្សាវិន័យ អាចចាត់ឱ្យមានការស៊ើបអង្កេត និងស្រាវជ្រាវបន្ថែមដោយប្រើយន្តការក្រុមអធិការកិច្ចនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ក្នុងករណីរកឃើញកំហុសក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចដាក់វិន័យ ដូចមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា។សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យត្រូវមានសំអាងហេតុ និងសំអាងច្បាប់។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីពិនិត្យនិងសម្រេច។សេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

រចនាសម្ព័ន្ធតុលាការកម្ពុជា



ដោយៈ
-ឯកឧត្តម **សេខ ឌីណា** រដ្ឋលេខាធិការក្រសួងយុត្តិធម៌
និងជាអនុប្រធានបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា

I-អំពីប្រវត្តិនៃការបង្កើតប្រព័ន្ធតុលាការរបស់កម្ពុជា

ប្រព័ន្ធតុលាការកម្ពុជានៅសម័យបុរាណ ទទួលឥទ្ធិពលពីច្បាប់ខ្មែរបុរាណ ដែលជាច្បាប់ផ្ទាល់មាត់ និងគ្របដណ្តប់ដោយឥទ្ធិពលនៃសាសនា។ ព្រះមហាក្សត្រ ដែលជាតំណាងអាទិទេព មានអំណាចគ្រប់យ៉ាង រាប់ទាំងអំណាចធ្វើសវនាការដោះស្រាយរឿងក្តីគ្រប់ប្រភេទផង។ ព្រះមហាក្សត្រទ្រង់មានមន្ត្រីមួយរូបជាជំនួយក្នុងកិច្ចការយុត្តិធម៌គឺ **"ឧកញ៉ាយមរាជ"** ដែលចាត់ទុកដូចជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម័យបច្ចុប្បន្ន។

នៅក្រោយពេលដែលបារាំងបានមកដាក់អាណាព្យាបាលលើកម្ពុជា កាលពីឆ្នាំ១៨៦៣ ប្រព័ន្ធតុលាការកម្ពុជាដែលធ្លាប់មានកន្លងមកនៅតែបន្តអនុវត្តសម្រាប់ដោះស្រាយវិវាទរវាងខ្មែរនិងខ្មែរ។ចំណែកវិវាទរវាងបរទេសនិងខ្មែរឬរវាងបរទេសនិងបរទេសត្រូវស្ថិតក្រោមយុត្តាធិការនៃប្រព័ន្ធតុលាការបែបបារាំង។ ក្រោយមកទៀត ប្រព័ន្ធតុលាការកម្ពុជាបុរាណក៏ត្រូវបានកែប្រែបន្តិចម្តងៗរហូតក្លាយជាប្រព័ន្ធតុលាការដែលយកតាមទម្រង់ដូចគ្នាទៅនឹងប្រព័ន្ធតុលាការបារាំង។

រចនាសម្ព័ន្ធតុលាការតាមបែបបារាំងនេះនៅតែបន្តអនុវត្តក្រោយពេលដែលកម្ពុជាទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ រហូតមកដល់របបកម្ពុជាប្រជាធិបតេយ្យ។ ប្រព័ន្ធតុលាការកម្ពុជានៅពេលនោះ ត្រូវបានបែងចែកជា សាលាលហុ (ឬ សាលាលុឃុន) និង សាលាជំបូង ដែលជាសាលាជម្រះក្តីជាន់ទាប ត្រូវបានបង្កើតឡើងនៅភ្នំពេញ និងនៅតាមបណ្តាខេត្តទូទាំងប្រទេស ហើយមានសមត្ថកិច្ចគ្របដណ្តប់លើដែនដីដែលសាលាជម្រះក្តីនោះស្ថិតនៅ និងសាលាឧទ្ធរណ៍ សាលាឧក្រិដ្ឋ និងសាលាវិនិច្ឆ័យ ដែលមានតែនៅរាជធានីភ្នំពេញប៉ុណ្ណោះ និងមានសមត្ថកិច្ចគ្របដណ្តប់លើដែនដីនៃប្រទេសកម្ពុជាទាំងមូល[1]។

នៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានធ្លាក់ចូលទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលអ្វីៗត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង ដោយក្នុងនោះប្រព័ន្ធតុលាការក៏ត្រូវបានលុបបំបាត់ចោលផងដែរ។ រហូតដល់ពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ទើបប្រព័ន្ធតុលាការកម្ពុជាត្រូវបានបង្កើតឡើងវិញនៅឆ្នាំ១៩៨០ដោយក្រឹត្យច្បាប់លេខ ០១ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០ របស់ក្រុមប្រឹក្សារដ្ឋ ដោយគ្រានោះកម្ពុជាបានបង្កើតឱ្យមានឡើងវិញនូវ **"តុលាការប្រជាជនបដិវត្តខេត្ត-ក្រុង"** ដែលក្រោយមកត្រូវបានប្តូរឈ្មោះទៅជា **"តុលាការប្រជាជនខេត្ត-ក្រុង និងអយ្យការអមតុលាការប្រជាជនខេត្ត-ក្រុង"** នៅឆ្នាំ១៩៨២។ នៅពេលនោះ តុលាការកម្ពុជា គឺមានតែមួយថ្នាក់តែប៉ុណ្ណោះ។ បន្ទាប់មកនៅឆ្នាំ១៩៨៥ តុលាការកំពូល ដែលមានឈ្មោះ ថា **"តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល"** ត្រូវបានបង្កើតឡើងដោយក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨៥។ គិតមកទល់ពេលនោះកម្ពុជាមានតែតុលាការខេត្ត-ក្រុងនិងតុលាការកំពូលតែប៉ុណ្ណោះដោយពុំទាន់មានសាលាឧទ្ធរណ៍នោះទេ។រហូតមកដល់ឆ្នាំ១៩៩២ទើប **"សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍"** ត្រូវបានបង្កើតឡើង ដោយមានទីតាំងនៅរាជធានីភ្នំពេញ ហើយមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីទាំងមូលនៃរដ្ឋកម្ពុជា និងដោះស្រាយគ្រប់សំណុំរឿងទាំងអស់។ រចនាសម្ព័ន្ធតុលាការនេះ ត្រូវបានបន្តអនុវត្តរហូតដល់មានច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ២០១៤ និងព្រះរាជក្រឹត្យឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ចំនួន៣រួមមាន សាលាឧទ្ធរណ៍ព្រះសីហនុ សាលាឧទ្ធរណ៍ត្បូងឃ្មុំ និងសាលាឧទ្ធរណ៍បាត់ដំបង បន្ថែមពីលើសាលាឧទ្ធរណ៍ភ្នំពេញដើម្បីបង្កើតសេវាយុត្តិធម៌ឱ្យកាន់តែទំនិតជិតប្រជាពលរដ្ឋនិងលើកកម្ពស់គុណភាពនៃការផ្តល់សេវាយុត្តិធម៌នេះ ព្រមទាំងដើម្បីដោះស្រាយបញ្ហាកកស្ទះសំណុំរឿងដែលត្រូវប្រមូលផ្តុំនៅតែសាលា ឧទ្ធរណ៍ភ្នំពេញ។

II-រចនាសម្ព័ន្ធតុលាការកម្ពុជាបច្ចុប្បន្ន

ប្រព័ន្ធតុលាការកម្ពុជាបច្ចុប្បន្នស្ថិតនៅក្រោមការគ្រប់គ្រងដោយច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ និងត្រូវបានព្រះមហាក្សត្រប្រកាសឱ្យប្រើនៅថ្ងៃទី១៦ខែកក្កដាឆ្នាំ២០១៤។យោងតាមច្បាប់នេះប្រព័ន្ធតុលាការកម្ពុជាត្រូវបានចែកចេញជា ២ ថ្នាក់ គឺ **តុលាការជាន់ទាប** (១) និង **តុលាការជាន់ខ្ពស់** (២) ហើយតុលាការទាំង ២ ថ្នាក់នេះអនុវត្តអំណាចតុលាការដែលគ្របដណ្តប់លើរឿងក្តីគ្រប់ប្រភេទរួមទាំងរឿងក្តីផ្នែករដ្ឋបាល[2] ផងដែរ។

១.តុលាការជាន់ទាប

តុលាការជាន់ទាបរួមមានសាលាដំបូងដែលត្រូវបានបង្កើតឱ្យមាននៅរាជធានីភ្នំពេញនិងនៅគ្រប់បណ្តាខេត្តនៃព្រះរាជាណាចក្រកម្ពុជា និងតុលាការយោធាដែលមានទីតាំងនៅរាជធានីភ្នំពេញ និងមានសមត្ថកិច្ចលើគ្រប់រឿងក្តីទូទាំងប្រទេសពាក់ព័ន្ធនឹងបទល្មើសយោធា។

1. សៀវភៅ "សង្គមវិជ្ជា", គីម សែត, ឆ្នាំ១៩៦០, ទំព័រទី០៧ ដល់ ៨៤

2. មាត្រា ៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

ក-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

(១)-សាលាដំបូង

សាលាដំបូង គឺជាសាលាជម្រះក្តីទូទៅ ដែលមានសមត្ថកិច្ចជំនុំជម្រះលើរឿងក្តីទាំងអស់ លើកលែងតែរឿងក្តីដែលស្ថិតក្រោមសមត្ថកិច្ចនៃសាលាជម្រះក្តីពិសេស ជាអាទិ៍ តុលាការយោធា ឬសាលាជម្រះក្តីវិសាមញ្ញជាអាទិ៍អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានបង្កើតឡើងដោយច្បាប់ដោយឡែក[3]។ សាលាដំបូង ត្រូវបែងចែកជាតុលាការជំនាញ[4] ដែលរួមមាន **តុលាការព្រហ្មទណ្ឌ តុលាការរដ្ឋប្បវេណី តុលាការពាណិជ្ជកម្ម និងតុលាការការងារ**។ តុលាការជំនាញផ្សេងទៀតរបស់សាលាដំបូង អាចត្រូវបានបង្កើតឡើងដោយយោងតាមសេចក្តីត្រូវការចាំបាច់។ ការបង្កើត ការលុបចោល និងការកែប្រែតុលាការជំនាញ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។ តុលាការជំនាញនីមួយៗរបស់សាលាដំបូងចេញសេចក្តីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងនាមសាលាដំបូងដែលតុលាការជំនាញនោះស្ថិតនៅ។ ប៉ុន្តែដោយបច្ចុប្បន្នតុលាការជំនាញនៅមិនទាន់ត្រូវបានបង្កើតឡើង, ចៅក្រមនៃសាលាដំបូងរាជធានី-ខេត្ត មានសមត្ថកិច្ចលើរាល់រឿងក្តីទាំងអស់។

សាលាដំបូងរាជធានី-ខេត្តនីមួយៗ មានសមត្ថកិច្ចជំនុំជម្រះគ្រប់រឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនលើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យសាលាជម្រះក្តីផ្សេងទៀត។ ប៉ុន្តែ ក្នុងករណីចាំបាច់ដើម្បីធានានូវផលប្រយោជន៍សាធារណៈ សុវត្ថិភាពសន្តិសុខសង្គម និងដំណើរការល្អនៃយុត្តិធម៌តុលាការ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចសម្រេចផ្ទេរសមត្ថកិច្ចក្នុងការចាត់ការរឿងក្តីពីសាលាដំបូងមួយទៅសាលាដំបូងមួយទៀតបាន[5]។ ទន្ទឹមនេះដើម្បីធានាដំណើរការល្អនៃយុត្តិធម៌ សាលាដំបូងមួយក៏អាចផ្ទេរសមត្ថកិច្ចទៅអោយសាលាដំបូងមួយទៀតបានដែរ ដោយអនុវត្តស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ជាធរមានផ្សេងទៀត។ ក្នុង ករណីមានវិវាទសមត្ថកិច្ចរវាងតុលាការជំនាញផ្សេងៗនៅក្នុងសាលាដំបូង ប្រធានសាលាដំបូងត្រូវកោះប្រជុំតុលាការជំនាញដែលពាក់ព័ន្ធដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬតាមសំណើរបស់ប្រធានតុលាការជំនាញណាមួយ ដើម្បីសម្រេចអំពីសមត្ថកិច្ច។ ប្រធានសាលាដំបូង សម្រេចលើវិវាទនេះដោយដីកាសម្រេច។ ដីកាសម្រេចនេះ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

3. មាត្រា ១២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
4. មាត្រា ៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
5. មាត្រា ១៩ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

សមាសភាពរបស់សាលាដំបូងរាជធានី-ខេត្តនីមួយៗ រួមមាន ប្រធាន អនុប្រធាន ចៅក្រមក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ព្រមទាំងអាចមានមន្ត្រីជំនាញច្បាប់ផ្សេងទៀត[6]។ ប្រធានសាលាដំបូងមានអំណាចហ៊ានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើប្រធានតុលាការជំនាញទាំងអស់នៃសាលាដំបូងនោះ។ ប្រធានតុលាការជំនាញនីមួយៗ មានអំណាចហ៊ានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើចៅក្រមដែលជាសមាជិក។ ប្រធានសាលាដំបូង មិនអាចធ្វើជាប្រធានតុលាការជំនាញណាមួយបានឡើយ។ ប្រធានតុលាការជំនាញនីមួយៗអាចធ្វើជាប្រធានតុលាការជំនាញបានតែមួយគត់នៃសាលាដំបូងនោះ។

ការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណី នៅសាលាដំបូង អាចធ្វើឡើងដោយចៅក្រមទោល ឬក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុលោមទៅតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ និងនីតិវិធីរដ្ឋប្បវេណីជាធរមាន[7]។

ការជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម នៅសាលាដំបូងត្រូវធ្វើឡើងដោយចៅក្រម៣រូបនិងអមដោយទីប្រឹក្សា ២រូប ជាពាណិជ្ជករ ឬជាអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្ម ក្នុងរឿងក្តីពាណិជ្ជកម្មដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃចាប់ពី១ពាន់លានរៀលឡើងទៅ។ រឿងក្តីពាណិជ្ជកម្មដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃពី ១០០លានរៀល ដល់ក្រោម ១ពាន់លានរៀល ត្រូវជំនុំជម្រះដោយមានចៅក្រម ១រូប និងអមដោយទីប្រឹក្សាពាណិជ្ជកម្ម ២ រូប។ ចំណែករឿងក្តីពាណិជ្ជកម្មដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃក្រោមមួយរយលានរៀលត្រូវជំនុំជម្រះដោយចៅក្រម១រូបដោយមិនចាំបាច់មានការចូលរួមពីទីប្រឹក្សាពាណិជ្ជកម្ម។ ក្នុងករណីជំនុំជម្រះដោយមានទីប្រឹក្សាពាណិជ្ជកម្មសាលក្រម ត្រូវសម្រេចដោយចៅក្រម ក្រោយពេលបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាពាណិជ្ជកម្ម។ ទីប្រឹក្សាពាណិជ្ជកម្មត្រូវចូលមកបំពេញមុខងាររបស់ខ្លួនតាមការអញ្ជើញរបស់ប្រធានតុលាការពាណិជ្ជកម្មនៃសាលាដំបូង ហើយមិនបំពេញមុខងារជាអចិន្ត្រៃយ៍ឡើយ[8]។

ការជំនុំជម្រះរឿងក្តីការងារនៅសាលាដំបូងត្រូវធ្វើឡើងដោយចៅក្រម១រូបនិងអមដោយទីប្រឹក្សាការងារ ២រូប ដែល ១រូប ជាកម្មករនិយោជិត និង ១រូបទៀតជានិយោជក។ សាលក្រមត្រូវសម្រេចដោយចៅក្រមក្រោយពេលបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាការងារ។ទីប្រឹក្សាការងារ ត្រូវចូលមកបំពេញមុខងាររបស់ខ្លួន តាមការអញ្ជើញរបស់ប្រធានតុលាការការងារនៃសាលាដំបូង ហើយមិនបំពេញមុខងារជាអចិន្ត្រៃយ៍ឡើយ[9]។

6. មាត្រា ១៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
7. មាត្រា ២០ កថាខណ្ឌទី២ និងមាត្រា ២១ កថាខ័ណ្ឌទី២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
8. មាត្រា ២៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
9. មាត្រា ២៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

នៅតាមសាលាដំបូងរាជធានី-ខេត្តនីមួយៗ ប្រធានសាលាដំបូងត្រូវចាត់តាំងឱ្យមានចៅក្រមស៊ើបសួរយ៉ាងតិច២រូបដែលមានសមត្ថកិច្ចស៊ើបសួរក្នុងសំណុំរឿងព្រហ្មទណ្ឌ។ការចាត់តាំងចៅក្រមស៊ើបសួរត្រូវធ្វើឡើងដោយដីកាសម្រេច ហើយនៅក្នុងដីកាសម្រេចត្រូវមានចែងកំណត់អំពីលំដាប់លេខរៀង សម្រាប់ការទទួលបំពេញការងារដោយចៅក្រមស៊ើបសួរនីមួយៗ[10]។

(២)-អយ្យការអមសាលាដំបូង

នៅតាមសាលាដំបូងនីមួយៗ មានអយ្យការអមសាលាដំបូង ដែលមានសមាសភាព ដូចជាៈ ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ព្រមទាំងអាចមានមន្ត្រីជំនាញច្បាប់ផ្សេងទៀត[11]។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ។ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានតែអង្គការអយ្យការទេដែលមានសិទ្ធិអំណាចផ្តាច់មុខក្នុងការធ្វើបណ្តឹងអាជ្ញា[12]។ អយ្យការមានមុខងារធ្វើបណ្តឹងអាជ្ញា និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងមុខងារផ្សេងទៀតតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន[13]។

អង្គការអយ្យការ គឺជាអង្គអវិភាគ។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងឱ្យអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ។ ព្រះរាជអាជ្ញារង ចូលរួមអនុវត្តមុខងាររបស់អយ្យការក្រោមការដឹកនាំនិងទទួលខុសត្រូវរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញា មានអំណាចគ្រប់គ្រងលើព្រះរាជអាជ្ញារងទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានអំណាចចាត់តាំង និងបែងចែកការងារដល់ព្រះរាជអាជ្ញារង ព្រមទាំងមានសិទ្ធិធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានរបស់ឆន្ទានុសិទ្ធិរបស់ខ្លួន។ សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារង ត្រូវតែបញ្ជូនទៅព្រះរាជអាជ្ញាពិនិត្យមុនពេលសវនាការ ប៉ុន្តែ នៅពេលសវនាការ ព្រះរាជអាជ្ញារងអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរីតាមការយល់ឃើញស្របទៅនឹងសតិសម្បជញ្ញៈរបស់ខ្លួន។គ្មានការចោទប្រកាន់ខាងវិន័យណាមួយ អាចធ្វើចំពោះតំណាងអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននៅពេលសវនាការ ខុសពីសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនោះឡើយ[14]។

10. មាត្រា ២០ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
11. មាត្រា ២៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
12. មាត្រា ១៣១ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
13. មាត្រា ៣០ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

ខ-តុលាការយោធា និងអយ្យការយោធា

(១)-តុលាការយោធា

តុលាការយោធា គឺមានតែមួយគត់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ និងមានសមត្ថកិច្ចលើគ្រប់រឿងក្តីទូទាំងប្រទេស ពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈជាយោធា[15] ដែលប្រព្រឹត្តដោយយោធិន។ បទល្មើសដែលមានលក្ខណៈយោធា (បទល្មើសយោធា) សំដៅដល់គ្រប់អំពើដែលធ្វើឱ្យប៉ះពាល់ដល់កម្លាំងប្រយុទ្ធរបស់កងកម្លាំងប្រដាប់អាវុធ បទបញ្ជាយោធា និងគ្រឿងអាវុធ និងគ្រឿងបរិក្ខាយោធា។ តុលាការយោធាដឹកនាំដោយប្រធាន ១រូប ព្រមទាំងអនុប្រធាន និងចៅក្រមមួយចំនួនជាជំនួយការ។ ប្រធាន អនុប្រធាន និងចៅក្រមតុលាការយោធា និងតំណាងអយ្យការយោធាត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងការពារជាតិ។នៅពេលជំនុំជម្រះ ក្រុមប្រឹក្សាជំនុំជម្រះ មានចៅក្រមម្នាក់ជាប្រធាន និងមានយោធិន ២ នាក់ជាទីប្រឹក្សា។ ទីប្រឹក្សាយោធា មានសិទ្ធិស្មើនឹងចៅក្រម។ ទីប្រឹក្សាយោធា ត្រូវបានជ្រើសរើសដោយអង្គការទទួលបន្ទុកកិច្ចការនយោបាយនៃកងទ័ព។ ក្រុមប្រឹក្សាជំនុំជម្រះ ធ្វើការសម្រេចជាសមូហភាព និងតាមមតិភាគច្រើន។

(២)-អយ្យការអមតុលាការយោធា

នៅអមតុលាការយោធា មានអយ្យការយោធា ដែលមានតួនាទីភារកិច្ចស៊ើបអង្កេត និងចោទប្រកាន់ជនល្មើសមានលក្ខណៈយោធានៅចំពោះមុខតុលាការយោធាកសាងសំណុំរឿងលើយោធិនទូទាំងកងយោធពលខេមរភូមិន្ទ ដែលមានបទល្មើសយោធា និងមានសិទ្ធិត្រួតពិនិត្យលើការជំនុំជម្រះរបស់តុលាការយោធា ព្រមទាំងធ្វើបណ្តឹងឧទ្ធរណ៍[16]។ តុលាការយោធា និងអយ្យការយោធាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិ។ សេចក្តីសម្រេចរបស់តុលាការយោធាអាចត្រូវបានប្តឹងជំទាស់ទៅកាន់សាលាឧទ្ធរណ៍ភ្នំពេញ ហើយសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍លើបណ្តឹងនេះ អាចត្រូវបានប្តឹងសាទុក្ខទៅកាន់តុលាការកំពូល។

២.តុលាការជាន់ខ្ពស់

យោងតាមមាត្រា ៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ សាលាដំបូង គឺជាសាលាជម្រះក្តីជាន់ទាប ចំណែកសាលាឧទ្ធរណ៍ និងតុលាការកំពូល ជាសាលាជម្រះក្តីជាន់ខ្ពស់។

15. មាត្រា ១១ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការពារជាតិ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០
16. មាត្រា ១២ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការពារជាតិ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០

ក-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍

(១)-សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍ ជាសាលាជម្រះក្តីថ្នាក់ទី២ ដែលមានសមត្ថកិច្ចជំនុំជម្រះ និងសម្រេចសេចក្តី ទាំងអង្គហេតុ និងអង្គច្បាប់ លើរឿងក្តីដែលត្រូវបានប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចរបស់សាលាដំបូង និងសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកឱ្យជំនុំជម្រះឡើងវិញ។ សាលាឧទ្ធរណ៍ រួមមាន សាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់។ ការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់នីមួយៗ និងការកំណត់សមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍តំបន់នេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។ បច្ចុប្បន្ន សាលាឧទ្ធរណ៍តំបន់ ដែលត្រូវបានដាក់ឱ្យដំណើរការមានចំនួន៣ រួមមាន សាលាឧទ្ធរណ៍ព្រះសីហនុ សាលាឧទ្ធរណ៍បាត់ដំបង និងសាលាឧទ្ធរណ៍ត្បូងឃ្មុំ។

សាលាឧទ្ធរណ៍ភ្នំពេញ មានទីតាំងស្ថិតនៅរាជធានីភ្នំពេញ និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតក្នុងសមត្ថកិច្ចដែនដីនៃសាលាដំបូងរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ព្រមទាំងរឿងក្តីផ្សេងទៀតដែលមិនស្ថិត នៅក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍តំបន់[17]។

សាលាឧទ្ធរណ៍ព្រះសីហនុ មានទីតាំងស្ថិតនៅក្នុងខេត្តព្រះសីហនុ និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាដំបូងខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត និងខេត្តកែប[18]។

សាលាឧទ្ធរណ៍បាត់ដំបង មានទីតាំងស្ថិតនៅក្នុងខេត្តបាត់ដំបង និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាដំបូងខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប[19] ។

សាលាឧទ្ធរណ៍ត្បូងឃ្មុំ មានទីតាំងស្ថិតនៅក្នុងខេត្តត្បូងឃ្មុំ និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាដំបូងខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី[20]។

សមាសភាពរបស់សាលាឧទ្ធរណ៍នីមួយៗរួមមាន ប្រធានអនុប្រធាន ចៅក្រម ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ព្រមទាំងអាចមានមន្ត្រីជំនាញច្បាប់ផ្សេងទៀត[21]។

17. មាត្រា ២ កថាខណ្ឌទី ៤ នៃព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០
18. មាត្រា ២ កថាខណ្ឌទី ១ នៃព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០
19. មាត្រា ២ កថាខណ្ឌទី ២ នៃព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០
20. មាត្រា ២ កថាខណ្ឌទី ៣ នៃព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០
21. មាត្រា ៣៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

សាលាឧទ្ធរណ៍ មានសភាជំនាញ ដូចខាងក្រោម៖

- **សភាព្រហ្មទណ្ឌ** មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូង និងរឿងក្តីផ្សេងទៀតដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។
- **សភារដ្ឋប្បវេណី** មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នឹងសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូងក្នុងរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីផ្សេងទៀតដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្ត ជាធរមាន។
- **សភាស៊ើបសួរ** មានសមត្ថកិច្ចដោះស្រាយលើបណ្តឹងនានាចំពោះកិច្ចស៊ើបសួរ ឬដីកាសម្រេចនានារបស់ចៅក្រមស៊ើបសួរ និងរឿងក្តីផ្សេងទៀតដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។
- **សភាពាណិជ្ជកម្ម** មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នឹងសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូងក្នុងរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីផ្សេងទៀតដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។
- **សភាការងារ** មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នឹងសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូងក្នុងរឿងក្តីការងារ និងរឿងក្តីផ្សេងទៀតដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។
- ក្នុងករណីចាំបាច់ សភាជំនាញផ្សេងទៀតអាចត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ។

សភានីមួយៗនៃសាលាឧទ្ធរណ៍ជំនុំជម្រះរឿងក្តី និងចេញសេចក្តីសម្រេចដោយមានចៅក្រម ៣រូប ដែល ១រូបជាប្រធាន[22]។ ចំពោះរឿងក្តីដែលតុលាការកំពូលបានបង្វិលមកវិញ សាលាឧទ្ធរណ៍ ត្រូវជំនុំជម្រះនៅក្នុងសវនាការមួយដោយមានចៅក្រម ៥ រូប ហើយសុទ្ធតែជាចៅក្រមដែលមិនបានចូលជំនុំជម្រះលើកមុន[23]។

ចំពោះការជំនុំជម្រះរឿងក្តីនៅសភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ ក្រៅពីចៅក្រម ៣ រូប ត្រូវមានអមដោយទីប្រឹក្សាពាណិជ្ជកម្ម២រូប ដែលមិនមែនជាទីប្រឹក្សាពាណិជ្ជកម្មនៅក្នុងរឿងក្តីតែមួយនៅសាលាដំបូង[24]។ ចំណែកការជំនុំជម្រះរឿងក្តីនៅសភាការងារនៃសាលាឧទ្ធរណ៍ ក្រៅពីចៅក្រម ៣រូប ត្រូវមានអមដោយទីប្រឹក្សា ២រូប ដែល ១រូប ជាកម្មករនិយោជិត និង ១រូបទៀត ជានិយោជក ហើយទីប្រឹក្សាទាំង ២រូបនេះ មិនមែនជាទីប្រឹក្សាការងារនៅក្នុងរឿងក្តីតែមួយនៅសាលាដំបូង[25]។

22. មាត្រា ៣៧ និងមាត្រា ៣៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
23. មាត្រា ៣៩ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
24. មាត្រា ៤១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
25. មាត្រា ៤៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

សភារួមក្រុមអាចត្រូវបានបង្កើតឱ្យមានដំណើរការបានដោយដីកាសម្រេចរបស់ប្រធានសាលាឧទ្ធរណ៍ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយ។ សភារួមក្រុមនេះអាចត្រូវបានបង្កើតឡើងក្នុងករណីដែលរឿងក្តីណាមួយចោទជាបញ្ហាដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើនឬក្នុងករណីដែលបញ្ហានោះបានទទួលនូវដំណោះស្រាយខ្វែងគ្នានៅចំពោះមុខសភាផ្សេង គ្នានៃសាលាឧទ្ធរណ៍តែមួយ។ សភារួមក្រុម ត្រូវមានសមាសភាពជាចៅក្រមយ៉ាងតិច ៥រូប ដែលបែងចែកស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាពាក់ព័ន្ធ។សភារួមក្រុមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានសាលាឧទ្ធរណ៍និងត្រូវដំណើរការក្រោមអធិបតីភាពរបស់ប្រធានសាលាឧទ្ធរណ៍។ សេចក្តីសម្រេចរបស់សភារួមក្រុមអំពីសមត្ថកិច្ចរវាងសភាផ្សេងៗ និងវិវាទច្បាប់ មានអំណាចបង្ខំឱ្យសភាទាំងអស់នៃសាលាឧទ្ធរណ៍គោរពតាម។សេចក្តីសម្រេចរបស់សភារួមក្រុមលើវិវាទសមត្ថកិច្ចនិងវិវាទច្បាប់ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

(២)-មហាអយ្យការអមសាលាឧទ្ធរណ៍

នៅតាមសាលាឧទ្ធរណ៍នីមួយៗ មានមហាអយ្យការអមសាលាឧទ្ធរណ៍ ដែលមានសមាសភាពដូចតទៅ៖ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ព្រមទាំងអាចមានមន្ត្រីជំនាញច្បាប់ផ្សេងទៀត[26]។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដោយមានសិទ្ធិអំណាចចាត់តាំង និងបែងចែកការងារដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាទាំងអស់នៅក្នុងសាលាឧទ្ធរណ៍របស់ខ្លួន។ សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជ អាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ពិនិត្យមុនពេលសវនាការ ប៉ុន្តែនាពេលសវនាការ អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរីតាមការដែលខ្លួនយល់ឃើញថាស្របទៅនឹងសតិសម្បជញ្ញៈរបស់ខ្លួន។គ្មានការចោទប្រកាន់ខាងវិន័យណាមួយអាចត្រូវធ្វើចំពោះតំណាងមហា អយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការខុសពីសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនោះឡើយ[27]។

ក្រៅពីសិទ្ធិអំណាចគ្រប់គ្រងទៅលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក៏មានសិទ្ធិធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញាអមសាលាដំបូងដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួនធ្វើការចោទប្រកាន់ដោយអនុវត្តតាមបទបញ្ជត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន[28]។

26. មាត្រា ៤៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
27. មាត្រា ៥១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
28. មាត្រា ៥១ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

ខ-តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

(១)-តុលាការកំពូល

តុលាការកំពូលជាសាលាជម្រះក្តីថ្នាក់ខ្ពស់បំផុត។តុលាការកំពូលមានតែមួយគត់ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ហើយមានសមត្ថកិច្ចគ្របដណ្តប់លើដែនដីនៃប្រទេសកម្ពុជាទាំងមូល។ តុលាការកំពូល មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ឬចំពោះសាលក្រមសាលាដំបូងនៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរមិនប្តឹងឧទ្ធរណ៍ឬនៅក្នុងករណីដែលសាលក្រមសាលាដំបូងវិនិច្ឆ័យលើរឿងក្តីដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃមិនលើសពី៥លានរៀល[29]។សមាសភាពរបស់តុលាការកំពូលរួមមាន ប្រធាន អនុប្រធាន ចៅក្រម ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ព្រមទាំងអាចមានមន្ត្រីជំនាញច្បាប់ផ្សេងទៀត[30]។

តុលាការកំពូល ត្រូវបែងចែកជា សភាព្រហ្មទណ្ឌ សភារដ្ឋប្បវេណី សភាពាណិជ្ជកម្ម និងសភាការងារ។ ក្នុងករណីចាំបាច់ សភាជំនាញផ្សេងទៀតរបស់តុលាការកំពូល អាចត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ។ សភានីមួយៗ ចេញសេចក្តីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងនាមតុលាការកំពូល។ ចំពោះបណ្តឹងសាទុក្ខលើកទី១ សភានីមួយៗនៃតុលាការកំពូលជំនុំជម្រះនឹងចេញសេចក្តីសម្រេចដោយមានចៅក្រម ៥រូប ដែល ១រូប ជាប្រធាន[31]ដោយអនុលោមតាមបទបញ្ជត្តិស្តីពីនីតិវិធីជាធរមាន។ ចំពោះបណ្តឹងសាទុក្ខលើកទី១ តុលាការកំពូលជំនុំជម្រះ នឹងសម្រេចសេចក្តីទៅលើអង្គច្បាប់តែប៉ុណ្ណោះ។ ក្នុងការជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី ១ នេះ, តុលាការកំពូល អាចសម្រេចតម្កល់ឬបដិសេធសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ហើយសម្រេចសេចក្តីតែម្តង ក្នុងករណីដែលតុលាការកំពូលយល់ថា សាលាឧទ្ធរណ៍បានកំណត់ចំណុចវិវាទច្បាស់លាស់ និងបានវិនិច្ឆ័យអំពីអង្គហេតុច្បាស់លាស់ហើយ។ ដោយឡែក ក្នុងករណីដែលពិនិត្យឃើញថា សាលាឧទ្ធរណ៍នៅមិនទាន់បានវិនិច្ឆ័យច្បាស់លាស់អំពីចំណុចវិវាទ ឬអំពីអង្គហេតុ,តុលាការកំពូលអាចសម្រេចបដិសេធសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍និងបង្ហិលសំណុំរឿងឱ្យទៅសាលាឧទ្ធរណ៍ជំនុំជម្រះឡើងវិញ។

ចំពោះបណ្តឹងសាទុក្ខលើកទី២ បណ្តឹងសើរើ ឬបណ្តឹងសុំជំនុំជម្រះសាជាថ្មីឡើងវិញ ចំពោះសាលក្រម និងសាលដីកាស្តាពរ តុលាការកំពូលជំនុំជម្រះ នឹងចេញសេចក្តីសម្រេចដោយសភាពេញអង្គ ដែលមានសមាសភាពចៅក្រមយ៉ាងតិច ៩រូប ដែលមានចៅក្រមជាតំណាងនៃ

29. មាត្រា ២៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី
30. មាត្រា ៥៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
31. មាត្រា ៥៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

សភាទាំងអស់របស់តុលាការកំពូល ហើយត្រូវដំណើរការក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល[32]។ ករណីនេះ តុលាការកំពូលជំនុំជម្រះ នឹងសម្រេចសេចក្តីទាំងអង្គហេតុ និងអង្គច្បាប់។ ដោយឡែកតុលាការកំពូលក៏អាចបង្កើតជាសភារួមក្រុម ដោយសេចក្តីសម្រេចរបស់ប្រធានតុលាការកំពូល តាមគំនិតផ្តួចផ្តើមរបស់ប្រធានតុលាការកំពូល ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយ កាលណាមានរឿងក្តីណាមួយចោទជាបញ្ហាដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើនឬប្រសិនបើបញ្ហានោះបានទទួលនូវដំណោះស្រាយខ្វែងគ្នានៅចំពោះមុខសភាផ្សេងគ្នានៃតុលាការកំពូល។ សភារួមក្រុមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល។ សេចក្តីសម្រេចរបស់សភារួមក្រុមអំពីសមត្ថកិច្ចរវាងសភាផ្សេងៗ និងវិវាទអំពីច្បាប់ មានអំណាចបង្ខំសភាទាំងអស់នៃតុលាការកំពូល និងតុលាការថ្នាក់ក្រោមគោរពតាម។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទច្បាប់ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

(២)-មហាអយ្យការអមតុលាការកំពូល

នៅអមតុលាការកំពូលមានមហាអយ្យការមួយ ដែលមានសមាសភាពដូចតទៅ៖ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ព្រមទាំងអាចមានមន្ត្រីជំនាញច្បាប់ផ្សេងទៀត[33]។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និង ព្រះរាជអាជ្ញាអមតុលាការកំពូល មានអំណាចចាត់តាំង និងបែងចែកការងារដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាទាំងអស់នៅមហាអយ្យការអមតុលាការកំពូល។ សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលពិនិត្យមុនពេលសវនាការ ប៉ុន្តែនាពេលសវនាការអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរីតាមការដែលខ្លួនយល់ឃើញថាស្របទៅនឹងសតិសម្បជញ្ញៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយ អាចត្រូវធ្វើចំពោះតំណាងមហាអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការ ខុសពីសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនោះឡើយ[34]។

៣. អង្គភាពរដ្ឋបាលតុលាការ

ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ២០១៤ បានបង្កើតឱ្យមានអង្គភាពរដ្ឋបាលតុលាការមួយនៅតាមគ្រប់សាលាជម្រះក្តីនានា ទាំងសាលាដំបូងរាជធានី-ខេត្ត ទាំងសាលាឧទ្ធរណ៍ និងទាំងតុលាការកំពូល។ អង្គភាពរដ្ឋបាលតុលាការ គឺជាអង្គភាពថ្មីស្រឡាងមួយ ដែលមិនធ្លាប់មាននៅក្នុងប្រវត្តិច្បាប់ខ្មែរ ហើយការបង្កើតអង្គភាពរដ្ឋបាលតុលាការនេះគឺជាសមិទ្ធផលដ៏ចម្បងមួយនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃសេវាយុត្តិធម៌។ អង្គភាពរដ្ឋបាលតុលាការនេះ ជាសេនាធិការឱ្យសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី លើការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ការងារទំនាក់ទំនងសាធារណៈ និងការងារគ្រប់គងរដ្ឋបាលតុលាការ ជាអាទិ៍ ការងារទទួលពាក្យបណ្តឹង និងការគ្រប់គ្រងសំណុំរឿង និងវឌ្ឍនភាពនៃពាក្យបណ្តឹង និងការងារផ្សេងទៀតតាមការកំណត់របស់លិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គភាពរដ្ឋបាលតុលាការនេះបានជួយសម្រាលបន្ទុកការងាររបស់ក្រឡាបញ្ជីនិងរបស់ប្រធានសាលាជម្រះក្តីនីមួយៗដោយអនុញ្ញាតឱ្យចៅក្រម ព្រះរាជអាជ្ញានិងក្រឡាបញ្ជីផ្តោតការយកចិត្តទុកដាក់ខ្ពស់តែលើការងារបច្ចេកទេសសំណុំរឿងសំដៅធ្វើយ៉ាងណាឱ្យការជំនុំជម្រះក្តីអាចធ្វើឡើងបានលឿនត្រឹមត្រូវនិងយុត្តិធម៌ស្របតាមច្បាប់និងនីតិវិធីជាធរមាន។ វត្តមានរបស់អង្គភាពរដ្ឋបាលតុលាការក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការ៖ **(១)**-ពន្លឿនការដោះស្រាយសំណុំរឿងក្តីនៅតាមសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី, **(២)**-លើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ ដែលមានលក្ខណៈងាយស្រួលប្រើ និងឆាប់រហ័ស ដោយសារអង្គភាពរដ្ឋបាលតុលាការនេះ បានក្លាយជាច្រកចេញ-ចូលតែមួយសម្រាប់ប្រជាពលរដ្ឋដាក់ពាក្យបណ្តឹង និងទទួលបាននូវព័ត៌មានអំពីវឌ្ឍនភាពនៃចំណាត់ការលើពាក្យបណ្តឹងរបស់ខ្លួន, **(៣)**-លើកកម្ពស់ប្រសិទ្ធភាពនៃការចុះបញ្ជី និងការគ្រប់គ្រងសំណុំរឿង និង **(៤)**-លើកកម្ពស់ប្រសិទ្ធភាពនៃការងារនាំពាក្យ និងទំនាក់ទំនងសាធារណៈ។

អង្គភាពរដ្ឋបាលតុលាការ ត្រូវបានបែងចែកជា **លេខាធិការដ្ឋានរដ្ឋបាលតុលាការ** សម្រាប់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត និង **អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការ** សម្រាប់សាលាឧទ្ធរណ៍និងតុលាការកំពូល។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពរដ្ឋបាល តុលាការ ត្រូវកំណត់ដោយអនុក្រឹត្យ។ អង្គភាពរដ្ឋបាលតុលាការ ស្ថិតនៅក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ហើយមន្ត្រីរបស់អង្គភាពរដ្ឋបាលតុលាការ គឺជាមន្ត្រីក្របខ័ណ្ឌរបស់ក្រសួងយុត្តិធម៌។ ផ្អែកតាមច្បាប់ ក្រសួងយុត្តិធម៌ មានសិទ្ធិត្រួតពិនិត្យលើកិច្ចការរដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់។ ក្នុងករណីចាំបាច់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចេញលិខិតបទដ្ឋានគតិយុត្តនិងសេចក្តីណែនាំនានាដើម្បីធានាដំណើរការប្រព្រឹត្តទៅល្អប្រសើរនៃការគ្រប់គ្រងរដ្ឋបាលតុលាការគ្រប់ជាន់ថ្នាក់។ ក្រសួងយុត្តិធម៌ គ្រប់គ្រងតែលើការងាររដ្ឋបាលតុលាការប៉ុណ្ណោះ ដោយឡែកការជំនុំជម្រះនិងការសម្រេចសេចក្តីគឺសិទ្ធិសម្រេចស្ម័យភាពនិងដោយឯករាជ្យរបស់ចៅក្រម៕

32. មាត្រា ៦២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
33. មាត្រា ៦៨ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
34. មាត្រា ៥១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

អាជ្ញាធរជាតិ ដោះស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការ



ដោយ៖
-ឯកឧត្តម ញ៉ាន ភល្លៈ រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌
-ឯកឧត្តម តាន់ហ៊ាង ជាវ័ណ្ណ រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌

សេចក្តីផ្តើម

វិវាទរវាងបុគ្គល និងបុគ្គល អាចត្រូវបានដោះស្រាយដោយយន្តការតុលាការ ឬយន្តការផ្សេងទៀតក្រៅពីយន្តការតុលាការ។ ការដោះស្រាយតាមរយៈយន្តការផ្សេងក្រៅពីយន្តការតុលាការនេះ ត្រូវបានកំណត់ថាជា "**ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**"។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះអាចធ្វើឡើងតាមវិធីសាស្ត្រផ្សេងៗដែលរួមមានការចរចា[1]ការផ្សះផ្សា ឬ **ការសម្រុះសម្រួល**[2] និង **អាជ្ញាកណ្តាល** ឬ **មជ្ឈត្តការ**[3] ។ ក្នុងចំណោមវិធីសាស្ត្រទាំងនេះ វិធីសាស្ត្រមួយចំនួនជាវិធីសាស្ត្រដែលដំណោះស្រាយចំពោះវិវាទអាចទទួលបាន ដោយផ្អែកទាំងស្រុងលើការព្រមព្រៀងរបស់ភាគីវិវាទ ទោះដោយមាន ឬគ្មានជំនួយពីភាគីទី៣ ក៏ដោយ (*ការចរចា,ការផ្សះផ្សាឬការសម្រុះសម្រួល*)ហើយវិធីសាស្ត្រមួយចំនួនទៀតជាវិធីសាស្ត្រដែលដំណោះស្រាយទទួលបានដោយមានការវិនិច្ឆ័យសម្រេចសេចក្តីតាមរបៀបនៃការកាត់ក្តី(*អាជ្ញាកណ្តាល*

1. ***ការចរចា*** (negotiation) ជាទម្រង់ដំសាមញ្ញបំផុតនៃដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ការចរចាអាចធ្វើឡើងដោយផ្ទាល់រវាងភាគីវិវាទឬតាមរយៈអ្នកតំណាងរបស់ភាគីវិវាទ។ភាគីលើកសំណើដំណោះស្រាយជាមួយគ្នាទៅវិញទៅមករហូតដល់សម្រេចបាននូវការព្រមព្រៀងគ្នាលើសំណើដំណោះស្រាយណាមួយ ដែលនាំឱ្យឈានដល់ការបញ្ចប់វិវាទ។ ជាទូទៅ ការចរចានេះ គឺជាជម្រើសដំបូងដ៏ល្អបំផុត និងវិធីសាស្ត្រដែលមានការពេញនិយមបំផុត ដោយសារជាវិធីសាស្ត្រដែលលឿន ហើយភាគីគ្រប់គ្រងបានទាំងស្រុងលើដំណើរការចរចា, លទ្ធផលនៃការចរចាមានភាពបត់បែនខ្ពស់ទៅតាមឆន្ទៈរបស់ភាគីវិវាទនិងងាយស្រួលក្នុងការអនុវត្តព្រមទាំងអាចរក្សាបាននូវការសម្ងាត់របស់ភាគី។ជាធម្មតាមុនទីងសម្រេចប្តឹងផ្តល់គ្នាទៅយន្តការផ្សេងៗសម្រាប់វិនិច្ឆ័យកាត់ក្តី ភាគច្រើនភាគីតែងព្យាយាមសាកល្បងចរចាគ្នាជាមុនសិន ទោះដោយផ្ទាល់ក្តី ទោះតាមរយៈអ្នកតំណាងក្តី។

2. ***ការផ្សះផ្សា*** (conciliation) ***ឬការសម្រុះសម្រួល*** (mediation) ជាវិធីសាស្ត្រក្នុងការដោះស្រាយវិវាទតាមរយៈការចរចាគ្នា ដោយមានជំនួយពីភាគីទី៣ ដែលត្រូវតែមានភាពអព្យាក្រឹតចំពោះភាគីទាំងសងខាង។ ភាគីទី៣ ដែលជាអ្នកគ្រប់គ្រងដំណើរការផ្សះផ្សា ឬសម្រុះសម្រួលវិវាទ មិនមានសិទ្ធិអំណាចចាប់បង្ខំឱ្យភាគីវិវាទទទួលយកនូវដំណោះស្រាយណាមួយនោះទេ។ រាល់ការសម្រេចនៅតែជាសិទ្ធិអំណាចរបស់ភាគីវិវាទ។ ភាគីទី៣ ជាអ្នកសម្របសម្រួលឱ្យភាគីវិវាទជួបជជែកចរចាគ្នា ហើយភាគីទី៣ អាចមានតួនាទីសកម្ម ឬមិនសូវសកម្ម អាស្រ័យទៅលើថាតើវិធីសាស្ត្រនៃការដោះស្រាយនោះជាការផ្សះផ្សាវិវាទឬជាសម្រុះសម្រួលវិវាទ។ ប៉ុន្តែលើការជាក់ស្តែងពាក្យការផ្សះផ្សានិងការសម្រុះសម្រួលនេះត្រូវបានប្រើឡាយឡំគ្នា ទាំងក្នុងក្របខ័ណ្ឌច្បាប់ ទាំងក្នុងការអនុវត្តជាក់ស្តែង។

3. ***មជ្ឈត្តកម្ម ឬ អាជ្ញាកណ្តាល*** (arbitration) គឺជាកិច្ចដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមួយប្រភេទ ដែលធ្វើឡើងដោយភាគីទីបីជាអ្នកអព្យាក្រឹត (មជ្ឈត្តករ ឬអាជ្ញាកណ្តាល) ដែលមានសិទ្ធិសម្រេច និងវិនិច្ឆ័យរកខុសត្រូវចំពោះវិវាទ (ការកាត់ក្តី) បន្ទាប់ពីបានពិនិត្យរង្គហេតុ អង្គច្បាប់ភស្តុតាង និងស្តាប់ការជជែកវែកញែកពីភាគីវិវាទរួចមក។ មជ្ឈត្តកម្ម ឬអាជ្ញាកណ្តាល នេះ តែងត្រូវបានប្រើប្រាស់សម្រាប់វិវាទដែលមានលក្ខណៈស្មុគស្មាញ ជាអាទិ៍ វិវាទការងារ,រួម និងវិវាទពាណិជ្ជកម្ម ជាដើម។

ការងារ និងមជ្ឈត្តការពាណិជ្ជកម្ម)។ ការដោះស្រាយវិវាទតាមរយៈយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ បានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គម ហើយបាននិងកំពុងដើរតួនាទីកាន់តែសំខាន់ឡើងៗនៅក្នុងប្រព័ន្ធយុត្តិធម៌ ទាំងនៅក្នុងប្រព័ន្ធច្បាប់ Civil Law, ប្រព័ន្ធច្បាប់ Common Law និងទាំងប្រព័ន្ធច្បាប់ផ្សេងទៀត ដោយមូលហេតុសំខាន់ៗ ជាអាទិ៍៖ (១)-ជាវិធីសាស្ត្រដោះស្រាយវិវាទ បានឆាប់រហ័ស ជាងការដោះស្រាយតាមប្រព័ន្ធតុលាការដែលអាចត្រូវចំណាយពេលជាច្រើនក្នុងការជំនុំជម្រះក្តីតាំងពីសាលាដំបូងដល់តុលាការកំពូល,(២)-ដំណោះស្រាយតាមយន្តការក្រៅប្រព័ន្ធតុលាការអាចមានភាពបត់បែន និងអាចទទួលយកបានដោយភាគីវិវាទ និងអាចរក្សាបាននូវទំនាក់ទំនងរវាងភាគីវិវាទ ខុសពីការវិនិច្ឆ័យសម្រេចសេចក្តីដែលតែងនាំឱ្យមានភាគីម្ខាងចាញ់ក្តី និងភាគីម្ខាងទៀតឈ្នះក្តី ហើយភាគីវិវាទមិនអាចរក្សាបាននូវទំនាក់ទំនងល្អរវាងគ្នានឹងគ្នាបន្តទៀត, (៣)-ក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ភាគីវិវាទអាចមិនចំណាយប្រាក់ ឬចំណាយតិចជាងការចំណាយសម្រាប់ការដោះស្រាយក្នុងប្រព័ន្ធតុលាការដូចសុភាសិតខ្មែរពោលថា “**ធ្ងន់នឹងថ្ម ក្រនឹងក្តី**” (ចំណាយលើមេធាវីនៅគ្រប់ដំណាក់កាល, ចំណាយលើការធ្វើដំណើរចុះឡើងច្រើនដង ជាដើម), (៤)-ទីតាំងរបស់សាលាជម្រះក្តីអាចនៅឆ្ងាយពីប្រជាពលរដ្ឋ ពិសេស សម្រាប់ប្រជាពលរដ្ឋក្រីក្រ ឬរស់នៅតំបន់ដាច់ស្រយាលដែលមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការមកប្តឹងផ្តល់គ្នានៅតុលាការ,(៥)-វិវាទក្នុងគ្រួសារដែលគួរមានការសម្រុះសម្រួលឱ្យបានច្រើនជាមុន ដើម្បីរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារ រក្សាបាននូវទំនាក់ទំនងញាតិ និងការពារផលប្រយោជន៍របស់កូន, និង (៦)-ចំនួនសំណុំរឿងនៅតុលាការ តែងមានការកើនឡើងជាបន្តបន្ទាប់ ប៉ុន្តែ ចំនួនចៅក្រមជម្រះក្តីនៅមិនទាន់គ្រប់គ្រាន់ដែលធ្វើឱ្យមាននិន្នាការក្នុងការបញ្ជូន ឬតម្រូវឱ្យវិវាទដែលមានលក្ខណៈតូចតាចត្រូវស្វែងរកការផ្សះផ្សាឬការសម្រុះសម្រួលជាមុនសិនដើម្បីទុកលទ្ធភាពឱ្យចៅក្រមផ្តោតការយកចិត្តទុកដាក់លើវិវាទធំៗដែលមានលក្ខណៈស្មុគស្មាញ និងមិនអាចសម្រុះសម្រួលគ្នាបាន។

ផ្អែកលើមូលដ្ឋាន និងសារសំខាន់ខាងលើ ទើបរាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជាសសរស្តម្ភមួយដ៏សំខាន់នៃកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា[4]។ ជាលទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នេះ,

4.ឯកសារ “ការកែទម្រង់ច្បាប់ និងតុលាការ”” ឆ្នាំ២០០៣ ត្រូវបានអនុម័តដោយកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣ ហើយ “កម្មវិធី សកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ”” ត្រូវបាន,អនុម័តដោយកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៥។ ទិសដៅជាយុទ្ធសាស្ត្រនៃការកែទម្រង់ច្បាប់ និងតុលាការ មាន៧ រួមមានៈ (១)-ពង្រឹងការការពារសិទ្ធិ និងសេរីភាពបុគ្គល, (២)-ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់, (៣)-ផ្តល់លទ្ធភាពឱ្យទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការកាន់តែប្រសើរឡើង, (៤)-ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃដំណើរការរឿងក្តី និងសេវាកម្មពាក់ព័ន្ធ (៥)-ពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មផ្នែករដ្ឋបាល, (៦)-បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និង (៧)-ពង្រឹង ស្ថាប័នវិស័យច្បាប់ និងតុលាការឱ្យបំពេញអាណត្តិរបស់ខ្លួនបានសម្រេច។

យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្សេងៗត្រូវបានបង្កើតឡើងជាផ្លូវការជាបន្តបន្ទាប់ដោយច្បាប់ឬលិខិតបទដ្ឋានគតិយុត្តនានា។អាជ្ញាកណ្តាលការងារដែលមានសមត្ថកិច្ចដោះស្រាយវិវាទការងារដែលការផ្សះផ្សាពុំបានសះជាត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ និងប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលឆ្នាំ២០០២[5]។ បន្ទាប់មក នៅឆ្នាំ២០០៦ មជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មសម្រាប់ដោះស្រាយវិវាទពាណិជ្ជកម្មស្របតាមការស្ម័គ្រចិត្តរបស់ភាគីវិវាទ[6]។ ក្រៅពីយន្តការទាំង ២ នេះ មានយន្តការផ្សេងទៀតដែលមានលក្ខណៈរដ្ឋបាល ត្រូវបានបង្កើតឡើងនៅតាមវិស័យនានាផងដែរ ជាអាទិ៍ (១)-អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មការសុរិយោដី សម្រាប់ដោះស្រាយវិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជីដីធ្លី ដែលត្រូវបានបង្កើតឡើងស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១, (២)-គណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម សម្រាប់ផ្សះផ្សាទំនាស់ដែលអាចកើតមានក្នុងអំឡុងពេលអនុវត្តការធ្វើកសិកម្មតាមកិច្ចសន្យា(កិច្ចសន្យាផលិតកម្មកសិកម្ម) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យឆ្នាំ២០១១ ស្តីពីការធ្វើកសិកម្មតាមកិច្ចសន្យា, (៣)-មណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានប្រែក្លាយទៅជាការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានស្ថិតក្រោមរចនាសម្ព័ន្ធរដ្ឋបាលក្រុងស្រុកខណ្ឌនៅទូទាំងប្រទេសកម្ពុជានិង(៤)-មេឃុំ-ចៅសង្កាត់និងក្រុមប្រឹក្សាឃុំ-សង្កាត់សម្រាប់ដោះស្រាយសម្រុះសម្រួលវិវាទគ្រួសារនិងវិវាទរដ្ឋប្បវេណីនៅក្នុងមូលដ្ឋាន។យន្តការទាំងនេះបាននិងកំពុងរួមចំណែកយ៉ាងសំខាន់ក្នុងការដោះស្រាយវិវាទរបស់ប្រជាពលរដ្ឋ។ ប៉ុន្តែ ពេលខ្លះ វិវាទមួយចំនួនដែលត្រូវបានដោះស្រាយបញ្ចប់ដោយយន្តការទាំងនេះបានលាប់ឡើងវិញនៅពេលដែលភាគីម្ខាងមិនគោរពតាមលក្ខខណ្ឌនៃការព្រមព្រៀងគ្នាដែលមានតម្លៃត្រឹមជាកិច្ចព្រមព្រៀង និងមិនមានអានុភាពអនុវត្តតាមផ្លូវតុលាការ ហើយពេលខ្លះ ភាគីមិនសុខចិត្តនៅតែមានសិទ្ធិក្នុងការប្តឹងតវ៉ាបន្តទៅយន្តការតុលាការ។ទន្ទឹមនេះយន្តការមួយចំនួនដែលត្រូវបានបង្កើតឡើងមានសមត្ថកិច្ចដោះស្រាយតែវិវាទមួយចំនួនប៉ុណ្ណោះ ដូចជាវិវាទដីធ្លីវិវាទការងារ ឬវិវាទពាណិជ្ជកម្ម ដែលធ្វើឱ្យវិវាទទូទៅរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានមិនមានយន្តការជាក់លាក់ណាមួយអាចទទួលបន្ទុកដោះស្រាយប្រកបដោយប្រសិទ្ធភាពនៅឡើយទេ។

5. ប្រកាសលេខ ៣៣៨ សកបយ. ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២២ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។
6. ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦។

ផ្អែកលើការវាយតម្លៃនេះ និងដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, **“អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ”** ហៅកាត់ថា **“អ.ដ.ក.”** ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យឆ្នាំ២០២៣[7]។ យោងតាមមាត្រា១ នៃព្រះរាជក្រឹត្យនេះ, អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះគឺជា*“យន្តការបំពេញបន្ថែមឱ្យប្រព័ន្ធដោះស្រាយវិវាទនៅព្រះរាជាណាចក្រកម្ពុជាសំដៅលើកកម្ពស់គុណភាពប្រសិទ្ធភាពនិងភាពឆាប់រហ័សនៃការដោះស្រាយវិវាទ តាមរយៈការសម្រុះសម្រួលផ្សះផ្សាក្រៅប្រព័ន្ធតុលាការ ក្នុងគោលបំណងជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះក្តី បង្កើតសេវាដោះស្រាយវិវាទឱ្យកាន់តែទៅកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាននិងធានាបាននូវភាពសុខដុមរមនានិងយុត្តិធម៌ក្នុងសង្គមជាតិ”*។ ផ្អែកតាមមាត្រានេះ យើងអាចកត់សម្គាល់បាននូវចំណុចសំខាន់ចំនួន ២ គឺ៖

- យន្តការ **អ.ដ.ក.** នេះ ជាយន្តការថ្មីមួយដែលបំពេញបន្ថែមឱ្យយន្តការដោះស្រាយវិវាទដែលមានស្រាប់ និងមិនជំនួសយន្តការដែលមានស្រាប់នោះទេ។ ការបង្កើតយន្តការនេះ នឹងផ្តល់ជាជម្រើសថ្មីមួយដែល*“**កាន់តែងាយស្រួល,កាន់តែសម្បូរបែប,កាន់តែទិតជិតប្រជាពលរដ្ឋនៅមូលដ្ឋាន និងកាន់តែមានប្រសិទ្ធភាពក្នុងការដោះស្រាយវិវាទ**”* ជូនប្រជាពលរដ្ឋ ដែលមានបំណងស្វែងរកការសម្រុះសម្រួលដោះស្រាយបញ្ហាប់វិវាទរបស់ខ្លួនឱ្យបានឆាប់។ ប្រជាពលរដ្ឋមានជម្រើសក្នុងការប្រើប្រាស់យន្តការថ្មីនេះ ឬយន្តការដែលមានស្រាប់ ដើម្បីដោះស្រាយវិវាទរបស់ខ្លួនដោយគ្មានការបង្ខិតបង្ខំ។

- ការបង្កើតនូវ **អ.ដ.ក.** មានគោលបំណងសំខាន់ចំនួន ៣។ ទី១-គឺការជួយកាត់បន្ថយការកកស្ទះសំណុំរឿងក្តីនៅតាមសាលាជម្រះក្តី។ ទី២-គឺការបង្កើតសេវាដោះស្រាយវិវាទឱ្យកាន់តែទៅកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន។ ទី៣-គឺការសម្រុះសម្រួលដោះស្រាយវិវាទដោយ **អ.ដ.ក.** នឹងធានាបាននូវភាពសុខដុមរមនា និងយុត្តិធម៌ក្នុងសង្គមជាតិ។

តើ **អ.ដ.ក.** ត្រូវបានបង្កើតឡើងដោយផ្អែកលើមូលដ្ឋានអ្វីខ្លះ? និងតើការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌ **អ.ដ.ក.** ដំណើរការយ៉ាងដូចម្តេច, ត្រូវគោរពតាមគោលការណ៍អ្វីខ្លះ ហើយលទ្ធផលសះជានៃកាសម្រុះសម្រួលផ្សះផ្សាវិវាទនេះមានអានុភាពគតិយុត្តយ៉ាងដូចម្តេច?

I- ការបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ការបង្កើតនូវអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ ត្រូវបានរៀបចំដោយផ្អែកលើមូលដ្ឋានសំខាន់ៗចំនួន ៣ គឺ៖ (១)-មូលដ្ឋានផ្នែកគោលនយោបាយ, (២)-មូលដ្ឋានផ្នែកច្បាប់ និង (៣)-មូលដ្ឋានផ្នែកសង្គម។

7.ព្រះរាជក្រឹត្យលេខនស/រកត/១១២៣/២៣៨១ចុះថ្ងៃទី២ខែវិច្ឆិកាឆ្នាំ២០២៣ស្តីពីការបង្កើតការរៀបចំនិងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

១-មូលដ្ឋានផ្នែកគោលនយោបាយ

លើទិដ្ឋភាពគោលនយោបាយ, ព្រះរាជក្រឹត្យបង្កើត**អ.ដ.ក.** ត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានសំខាន់ចំនួន ២ គឺ៖ **(ទី១)-“យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១”** របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា និង **(ទី២)-“វិធានការគន្លឹះជាអាទិភាពទាំង ៥”** របស់**សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**ដែលទាំង**“យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១”** ទាំង**“វិធានការគន្លឹះជាអាទិភាពទាំង៥”** នេះត្រូវបាន**សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ កន្លងទៅ។

ផ្អែកតាម **“យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១”**, សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភានេះ, រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** នៅតែបានបន្តចាត់ទុក **“ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌”** ជាអាទិភាពមួយដ៏សំខាន់របស់ខ្លួនសំដៅពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្នុងចក្ខុវិស័យដើម្បីពង្រឹង និងលើកកម្ពស់ “គោលការណ៍នីតិរដ្ឋ” និង “យុត្តិធម៌នៅក្នុងសង្គម” ដែលជាកត្តាសំខាន់ និងចាំបាច់ក្នុងការរួមចំណែកធានាថែរក្សាស្ថិរភាពសង្គម សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។ **“ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌”** ត្រូវបានរៀបចំជាមុំមួយក្នុងចំណោមមុំទាំង៥ដែលបង្កើតបានជាស្នូលនៃ**“យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១“** របស់រាជរដ្ឋាភិបាល ហើយចំណុចទី៦ ក្នុងមុំទី៤ នៃស្នូល**“យុទ្ធសាស្ត្របញ្ចកោណ“**នេះ,រាជរដ្ឋាភិបាលបានដាក់ចេញជាទិសដៅអាទិភាពគឺការរៀបចំនូវក្របខ័ណ្ឌច្បាប់ និងយន្តការសម្រុះសម្រួល និងផ្សះផ្សាវិវាទ ទាំងក្នុងប្រព័ន្ធតុលាការ ទាំងក្រៅប្រព័ន្ធតុលាការ សំដៅលើកកម្ពស់ប្រសិទ្ធភាព និងភាពឆាប់រហ័សនៃការដោះស្រាយវិវាទ, បង្កើតសេវានៃការដោះស្រាយវិវាទដែលមានលក្ខណៈងាយស្រួលនិងសម្បូរបែបឱ្យទៅជិតប្រជាពលរដ្ឋនិងធានាបាននូវបរិយាកាសសន្តិភាពនិយម និងភាពសុខដុមរមនាក្នុងសង្គមជាតិ។

ទន្ទឹមនេះ, បន្ថែមលើ **“យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១”**, នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកដំបូង, **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក៏បានប្រកាសដាក់ចេញនូវវិធានការគន្លឹះជាអាទិភាពចំនួន៥ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខដោយត្រូវសម្រេចឱ្យចេញជាលទ្ធផល នៅក្នុងនីតិកាលទី ៧ នៃរដ្ឋសភានេះ ដោយក្នុងនោះ **“ការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌”** គឺជាអាទិភាពដ៏សំខាន់មួយក្នុងចំណោមវិធានការគន្លឹះទាំង ៥ នេះ ហើយ សម្តេចធិបតីនាយករដ្ឋមន្ត្រី បានសម្រេចប្រគល់ភារកិច្ចនេះ ជូនក្រសួងយុត្តិធម៌ ក្នុងការរៀបចំផែនការសកម្មភាពជាក់ស្តែង សំដៅធ្វើយ៉ាងណា

សម្រេចឱ្យបាននូវកិច្ចការអាទិភាពសំខាន់ៗចំនួន ៣ ដែលក្នុងនោះរួមមាន៖ **(ទី១)**-ការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បន្ថែមលើយន្តការដែលមានស្រាប់ ដើម្បីជួយសម្រុះសម្រួលដោះស្រាយវិវាទឱ្យបានឆាប់រហ័សជាពិសេសវិវាទរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន, **(ទី២)**-ការជំរុញនិងការពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការឱ្យបានឆាប់រហ័ស និង **(ទី៣)**-ការត្រួតពិនិត្យនិងការដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការសំដៅជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ក៏ដូចជាលើកកម្ពស់តម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវក្នុងការអនុវត្តច្បាប់ និងចំណាត់ការរឿងក្តីដោយតុលាការ។

ផ្អែកតាម **“យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១”** និង **“វិធានការគន្លឹះ”** ខាងលើនេះ, ជាទិសដៅការងារទៅមុខ, ការកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា នឹងត្រូវប្រមូលផ្តុំការយកចិត្តទុកដាក់ទៅលើ **“សសរស្តម្ភ”** ចំនួន ២ គឺ **(សសរស្តម្ភទី១)**-ការកែទម្រង់ប្រព័ន្ធតុលាការ សំដៅទិតខំធ្វើឱ្យប្រសើរឡើងជាលំដាប់ជាបន្តទៀត នូវគុណភាព និងប្រសិទ្ធភាព ទាំងលើការផ្តល់សេវាយុត្តិធម៌ប្រកបដោយភាពឆាប់រហ័ស ទាំងលើគុណភាពនៃយុត្តិធម៌ប្រកបដោយភាពសុក្រឹតនិងភាពត្រឹមត្រូវ និង **(សសរស្តម្ភទី២)**-ការកែទម្រង់ប្រព័ន្ធដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ សំដៅបង្កើតសេវានៃការដោះស្រាយវិវាទដែលមានលក្ខណៈងាយស្រួល និងសម្បូរបែបឱ្យទៅជិតប្រជាពលរដ្ឋនៅមូលដ្ឋាន,ជួយសម្រុះសម្រួលផ្សះផ្សាដោះស្រាយបញ្ហាវិវាទឱ្យបានឆាប់រហ័សជូនប្រជាពលរដ្ឋ ព្រមទាំងរួមចំណែកលើកកម្ពស់វប្បធម៌សន្តិភាពនិយមក្នុងសង្គមកម្ពុជា។

ហេតុដូចនេះ លើទិដ្ឋភាពនយោបាយ ការបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនាពេលនេះ គឺជា **“ការបោះជំហានថ្មីមួយ”** ដ៏មានសារសំខាន់សម្រាប់ការកែទម្រង់យន្តការដោះស្រាយវិវាទនៅកម្ពុជាឱ្យមានភាពកាន់តែសម្បូរបែបនិងងាយស្រួលប្រើប្រាស់ហើយអាចឆ្លើយតបបានទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ពិសេសនៅតាមមូលដ្ឋានស្របតាមទិសដៅនិងចក្ខុវិស័យនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាលព្រមទាំងវិធានការគន្លឹះអាទិភាពទាំង ៥ ចំណុចរបស់ **សម្តេចតិបតីនាយករដ្ឋមន្ត្រី** ដែលបានប្រកាសដាក់ចេញជាផ្លូវការក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ កន្លងទៅ។

២-មូលដ្ឋានផ្នែកច្បាប់

លើទិដ្ឋភាពច្បាប់, ការដោះស្រាយវិវាទអាចប្រព្រឹត្តទៅទាំងតាមប្រព័ន្ធតុលាការ ទាំងតាមយន្តការក្រៅប្រព័ន្ធតុលាការ លើកលែងតែករណីខ្លះដែលច្បាប់កំណត់ជាសមត្ថកិច្ចផ្តាច់មុខរបស់ស្ថាប័នតុលាការដូចជាករណីរឿងព្រហ្មទណ្ឌជាដើម។ វិធីសាស្ត្រនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បានក្លាយជាផ្នែកមួយដ៏សំខាន់នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា។ ដូចនេះ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការពុំមែនជារឿងថ្មីនោះទេ។ដូចបានគូសបញ្ជាក់ពីខាងដើមយន្តការ

ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាច្រើនត្រូវបានអនុញ្ញាតដោយច្បាប់។

ចំពោះវិធីសាស្ត្រដែលត្រូវបាននិយមយកមកប្រើដើម្បីដោះស្រាយវិវាទនៅក្នុងសង្គមនីតិរដ្ឋ មាន ២ សំខាន់ គឺ៖ **“វិធីកាត់ក្តី”** និង **“វិធីសម្រុះសម្រួលផ្សះផ្សាវិវាទ”**។ វិធីសាស្ត្រទាំងពីរនេះ ត្រូវបានច្បាប់អនុញ្ញាតឱ្យប្រើ ទាំងក្នុងយន្តការតុលាការ ទាំងក្នុងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។សម្រាប់ប្រព័ន្ធតុលាការ,**“ការកាត់ក្តី”** គឺជាវិធីសាស្ត្រដែលត្រូវបានប្រើជាទូទៅដោយតុលាការដើម្បីដោះស្រាយវិវាទ។ របៀបនៃការដោះស្រាយវិវាទដោយការសម្រេចសេចក្តីនេះ ក៏ត្រូវបានទទួលស្គាល់ផងដែរ ដល់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធ ហើយដែលគេស្គាល់ជាទូទៅ គឺ **“យន្តការមជ្ឈត្តការ”** ឬ **“យន្តការអាជ្ញាកណ្តាល”**។ ការដោះស្រាយវិវាទដោយ **“ការកាត់ក្តី”** នេះ ថ្វីត្បិតតែជាទូទៅនឹងផ្តល់លទ្ធផលជាដំណោះស្រាយឱ្យមានភាគីម្ខាងជាភាគីឈ្នះក្តី ហើយភាគីម្ខាងទៀតជាភាគីចាញ់ក្តីក៏ពិតមែន ប៉ុន្តែវិធីដោះស្រាយវិវាទបែបនេះគឺមានភាពចាំបាច់ដើម្បីធានាការពារសិទ្ធិស្របច្បាប់របស់បុគ្គលនៅក្នុងសង្គម ហើយផ្តល់យុត្តិធម៌ទៅដល់បុគ្គលរងគ្រោះ ដែលសិទ្ធិស្របច្បាប់របស់ខ្លួនត្រូវបានរំលោភបំពាន។ ទន្ទឹមនឹងរបៀបដោះស្រាយវិវាទដោយ **“ការកាត់ក្តី”**, ច្បាប់ក៏អនុញ្ញាតឱ្យមានវិធីដោះស្រាយវិវាទដោយ **“ការសម្រុះសម្រួល ផ្សះផ្សា”** ផងដែរ ជាពិសេសសម្រាប់វិវាទក្នុងវិស័យមួយចំនួនដែលច្បាប់អនុញ្ញាត។ យោងតាមច្បាប់ជាធរមាន, ការដោះស្រាយវិវាទតាមរយៈការសម្រុះសម្រួលផ្សះផ្សាគ្នានេះ គឺត្រូវបានអនុញ្ញាតទាំងនៅក្នុងប្រព័ន្ធតុលាការ ទាំងនៅក្រៅប្រព័ន្ធតុលាការ។ លើសពីនេះ ចំពោះវិវាទមួយចំនួន ច្បាប់តម្រូវឱ្យមានការសម្រុះសម្រួលផ្សះផ្សាគ្នាជាមុន ទើបអាចឈានទៅរកការដោះស្រាយ តាមរយៈការកាត់ក្តី[8]។

ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ចៅក្រមក៏អាចធ្វើការសម្រុះសម្រួល និងផ្សះផ្សារវាងគូភាគី ដើម្បីបញ្ចប់វិវាទនៅក្នុងសំណុំរឿងរដ្ឋប្បវេណី ហើយការសម្រុះសម្រួលនេះ អាចធ្វើ ឡើងបាននៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ។ យោងតាមមាត្រា១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី, *នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ឃើញថាមិនសមរម្យ។ បន្ថែមពីនេះ មាត្រា២២០ នៃក្រមដដែលបានបញ្ជាក់ថាភាគីអាចធ្វើការផ្សះផ្សានៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការផ្សះផ្សាបាន។ ការផ្សះផ្សានេះអាចធ្វើនៅក្រៅទីតាំងតុលាការក៏បាន ប្រសិនបើតុលាការ*

8. នៅប្រទេសបារាំង ចាប់តាំងពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣, វាល់វិវាទទាំងឡាយណាដែលមានទឹកប្រាក់មិនលើសពី ៥០០០អឺរ៉ូ ភាគីចាំបាច់ត្រូវស្វែងរកដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាមុនសិន ទើបអាចប្តឹងទៅតុលាការបាន។ ប្រសិនបើភាគីប្តឹងទៅតុលាការមិនទាន់ស្វែងរកដំណោះស្រាយវិវាទក្រៅផ្លូវតុលាការជាមុននោះទេចៅក្រមត្រូវបដិសេធបណ្តឹងនោះតែម្តង។ក្នុងន័យនេះការស្វែងរកដំណោះស្រាយក្រៅប្រព័ន្ធតុលាការបានក្លាយជាកាតព្វកិច្ចសម្រាប់សំណុំរឿងដែលមានចំនួនទឹកប្រាក់តិច។ (Décret no 2023-357 du 11 mai 2023 relatif à la tentative préalable obligatoire de la médiation, de conciliation ou de procedure participative en matière civile).

*យល់ឃើញថាសមរម្យ។ ការផ្សះផ្សាដែលធ្វើឡើងដោយតុលាការ គឺមានតម្លៃគតិយុត្តរឹងមាំ ដោយហេតុថា **កំណត់ហេតុស្តីពីការសះជា** ដែលជាលទ្ធផលនៃការផ្សះផ្សាបញ្ចប់វិវាទដោយចៅក្រមមាន តម្លៃជាលិខិតអនុវត្ត[9] និងមានអានុភាពដូចសាលក្រមស្ថាពរ[10]។* ប៉ុន្តែ, លើការជាក់ស្តែង, ការដោះស្រាយសំណុំរឿងដោយការសម្រុះសម្រួលផ្សះផ្សានេះមិនសូវត្រូវបានប្រើដោយចៅក្រមនោះទេដោយសារការសម្រុះសម្រួលវិវាទត្រូវការពេលវេលាច្រើនខណៈពេលដែលចៅក្រមត្រូវទទួលបន្ទុកដោះស្រាយសំណុំរឿងជាច្រើន។ ហេតុដូចនេះ ជាទូទៅ ការសម្រុះសម្រួលផ្សះផ្សាវិវាទតែងប្រព្រឹត្តទៅនៅក្រៅប្រព័ន្ធតុលាការ។ ផ្អែកលើមូលដ្ឋាននៃការសិក្សាស្រាវជ្រាវអំពីប្រព័ន្ធដោះស្រាយវិវាទដែលកំពុងអនុវត្តនៅក្នុងបណ្តាប្រទេសជាច្រើន ទាំងក្នុងតំបន់ និងពិភពលោក, វិធីដោះស្រាយវិវាទតាមរយៈការសម្រុះសម្រួលផ្សះផ្សា គឺកំពុងទទួលបានការពេញនិយមកាន់តែច្រើនឡើងពីសំណាក់ភាគីវិវាទហើយយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះក៏ត្រូវបានលើកកម្ពស់ជាលំដាប់ ដោយរួមទាំងការបង្កើតឱ្យមានវិជ្ជាជីវៈច្បាប់ថ្មីមួយគឺ **“សន្ធានការី”** ដែលជាអ្នកជំនាញក្នុងការសម្រុះសម្រួលផ្សះផ្សាវិវាទ។

៣-មូលដ្ឋានផ្នែកសង្គម

លើទិដ្ឋភាពសង្គម, ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានឫសគល់ប្រវត្តិសាស្ត្រយ៉ាងជ្រាលជ្រៅនៅក្នុងបណ្តាប្រទេស និងវប្បធម៌ជាច្រើន។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគឺមានលក្ខណៈស្របទៅនឹងប្រពៃណីនៃការដោះស្រាយវិវាទនៅក្នុងសង្គមកម្ពុជាដែលជាទូទៅប្រជាពលរដ្ឋតែងប្រើយន្តការរដ្ឋបាលដោយប្តឹងទៅអាជ្ញាធរមូលដ្ឋានដូចជាមេភូមិ,មេឃុំ,អភិបាលស្រុក ឬអភិបាលខេត្តជាដើម ដើម្បីជួយដោះស្រាយវិវាទរបស់ពួកគាត់ ហើយវិធីសាស្ត្រក្នុងការដោះស្រាយវិវាទដែលល្អបំផុតតាមរយៈយន្តការរដ្ឋបាលនេះ គឺការសម្រុះសម្រួលផ្សះផ្សាវិវាទ ដើម្បីទទួលបានទូរដំណោះស្រាយមួយ ដែលជា **“ដំណោះស្រាយឈ្នះ-ឈ្នះ”** សម្រាប់ភាគីវិវាទដែលមានការពាក់ព័ន្ធ។

សម្រាប់សង្គមកម្ពុជាក្នុងយុគសម័យទំនើប, ការដោះស្រាយវិវាទដោយការសម្រុះសម្រួលផ្សះផ្សាគ្នា ដែលធានាបាននូវបរិយាកាសឈ្នះ-ឈ្នះសម្រាប់គូភាគីវិវាទ គឺមានមូលដ្ឋានគ្រឹះនៅក្នុង **“នយោបាយឈ្នះ-ឈ្នះ”** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលមិនមែនត្រឹមតែជាការដោះស្រាយវិវាទធម្មតានោះទេ ប៉ុន្តែ **“នយោបាយឈ្នះ-ឈ្នះ”** នេះគឺជារូបមន្តដ៏ស័ក្តិសិទ្ធិក្នុងការដោះស្រាយផ្សះផ្សាបាននូវការបែកបាក់ជាតិនិងការពន្លត់បានទាំងស្រុងនូវភ្លើងសង្គ្រាមដ៏វ៉ាំរ៉ៃរស់ជាងពីរទសវត្សរ៍នៅកម្ពុជា ហើយបាននាំមកនូវការបង្រួបបង្រួមជាតិ, ការឯកភាពជាតិនិងសន្តិភាពពេញបរិបូរណ៍ជូនជាតិមាតុភូមិនិងប្រជាជនកម្ពុជារហូតមកដល់ពេលបច្ចុប្បន្ន ហើយ **សម្តេចតេជោ ហ៊ុន សែន** ត្រូវបានប្រជាជនកម្ពុជាថាត់ទុកនិងប្រសិទ្ធនាមជា **“បិតាសន្តិភាពរបស់កម្ពុជា”**។

II-របបគតិយុត្តនៃការសម្រុះសម្រួលដោះស្រាយវិវាទរបស់ អ.ជ.ក

(១)-តើវិវាទណាខ្លះអាចជាកម្មវត្ថុនៃការសម្រុះសម្រួលផ្សះផ្សាក្នុងក្របខ័ណ្ឌ **អ.ជ.ក.**? (២)-តើការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ត្រូវផ្អែកលើគោលការណ៍គ្រឹះអ្វីខ្លះ? និង(៣)-តើលទ្ធផលជោគជ័យនៃការសម្រុះសម្រួលផ្សះផ្សាវិវាទដោយអ.ជ.ក.មានអានុភាពគតិយុត្តយ៉ាងដូចម្តេច?

១- វិវាទដែលជាកម្មវត្ថុនៃការសម្រុះសម្រួលផ្សះផ្សាដោយ អ.ជ.ក.

ប្រភេទនៃវិវាទដែលអាចជាកម្មវត្ថុនៃការសម្រុះសម្រួលផ្សះផ្សាក្នុងក្របខ័ណ្ឌ**អ.ជ.ក.** ត្រូវបានកំណត់នៅក្នុងមាត្រា២ និងមាត្រា១១ នៃព្រះរាជក្រឹត្យបង្កើត **អ.ជ.ក.**។ ផ្អែកតាមមាត្រាទាំង ២ នេះ, វិវាទដែលជាកម្មវត្ថុនៃការសម្រុះសម្រួលផ្សះផ្សា ក្នុងសមត្ថកិច្ចរបស់ **អ.ជ.ក.** រួមមានវិវាទរដ្ឋប្បវេណីវិវាទពាណិជ្ជកម្ម និងវិវាទដទៃទៀតដែលផ្អែកតាមច្បាប់ការបញ្ចប់វិវាទទាំងនេះចំណុំឱ្យសេរីភាពនៃឆន្ទៈរបស់ភាគីវិវាទ។ ការសម្រុះសម្រួលផ្សះផ្សាវិវាទនៅក្នុងក្របខ័ណ្ឌ **អ.ជ.ក.** មិនអាចធ្វើបានឡើយចំពោះបទល្មើសព្រហ្មទណ្ឌ លើកលែងតែច្បាប់អនុញ្ញាត។

ពាក្យបណ្តឹងដែល **អ.ជ.ក.** ទទួលយកមកពិនិត្យ និងសម្រុះសម្រួលដោះស្រាយ អាចជាពាក្យបណ្តឹងដែលទទួលផ្ទាល់ពីរូបបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់បណ្តឹង ឬអាចទទួលបានតាមរយៈការបញ្ជូនមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងស្ថាប័នថ្នាក់ជាតិ និងស្ថាប័នថ្នាក់ក្រោមជាតិ។ ទន្ទឹមនេះ **អ.ជ.ក.** ក៏អាចទទួលពិនិត្យ និងដោះស្រាយនូវសំណុំរឿងវិវាទដែលបញ្ជូនមកពី សាលាជម្រះក្តីជាន់ទាបក្នុងករណីភាគីវិវាទណាមួយបានបង្ហាញឆន្ទៈឱ្យធ្វើការសម្រុះសម្រួលផ្សះផ្សាវិវាទរបស់ខ្លួន។ ការបញ្ជូនសំណុំរឿងពីតុលាការមក **អ.ជ.ក.** នេះ អាចធ្វើឡើងតាមសំណើរបស់ភាគីវិវាទទាំងសងខាង ឬតាមសំណើរបស់ភាគីណាមួយ។ ការសម្រេចលើការបញ្ជូននេះ គឺជា ឆន្ទានុសិទ្ធិរបស់ចៅក្រម។ ប៉ុន្តែ ដើម្បីចៀសវាងនូវស្ថានភាពនៃការអូសបន្លាយនីតិវិធីក្នុងការសម្រេចក្តីតាមរយៈការបញ្ជូនសំណុំរឿងមក**អ.ជ.ក.** ឬក្នុងករណីដែលភាគីយល់ឃើញថាការដោះស្រាយដោយការសម្រុះសម្រួលគ្នានៅ**អ.ជ.ក.** មិនអាចប្រព្រឹត្តទៅបាន,ភាគីណាមួយនៃវិវាទមានសិទ្ធិស្នើសុំទៅតុលាការ ដើម្បីបន្តចំណាត់ការនីតិវិធីលើសំណុំរឿងវិវាទឡើងវិញ។ បែបបទ និងនីតិវិធីនៃការបញ្ជូនសំណុំរឿងវិវាទរវាងសាលាជម្រះក្តី និង **អ.ជ.ក.** ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

9. ចំណុច ឈ កថា១ណ្ឌទី២ នៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី។
10. មាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា “ក្នុងករណីដែលមានការសះជាការលះបង់នូវការទាមទារ ឬការទទួល ស្គាល់នូវការទាមទារ ត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ កំណត់ត្រានេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ”” ។

២- គោលការណ៍នៃការសម្រុះសម្រួលដោះស្រាយវិវាទដោយ អ.ជ.ក.

យោងតាមមាត្រា ១១ នៃព្រះក្រឹត្យបង្កើត **អ.ជ.ក.**, ការដោះស្រាយវិវាទក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ត្រូវធ្វើឡើងតាមរយៈ**ការសម្រុះសម្រួលផ្សះផ្សា**។ ផ្អែកតាមមាត្រា១១ នេះ វិធីសាស្ត្រដោះស្រាយវិវាទរបស់ **អ.ជ.ក.** គឺមានទាំងវិធីសាស្ត្រ ការសម្រុះសម្រួល ទាំងវិធីសាស្ត្រ ការ**ផ្សះផ្សា**។ ក្នុងន័យនេះ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទរបស់ **អ.ជ.ក.** ត្រូវដើរតួនាទីសកម្ម ទាំងលើការកំណត់អំពីចំណុចវិវាទ ការកំណត់អំពីការទាមទារ ក៏ដូចជាអាចផ្តល់នូវមតិជាការវាយតម្លៃអំពីវិវាទ ការស្នើនូវដំណោះស្រាយសម្រាប់បញ្ចប់វិវាទ ព្រមទាំងការផ្តល់យោបល់អំពីផលវិបាកដែលអាចកើតមានពីការព្រមព្រៀងបញ្ចប់វិវាទ។ ក្នុងកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទជាអ្នកសម្រុះសម្រួលជួយផ្សះផ្សាវិវាទនិងជួយបំផុសនូវជម្រើសនៃដំណោះស្រាយដល់ភាគីវិវាទ ដោយត្រូវប្រកាន់នូវជំហរអព្យាក្រឹតនិងមិនលំអៀង និងត្រូវផ្តល់ឱ្យភាគីវិវាទនូវឱកាសព្រមព្រៀងសះជាវិវាទដោយសន្តិវិធី និងដោយគ្មានការធ្វើសេចក្តីសម្រេចដោយបង្ខំណាមួយឡើយ។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ គ្មានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចណាមួយជំនួសភាគីវិវាទបានឡើយ។ នៅគ្រប់ករណីរាល់ដំណោះស្រាយចំពោះវិវាទត្រូវតែគោរពតាមឆន្ទៈយល់ព្រមដោយសេរី និងដោយស្ម័គ្រចិត្តរបស់ភាគីវិវាទ។ ភាគីវិវាទមានសិទ្ធិស្មើគ្នានៅគ្រប់ដំណាក់កាលនៃការសម្រុះសម្រួលវិវាទ។

នៅក្នុងកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទនេះមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឬក្រុមការងារសម្រុះសម្រួលវិវាទ ឬសមាសភាព **អ.ជ.ក.** អាចកោះអញ្ជើញភាគីវិវាទ សាក្សី ឬបុគ្គលពាក់ព័ន្ធផ្សេងទៀត, ណែនាំឱ្យភាគីវិវាទបញ្ជាក់ពីការទាមទារ ឬផ្តល់ព័ត៌មានបន្ថែមលើការទាមទារ ឬស្រាវជ្រាវព័ត៌មានផ្សេងទៀតដែលទាក់ទងនឹងវិវាទដោយយោងតាមការចាំបាច់ដើម្បីជាមូលដ្ឋានក្នុងការដោះស្រាយវិវាទ។ ការចូលរួមក្នុងកិច្ចដំណើរការនេះជាសិទ្ធិសេរីភាពរបស់ភាគី។ ក្នុងករណីដែលភាគីមិនព្រមចូលរួមមានន័យថាភាគីមិនយល់ព្រមធ្វើការសម្រុះសម្រួលផ្សះផ្សាវិវាទរបស់ខ្លួនឡើយ។ ក្នុងករណីដែលភាគីចូលរួម ភាគីវិវាទចូលរួមដោយផ្ទាល់ ឬភាគីអាចត្រូវបានតំណាងដោយអ្នកតំណាងដោយអាណត្តិ ឬអាចអមដោយមេធាវី ឬអ្នកប្រឹក្សាយោបល់របស់ខ្លួនតាមការចាំបាច់។ ក្នុងកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ត្រូវធានាថា គ្រប់ភាគី និងបុគ្គលពាក់ព័ន្ធទទួលបាននូវព័ត៌មាន និងការពន្យល់បំភ្លឺយ៉ាងច្បាស់ និងត្រឹមត្រូវអំពីកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទ សិទ្ធិរបស់ភាគី ការរក្សាការសម្ងាត់វិជ្ជាជីវៈ និងផលវិបាកនានាដែលអាចកើតមានពីការព្រមព្រៀងបញ្ចប់វិវាទជាពិសេសអានុភាពនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទក្នុងករណីដែលភាគីវិវាទព្រមព្រៀងសះជាបញ្ចប់

វិវាទនឹងគ្នា។ បែបបទ និងនីតិវិធីនៃការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌនៃ អ.ជ.ក. ត្រូវកំណត់ដោយសេចក្តីសម្រេច របស់ **អ.ជ.ក.**[11]។

ការសម្រុះសម្រួលផ្សះផ្សាយវិវាទក្នុងក្របខ័ណ្ឌអ.ជ.ក.អាចត្រូវធ្វើឡើងដោយ៖(១)-**មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ** ឬ (២)-**ក្រុមការងារសម្រុះសម្រួលវិវាទ** ឬដោយ (៣)- **អ.ជ.ក.** តែម្តង។

- **មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ អ.ជ.ក.៖** ដើម្បីអាចទទួលបានការចាត់តាំងពី **អ.ជ.ក.** មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ អ.ជ.ក. ត្រូវទទួលបាននីតិសម្បទាពី អ.ជ.ក. ជាមុនសិន។ តើនរណាខ្លះអាចក្លាយជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.**? តើដើម្បីអាចក្លាយជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ អ.ជ.ក. ត្រូវគោរពលក្ខខណ្ឌអ្វីខ្លះ? មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** អាចត្រូវបានជ្រើសរើសចេញពីក្នុងចំណោមមន្ត្រីរាជការក្របខ័ណ្ឌ ឬពីក្នុងចំណោមសារការី មេធាវី និងអ្នកប្រកបវិជ្ជាជីវៈច្បាប់ផ្សេងទៀត ឬបុគ្គលផ្សេងទៀតដែលមានជំនាញផ្នែកច្បាប់ ឬជំនាញពាក់ព័ន្ធនឹងការដោះស្រាយវិវាទ។ ការជ្រើសរើសមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃអ.ជ.ក.ធ្វើឡើងតាមរយៈការប្រឡងជ្រើសរើសដែលរៀបចំ ឡើងដោយ **អ.ជ.ក.**។ បន្ទាប់ពីត្រូវបានជ្រើសរើស, មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ត្រូវទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈដែលរៀបចំដោយក្រសួងយុត្តិធម៌លើជំនាញច្បាប់ ជំនាញដោះស្រាយវិវាទ ក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិ[12]។ ក្រសួងយុត្តិធម៌បានប្រគល់សិទ្ធិក្នុងការបណ្តុះបណ្តាលនេះឱ្យទៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ដោយត្រូវសហការជាមួយអគ្គលេខាធិការដ្ឋាននៃ**អ.ជ.ក.**។បន្ទាប់ពីទទួលបានជោគជ័យក្នុងការបណ្តុះបណ្តាលនេះ, មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ទទួលបាននូវវិញ្ញាបនបត្របណ្តុះបណ្តាលជំនាញសម្រុះសម្រួលដោះស្រាយវិវាទដែលចេញដោយក្រសួងយុត្តិធម៌។ បន្ទាប់មកមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលបានបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យត្រូវដាក់ពាក្យស្នើសុំ និងត្រូវទទួលបាននីតិសម្បទាពី **អ.ជ.ក.** ជាមុនសិន ទើបអាចបំពេញមុខងាររបស់ខ្លួនក្នុងក្របខ័ណ្ឌនៃ **អ.ជ.ក.** បាន។

នីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនេះ ក៏អាចត្រូវបានផ្តល់ជូនបុគ្គលផ្សេងទៀតផងដែរ ជាអាទិ៍ អតីតចៅក្រម អតីតព្រះរាជអាជ្ញា អតីតក្រឡាបញ្ជី ឬអតីតអាជ្ញាសាលាដែលបានប្រកបវិជ្ជាជីវៈយ៉ាងតិច៣ឆ្នាំ, មេធាវី ឬសារការីដែលបានប្រកបវិជ្ជាជីវៈរយៈពេលយ៉ាង

11. សេចក្តីសម្រេចលេខ ០០២៤ សសរ.អ.ជ.ក. ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីបែប និងនីតិវិធីនៃការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌនៃអាជ្ញាធរជាតិ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
12. សេចក្តីសម្រេចលេខ ០០៦/២៤ សសរ.អ.ជ.ក. ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ ស្តីពីក្រមសីលធម៌ និងក្រមប្រតិបត្តិសម្រាប់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ នៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

តិច ៣ឆ្នាំ, សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល ឬមជ្ឈត្តករដែលមានបទពិសោធន៍ការងារដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរយៈពេលយ៉ាងតិច ៣ឆ្នាំ, ឥស្សរជន ឬមន្ត្រីសាធារណៈដែលមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងការដោះស្រាយវិវាទរយៈពេលយ៉ាងតិច ៣ឆ្នាំ, បុគ្គលដែលមានសញ្ញាបត្រ ឬវិញ្ញាបនបត្រជំនាញសម្រុះសម្រួលដោះស្រាយវិវាទដែលទទួលស្គាល់ដោយក្រសួងយុត្តិធម៌ និងបុគ្គលដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ និងមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរយៈពេលយ៉ាងតិច ៣ឆ្នាំ។ បែបបទនីតិវិធីនិងគុណវុឌ្ឍិសម្រាប់ការផ្តល់នីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ**អ.ដ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ដ.ក.**[13]។ មុននឹងអនុវត្តមុខងាររបស់ខ្លួន ពោលគឺមុននឹងអាចធ្វើការសម្រុះសម្រួលដោះស្រាយវិវាទបានមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ**អ.ដ.ក.** ដែលទទួលបាននីតិសម្បទា ត្រូវធ្វើសច្ចាប្រណិធានដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌។

-**ក្រុមការងារសម្រុះសម្រួលវិវាទ**៖ការសម្រុះសម្រួលវិវាទក្នុងក្របខ័ណ្ឌ**អ.ដ.ក.**អាចធ្វើឡើងដោយក្រុមការងារសម្រុះសម្រួលវិវាទ។ ប្រធាន**អ.ដ.ក.**អាចបង្កើតក្រុមការងារសម្រុះសម្រួលវិវាទមួយចំនួនតាមការចាំបាច់ដោយសេចក្តីសម្រេចដើម្បីចុះទៅសម្រុះសម្រួលផ្សះផ្សាបញ្ចប់វិវាទដោយផ្ទាល់នៅតាមមូលដ្ឋានជាពិសេស បណ្តឹងដែលប្រជាពលរដ្ឋបានប្តឹងទៅការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានក្រុង-ស្រុក-ខណ្ឌ ឬប្តឹងទៅឃុំ-សង្កាត់នានា។ ក្រុមការងារសម្រុះសម្រួលវិវាទនេះចាំបាច់ត្រូវដឹកនាំដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ**អ.ដ.ក.** និងអាចមានសមាសភាពផ្សេងទៀតចូលរួម ដែលជាអ្នកជំនាញផ្នែកច្បាប់ ឬកិច្ចការសង្គម។ សមាសភាពផ្សេងទៀតនេះ អាចជាចាស់ព្រឹទ្ធាចារ្យ អាចារ្យវត្ត ឬប្រធានសហគមន៍ជនជាតិដើមភាគតិចជាដើម។ ការបង្កើតជាក្រុមការងារសម្រុះសម្រួលវិវាទនេះ មានភាពចាំបាច់នៅពេលដែល**អ.ដ.ក.** ចុះធ្វើការដោះស្រាយវិវាទផ្ទាល់នៅតាមមូលដ្ឋាន តាមសហគមន៍ជនជាតិដើមភាគតិចនៅតាមតំបន់ដាច់ស្រយាលនានា។ ប៉ុន្តែ ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងច្បាស់លាស់ជាពិសេស ក្នុងការរៀបចំកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទដែលមានអានុភាពអនុវត្ត ក្រុមការងារនេះត្រូវតែដឹកនាំដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និងមាននីតិសម្បទាពី **អ.ដ.ក.**។

- **ការសម្រុះសម្រួលផ្សះផ្សាដោយ អ.ដ.ក.**៖ វិវាទដែលប្តឹងមក **អ.ដ.ក.** ក៏អាចត្រូវបានដោះស្រាយដោយផ្ទាល់ដោយ **អ.ដ.ក.** ក្រោមការដឹកនាំរបស់ប្រធាន **អ.ដ.ក.** អនុប្រធាន ឬសមាជិកណាមួយនៃ**អ.ដ.ក.** ផងដែរ។ ប្រធាន**អ.ដ.ក.**អាចចាត់តាំងសមាជិក**អ.ដ.ក.** ណាម្នាក់ដើម្បីធ្វើជាតំណាងឱ្យ **អ.ដ.ក.** ក្នុងការទទួលពិនិត្យ និងសម្រុះសម្រួលដោះស្រាយវិវាទក្នុងនាម**អ.ដ.ក.**។ ការសម្រុះសម្រួលផ្សះផ្សាវិវាទដោយ **អ.ដ.ក.** ត្រូវអនុវត្តតាមបែបបទ និងនីតិវិធីដូចគ្នានឹងការសម្រុះសម្រួលផ្សះផ្សាវិវាទដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ដ.ក.** ផងដែរ។

៣-អនុភាពគតិយុត្តនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទដោយ អ.ដ.ក.

ក្នុងករណីដែលការសម្រុះសម្រួលផ្សះផ្សាវិវាទទទួលបានជោគជ័យ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទឬសមាជិក**អ.ដ.ក.**ដែលទទួលបន្ទុកត្រូវរៀបចំចេញ **កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ**។ ក្នុងករណីដែលចំណុចវិវាទមានច្រើន ហើយភាគីវិវាទព្រមព្រៀងគ្នាបញ្ចប់តែលើចំណុចមួយចំនួននោះ កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ ក៏អាចត្រូវបានធ្វើឡើងផងដែរ ប៉ុន្តែ ត្រូវធ្វើតែលើចំណុចវិវាទដែលភាគីបានព្រមព្រៀងគ្នាប៉ុណ្ណោះ។ ដោយឡែក ក្នុងករណីដែលការសម្រុះសម្រួលផ្សះផ្សាវិវាទ មិនទទួលបានជោគជ័យ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទឬសមាជិក**អ.ដ.ក.** ទទួលបន្ទុក ត្រូវរៀបចំជារបាយការណ៍ច្បាស់លាស់។ ចំពោះសំណុំរឿងដែលត្រូវបានបញ្ជូនមក អ.ដ.ក. ដោយសាលាជម្រះក្តីជាន់ទាប, ក្រោយបញ្ចប់ការសម្រុះសម្រួលផ្សះផ្សាវិវាទ, **អ.ដ.ក.** ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការសម្រុះសម្រួលផ្សះផ្សាវិវាទ ទៅសាលាជម្រះក្តីដែលបានបញ្ជូនសំណុំរឿងវិវាទនោះមក អ.ដ.ក. ដោយភ្ជាប់ជាមួយនូវសំណុំរឿង និងឯកសារពាក់ព័ន្ធ។ ក្នុងករណីដែលវិវាទមិនអាចដោះស្រាយបានដោយជោគជ័យដោយ **អ.ដ.ក.**, សាលាជម្រះក្តីត្រូវបន្តចំណាត់ការដោះស្រាយស្របតាមច្បាប់ និងនីតិវិធីជាធរមាន។ បែបបទ នីតិវិធីលម្អិតនៃការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌនៃ **អ.ដ.ក.** ព្រមទាំងទម្រង់បែបបទ និងខ្លឹមសារសំខាន់ៗនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ត្រូវកំណត់ដោយ **អ.ដ.ក.**។

ភាគីដែលមិនសុខចិត្តនឹងកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ មានសិទ្ធិប្តឹងតវ៉ាទៅ**អ.ដ.ក.** ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃធ្វើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ។ ក្នុងករណីដែលមិនមានបណ្តឹងតវ៉ានោះទេឬក្នុងករណីដែលបណ្តឹងតវ៉ានេះត្រូវបានសម្រេចបដិសេធដោយ**អ.ដ.ក.** នោះកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ ត្រូវចាត់ទុកថាបានធ្វើឡើងត្រឹមត្រូវ។ កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទដែលត្រូវបានធ្វើឡើងត្រឹមត្រូវ មានតម្លៃគតិយុត្តរឹងមាំ ដែលនេះជាលក្ខណៈពិសេសនៃការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌនៃអ.ដ.ក.បើធៀបទៅនឹងការដោះស្រាយវិវាទដោយយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្សេងទៀត។ តើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះមានតម្លៃគតិយុត្តរឹងមាំយ៉ាងដូចម្តេច? តើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះមានអានុភាពគតិយុត្តយ៉ាងដូចម្តេចខ្លះ?

13. សេចក្តីសម្រេចលេខ ០០២/២៤ សសរ.អ.ដ.ក. ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្តីពីបែបទ នីតិវិធី និងគុណវុឌ្ឍិសម្រាប់ការផ្តល់នីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃអាជ្ញាជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ នៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

ផ្អែកតាមមាត្រា១៥ នៃព្រះរាជក្រឹត្យបង្កើត **អ.ជ.ក.** បានបញ្ជាក់ថា កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទក្នុងក្របខ័ណ្ឌនៃ អ.ជ.ក. ដែលត្រូវបានធ្វើឡើងត្រឹមត្រូវ មានអានុភាពគតិយុត្តសំខាន់ៗ ចំនួន ២ គឺ៖

- កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ **មាន តម្លៃគតិយុត្តដូចលិខិតយថាភូត និងត្រូវចាត់ទុកជាបន្ទាល់** ដែលតុលាការត្រូវតែជឿរហូតដល់មានភស្តុតាងផ្ទុយ ឬមានភស្តុតាងដែលបង្ហាញពីការក្លែងបន្លំ ឬវិការៈដទៃទៀតនៅក្នុងកំណត់ហេតុនេះ។ មានន័យថា ប្រសិនបើគ្មានការក្លែងបន្លំឬគ្មានវិការៈនៃការព្រមព្រៀងនោះទេ, កំណត់ហេតុនេះមានតម្លៃជាភស្តុតាងរឹងមាំដែលភាគីមិនអាចកែប្រែ ឬប្រកែកបានឡើយនៅចំពោះមុខតុលាការ។

- កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ **មាន អានុភាពអនុវត្តដូចគ្នានឹងសាលក្រមស្ថាពរ** របស់តុលាការ និងត្រូវចាត់ទុកជា **លិខិតអនុវត្ត** ដូចមានចែងក្នុងចំណុច ឈ នៃកថាខណ្ឌទី២ នៃមាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ក្នុងន័យនេះ ក្នុងករណីដែលមានភាគីណាមិនព្រមអនុវត្តដោយស្ម័គ្រចិត្តតាមខ្លឹមសារនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនោះ, ភាគីវិវាទអាចស្នើសុំអនុវត្តកំណត់ហេតុនេះ ដោយអនុវត្តស្របតាមនីតិវិធីច្បាប់ជាធរមាន។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទ ឬសមាជិក **អ.ជ.ក.** ដែលចេញកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ជាអ្នកផ្តល់រូបមន្តអនុវត្តចំពោះកំណត់ហេតុនេះ តាមការស្នើសុំ។ ការកំណត់បែបនេះ គឺផ្អែកលើមូលដ្ឋាននៃមាត្រា ៣៥៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលចែងថា រូបមន្តអនុវត្ត ត្រូវផ្តល់ដោយក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះ តាមពាក្យសុំ។ ប៉ុន្តែ ចំពោះលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុច ច នៃកថាខណ្ឌទី២ នៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ (*សំដៅដល់លិខិតយថាភូតដែលធ្វើឡើងសារការី*) ត្រូវផ្តល់ដោយសារការីដែលរក្សាទុកនូវលិខិតដើមនោះ។ ហេតុដូចនេះ ដោយកំណត់ហេតុព្រមព្រៀមបញ្ចប់វិវាទរបស់ **អ.ជ.ក.** មានតម្លៃដូចជាលិខិតយថាភូត និងសាលាក្រមស្ថាពរ, រូបមន្តអនុវត្តចំពោះកំណត់ហេតុនេះត្រូវផ្តល់ដោយអ្នកដែលធ្វើកំណត់ហេតុនោះពោលគឺដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទ ឬសមាជិក **អ.ជ.ក.** ទទួលបន្ទុក។ ម្យ៉ាងទៀត **អ.ជ.ក.** ត្រូវចាត់នីតិវិធីចាំបាច់នានាដើម្បីធានាដល់ការអនុវត្តកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះផងដែរ។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចេញសេចក្តីណែនាំដើម្បីធានាដល់ការអនុវត្តកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ។

ផ្អែកលើអានុភាពគតិយុត្តទាំងនេះជាគោលការណ៍ភាគីពាក់ព័ន្ធមិនអាចប្តឹងទៅសាលាដំបូងដែលមានសមត្ថកិច្ច ដើម្បីសើរើចំពោះកំណត់ហេតុនេះបាននោះទេ លើកលែងតែ ក្នុងករណីដូចខាងក្រោម៖

- មានភស្តុតាងដែលបង្ហាញពីការក្លែងបន្លំ ឬវិការៈផ្សេងទៀតនៅក្នុងកំណត់ហេតុនេះ។

-ខ្លឹមសារនៃកំណត់ហេតុនេះផ្ទុយនឹងបទប្បញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា[14]។

- កំណត់ហេតុនេះ ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់តតិយជន។ ក្នុងករណីនេះ តតិយជនអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនប្តឹងទៅសាលាដំបូងដែលមានសមត្ថកិច្ច ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ស្រមតាមច្បាប់ និងនីតិវិធីជាធរមាន ដែលអាចជាបណ្តឹងតវ៉ារបស់តតិយជនចំពោះការអនុវត្ត និង/ឬ ជាបណ្តឹងទាមទាររបស់តតិយជន។

ការកំណត់ឱ្យកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ មានតម្លៃជាបន្ទាល់ ជាលិខិតអនុវត្ត និងមានអានុភាពអនុវត្តដូចសាលក្រមស្ថាពរ ក៏ដូចជា កំណត់នូវលក្ខណៈពិសេសរឹងសម្រាប់ការប្តឹងសើរើចំពោះវិវាទដែលបានដោះស្រាយបញ្ចប់ដោយជោគជ័យដោយ អ.ជ.ក. នេះ គឺធ្វើឡើងដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់នៃការសម្រុះសម្រួលវិវាទក្នុងក្របខ័ណ្ឌអ.ជ.ក. និងធានាថាវិវាទដែលបានសម្រុះសម្រួលផ្សះផ្សាដោយជោគជ័យដោយអ.ជ.ក. ត្រូវបានដោះស្រាយចប់ជាស្ថាពរតែម្តង។

ទន្ទឹមនេះ ផ្អែកតាមអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការក្នុងការសម្រុះសម្រួលផ្សះផ្សាវិវាទជាមួយ **អ.ជ.ក.**, ក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ អាចស្នើសុំមក **អ.ជ.ក.** ដើម្បីទទួលស្គាល់ការសម្រុះសម្រួលវិវាទព្រមទាំងពិនិត្យនិងរៀបចំកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ចំពោះវិវាទដែលត្រូវបានសម្រុះសម្រួលបញ្ចប់ក្នុងក្របខ័ណ្ឌស្ថាប័នរបស់ខ្លួន។ បច្ចុប្បន្ន **អ.ជ.ក.**បានចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការនេះជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមួយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ តាមរយៈអនុស្សរណៈនៃការយោគយល់គ្នានេះ វិវាទដែលត្រូវបានសម្រុះសម្រួលបញ្ចប់ដោយមេធាវី ឬដោយមជ្ឈត្តករក៏អាចជាកម្មវត្ថុនៃការធ្វើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទក្នុងក្របខ័ណ្ឌនៃ **អ.ជ.ក.** ដែលមានតម្លៃគតិយុត្តដូចគ្នានឹងការសម្រុះសម្រួលផ្សះផ្សាវិវាទដែលធ្វើឡើងដោយផ្ទាល់ដោយ **អ.ជ.ក.** សំដៅឈានទៅបញ្ចប់វិវាទនេះជាស្ថាពរបានផងដែរនេះ។ ក្នុងន័យនេះ បន្ថែមលើកិច្ចខិតខំប្រឹងប្រែងរបស់ **អ.ជ.ក.**, ទាំងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ទាំងមេធាវី ទាំងមជ្ឈត្តករ នឹងក្លាយជាភ្នាក់ងារដ៏សំខាន់ក្នុងការពន្លត់ភ្លើងវិវាទនៅក្នុងសង្គមដោយមិនទុកឱ្យវិវាទ

14.យោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៩ ចំណុច គ, សណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជានេះ ត្រូវបានកំណត់ថាជាលក្ខខណ្ឌសម្រាប់បដិសេធមិនទទួលស្គាល់អានុភាពនៃសាលក្រមស្ថាពររបស់តុលាការបរទេស។ សាលក្រមស្ថាពររបស់តុលាការបរទេសត្រូវមានអានុភាព លុះត្រាតែ “ខ្លឹមសារនៃសាលក្រម និងនីតិវិធីនៃបណ្តឹងនោះ មិនប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា”។ ទន្ទឹមនេះ មាត្រា៣៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី កថាខណ្ឌទី៤ បានបញ្ជូតផងដែរថា តុលាការអាចបដិសេធការអនុវត្តសេចក្តីសម្រេចរបស់មជ្ឈត្តករ ប្រសិនបើយល់ឃើញថា ការទទួលស្គាល់ ឬការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ។

ក្លាយទៅជាវិវាទរ៉ាំរ៉ៃពិបាកដោះស្រាយដែលការណ៍នេះនឹងរួមចំណែកយ៉ាងសំខាន់ក្នុងអនុវត្តឱ្យបានជោគជ័យនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងវិធានការគន្លឹះជាអាទិភាពរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា៕

ទម្រង់សហគ្រាសពាណិជ្ជកម្មនៅកម្ពុជា



ដោយ៖
-ឯកឧត្តម ញ៉ាន ឥណ្ណៈ
រដ្ឋលេខាធិការក្រសួងយុត្តិធម៌
-លោក សាន ម៊ុនឡើន ចៅក្រម
សាលាដំបូងរាជធានីភ្នំពេញ

សេចក្តីផ្តើម

សហគ្រាស គឺជាសញ្ញាណសេដ្ឋកិច្ច ដែលមិនត្រូវបានកំណត់និយមន័យដោយច្បាប់ជាធរមាននោះទេ។ តាមន័យសេដ្ឋកិច្ច, សហគ្រាស សំដៅដល់អង្គភាពសេដ្ឋកិច្ចមួយដែលត្រូវបានបង្កើតឡើង ដើម្បីធ្វើសកម្មភាពអាជីវកម្មណាមួយ ជាអាទិ៍ ការផលិត ការផ្គត់ផ្គង់ទំនិញ ឬការផ្តល់សេវាកម្ម។សហគ្រាសអាចបែងចែងជាច្រើនប្រភេទទៅតាមវិស័យសេដ្ឋកិច្ចដូចជាសហគ្រាសក្នុងវិស័យកសិកម្ម, សហគ្រាសក្នុងវិស័យឧស្សាហកម្ម, សហគ្រាសក្នុងវិស័យសេវាកម្ម និងពាណិជ្ជកម្ម ឬទៅតាមទំហំរបស់សហគ្រាសដូចជាសហគ្រាសមីក្រូ,សហគ្រាសធុនតូចនិងមធ្យមនិងសហគ្រាសធុនធំ។ សហគ្រាស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមតាមរយៈការបង្កើតការងារ, ការបង្កើនចំណូលគ្រួសារ, ការធានានូវកំណើនសេដ្ឋកិច្ច និងបរិយាប័ន្សកល។ ពាក្យសហគ្រាសនេះ គ្របដណ្តប់ទាំងសហគ្រាសឯកបុគ្គល និងសហគ្រាសក្នុងទម្រង់ជាក្រុមហ៊ុន។ តាមន័យសេដ្ឋកិច្ច ក្រុមហ៊ុនគ្រាន់តែជាបច្ចេកទេសគតិយុត្តនៃសហគ្រាស ឬជាយន្តការគតិយុត្តសម្រាប់ប្រមូលទុនវិនិយោគសម្រាប់ការធ្វើអាជីវកម្ម[1]ប៉ុណ្ណោះ។ មានន័យថា រាល់ក្រុមហ៊ុនទាំងអស់សុទ្ធតែជាសហគ្រាស។

ដោយឡែក ក្នុងន័យច្បាប់ សហគ្រាស និងក្រុមហ៊ុន ជាសញ្ញាណ ២ ផ្សេងគ្នា។ ទោះបីជារាល់ក្រុមហ៊ុនសុទ្ធតែជាសហគ្រាស ប៉ុន្តែ រាល់សហគ្រាសមិនសុទ្ធតែជាក្រុមហ៊ុននោះទេ។ សហគ្រាសអាចជាសហគ្រាសសាធារណៈ[2] ឬជាសហគ្រាសឯកជនដែលមានរបបគតិយុត្តផ្សេងគ្នា។ តាមច្បាប់ សកម្មភាពអាជីវកម្មមួយ ទោះជាពាណិជ្ជកិច្ចក្តីឬមិនមែនជាពាណិជ្ជកិច្ចក្តីអាចធ្វើឡើងក្នុងទម្រង់ជាសហគ្រាសឯកបុគ្គល ឬក្នុងទម្រង់ជាក្រុមហ៊ុន។ ការសម្រេចជ្រើសរើសយកទម្រង់ជាសហគ្រាសឯកបុគ្គល ឬទម្រង់ជាក្រុមហ៊ុន គឺផ្អែកលើភាពខុសគ្នាត្រង់ចំណុចសំខាន់ៗជាអាទិ៍៖ (១)-ការបង្កើតសហគ្រាស ឬក្រុមហ៊ុន, (២)-ការទទួលខុសត្រូវរបស់ម្ចាស់ភាគហ៊ុន និងអ្នកគ្រប់គ្រង, (៣)-កិច្ចដំណើរការ និងការគ្រប់គ្រង, (៤)-ការធានាបាននូវស្ថិរភាព និងនិរន្តរភាពរបស់ក្រុមហ៊ុន ឬសហគ្រាស និង (៥)-ការកំណត់របបពន្ធដារ។ ខុសពីក្រុមហ៊ុន, ការបង្កើតសហគ្រាសឯកបុគ្គលមិនទាមទារឱ្យមានការរៀបចំជាលក្ខន្តិក:នោះទេ។ ជាទូទៅ សហគ្រាសឯកបុគ្គលមិនមានបុគ្គលភាពគតិយុត្តដាច់ដោយឡែកពីម្ចាស់សហគ្រាសនោះទេដែលធ្វើឱ្យសហគ្រាសឯកបុគ្គលមិនមានបេតិកភ័ណ្ឌផ្ទាល់ដាច់ចេញពីបេតិកភ័ណ្ឌរបស់ម្ចាស់សហគ្រាសនោះទេ ហើយម្ចាស់សហគ្រាសទទួលខុសត្រូវដោយគ្មានកម្រិតចំពោះអាជីវកម្មរបស់សហគ្រាស។ ដោយឡែកក្រុមហ៊ុនជានីតិបុគ្គលដែលមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីម្ចាស់ភាគហ៊ុននីមួយៗដែលធ្វើឱ្យក្រុមហ៊ុនមានទ្រព្យសម្បត្តិ សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវដាច់ដោយឡែកពីម្ចាស់ភាគហ៊ុននីមួយៗ ហើយម្ចាស់ភាគហ៊ុនទទួលខុសត្រូវត្រឹមកម្រិតនៃភាគទុនដែលខ្លួនបានដាក់បញ្ចូលឱ្យទៅជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ លើកលែងតែចំពោះទម្រង់ក្រុមហ៊ុនដែលច្បាប់កំណត់ឱ្យម្ចាស់ភាគហ៊ុនត្រូវទទួលខុសត្រូវដោយគ្មានកម្រិត។ ក្នុងន័យនេះ ម្ចាស់បំណុលរបស់ក្រុមហ៊ុនមិនមែនជាម្ចាស់បំណុលរបស់ម្ចាស់ភាគហ៊ុននោះទេ ហេតុដូចនេះ ម្ចាស់បំណុលរបស់ក្រុមហ៊ុនមិនអាចទាមទារឬប្រកួតប្រជែងជាមួយម្ចាស់បំណុលផ្ទាល់របស់ម្ចាស់ភាគហ៊ុននោះទេ។ ពាក់ព័ន្ធនឹងកិច្ចដំណើរការ និងការគ្រប់គ្រង, ចំពោះសហគ្រាសឯកបុគ្គលគឺម្ចាស់ភាគហ៊ុនមានសិទ្ធិសេរីភាពពេញលេញក្នុងសម្រេចចិត្តដោយខ្លួនឯង។ ដោយឡែក ចំពោះក្រុមហ៊ុនច្បាប់បានកំណត់នូវរបបគតិយុត្តសម្រាប់ការគ្រប់គ្រងកិច្ចដំណើរការរបស់ក្រុមហ៊ុន ដោយការសម្រេចចិត្តនានា អាចត្រូវធ្វើឡើងដោយអភិបាល ក្រុមប្រឹក្សាភិបាល ឬមហាសន្និបាតម្ចាស់ភាគហ៊ុន។ ស្ថិរភាពនិងនិរន្តរភាពរបស់ក្រុមហ៊ុន អាចត្រូវបានធានានៅពេលមានការផ្ទេរភាគហ៊ុន តាមរយៈអនុប្បទានក្តីតាមរយៈសន្តតិកម្មក្តី។ ក្រុមហ៊ុនអាចមានដំណើរការជានិរន្តរ៍ ទោះបីជាមានម្ចាស់ភាគហ៊ុនណាម្នាក់បានទទួលមរណភាព ឬដកខ្លួនចេញពីក្រុមហ៊ុនក្តី។ ពាក់ព័ន្ធនឹងរបបពន្ធដារ, សហគ្រាសឯកបុគ្គល ត្រូវស្ថិតក្នុងរបបពន្ធលើប្រាក់ចំណូល ដោយហេតុថាបេតិកភ័ណ្ឌរបស់សហគ្រាសជាបេតិកភ័ណ្ឌរបស់ម្ចាស់សហគ្រាស ហើយប្រាក់ចំណេញរបស់សហគ្រាសឯកបុគ្គល ត្រូវគិតជាប្រាក់ចំណូលរបស់ម្ចាស់សហគ្រាស។ផ្ទុយទៅវិញក្រុមហ៊ុនត្រូវស្ថិតក្នុងរបបពន្ធលើប្រាក់ចំណេញ។ ប្រាក់ចំណេញរបស់ក្រុមហ៊ុន ត្រូវជាប់ពន្ធលើប្រាក់ចំណេញ រីឯភាគលាភដែលត្រូវបានបែងចែកឱ្យទៅម្ចាស់ភាគហ៊ុន ត្រូវចាត់ទុកជាប្រាក់ចំណូលរបស់ម្ចាស់ភាគហ៊ុន ដែលត្រូវជាប់ពន្ធលើប្រាក់ចំណូលដាច់ដោយឡែក ស្របតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។

1 .Dominique VIDAL, Droit des sociétés, LGDJ, Paris, 6e éd., 2008, p.83

2 .សហគ្រាសសាធារណៈ ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីលក្ខន្តិក:ទូទៅនៃសហគ្រាសសាធារណៈឆ្នាំ១៩៩៦ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦។

សហគ្រាសពាណិជ្ជកម្មនៅកម្ពុជា ត្រូវស្ថិតក្រោមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០២២[3]។ ផ្អែកតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥, ទម្រង់នៃសហគ្រាសពាណិជ្ជកម្ម មានតែ ២ ប៉ុណ្ណោះ គឺ ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន[4]។ ចំពោះសហគ្រាសឯកបុគ្គល មិនត្រូវបានកំណត់ថាជាទម្រង់មួយនៃសហគ្រាសពាណិជ្ជកម្មនោះទេ ដូច្នេះ ច្បាប់នេះមិនបានកំណត់អំពីរបបគតិយុត្តិនៃសហគ្រាសឯកបុគ្គលឡើយ។ ក្នុងន័យនេះ ពាក្យថាសហគ្រាសពាណិជ្ជកម្ម គឺសំដៅដល់ក្រុមហ៊ុនពាណិជ្ជកម្មតែប៉ុណ្ណោះ ពោលគឺ ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន។ ដោយឡែក ផ្អែកតាមច្បាប់វិសោធនកម្មឆ្នាំ២០២២, សហគ្រាសឯកបុគ្គល ត្រូវបានទទួលស្គាល់ និងកំណត់ថាជាទម្រង់មួយបន្ថែមទៀតនៃសហគ្រាសពាណិជ្ជកម្ម។ តើទម្រង់នីមួយៗនៃសហគ្រាសពាណិជ្ជកម្មទាំង ៣ រួមមាន **សហគ្រាសឯកបុគ្គល** (I), **ក្រុមហ៊ុនសហកម្មសិទ្ធិ** (II) និង **ក្រុមហ៊ុនមូលធន** (III) មានចរិកលក្ខណៈ និងរបបគតិយុត្តយ៉ាងដូចម្តេចខ្លះ?

I- សហគ្រាសឯកបុគ្គល

សហគ្រាសឯកបុគ្គលគឺជាសហគ្រាសដែលបង្កើតឡើងដោយរូបវន្តបុគ្គលតែម្នាក់ដែលជាម្ចាស់សហគ្រាស ហើយការទទួលខុសត្រូវរបស់ម្ចាស់សហគ្រាសគឺជាការទទួលខុសត្រូវគ្មានកម្រិត។ ម្ចាស់សហគ្រាស ទទួលខុសត្រូវដោយផ្ទាល់ចំពោះបំណុល និងកាតព្វកិច្ចទាំងអស់របស់សហគ្រាស។ សហគ្រាសឯកបុគ្គល ពុំមាននីតិបុគ្គលិកលក្ខណៈ និងបេតិកភ័ណ្ឌរបស់ខ្លួន ដាច់ដោយឡែកពីម្ចាស់សហគ្រាសនោះទេ។ ដូច្នេះ ម្ចាស់បំណុលរបស់សហគ្រាសក៏ជាម្ចាស់បំណុលផ្ទាល់របស់ម្ចាស់សហគ្រាសផងដែរ។ ម្ចាស់បំណុលអាចធ្វើការប្តឹងទាមទារបំណុលពីម្ចាស់សហគ្រាសចំពោះបំណុលរបស់សហគ្រាស ឬបំណុលផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាស។ គោលការណ៍ទាំងនេះ ត្រូវបានបញ្ជូលជាវិធានច្បាប់ដោយច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ ផ្អែកតាមមាត្រា ៨ស្នូននៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម,សហគ្រាសឯកបុគ្គលទោះបីជាបានចុះបញ្ជីពាណិជ្ជកម្ម ក៏ដោយគឺជាសហគ្រាសដែលត្រូវបានបង្កើតឡើងដោយរូបវន្តបុគ្គលតែម្នាក់ហើយ *"ទ្រព្យសម្បត្តិរបស់ម្ចាស់សហគ្រាសឯកបុគ្គលជាដើមទុនរបស់សហគ្រាសឯកបុគ្គល"*។ នៅក្នុងសហគ្រាសឯកបុគ្គល រាល់គណនី កិច្ចសន្យា ទ្រព្យសម្បត្តិ និងអាជ្ញាប័ណ្ណទាំងអស់ ត្រូវដាក់ឈ្មោះរបស់ម្ចាស់សហគ្រាស។ ម្ចាស់សហគ្រាសឯកបុគ្គលមានឯករាជ្យភាពពេញលេញក្នុងការគ្រប់គ្រង និងការសម្រេចចំពោះអាជីវកម្មរបស់សហគ្រាស។ ម្ចាស់សហគ្រាសឯកបុគ្គលគឺជាអ្នកមានសិទ្ធិលើប្រាក់ចំណេញទាំងអស់របស់សហគ្រាស។

សហគ្រាសឯកបុគ្គលភាគច្រើនត្រូវបានបង្កើតឡើងសម្រាប់អាជីវកម្មជាលក្ខណៈគ្រួសារ។ ជាទូទៅការបង្កើតសហគ្រាសឯកបុគ្គលនេះមានភាពឆាប់រហ័ស និងមិនភាពស្មុគស្មាញនោះទេ ដោយច្បាប់កំណត់នូវលក្ខខណ្ឌតិចតួចបំផុត។ ការបង្កើតសហគ្រាសឯកបុគ្គល មិនតម្រូវឱ្យមានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសទេ[5]។ ម្ចាស់សហគ្រាសឯកបុគ្គល គឺជាពាណិជ្ជករ។ សហគ្រាសឯកបុគ្គល អាចជាសហគ្រាសដែលចុះបញ្ជីពាណិជ្ជកម្ម និងសហគ្រាសដែលមិនបានចុះបញ្ជីពាណិជ្ជកម្ម។ មាត្រា ១២ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម កំណត់ថាពាណិជ្ជករដែលមានគ្រឹះស្ថានដើមរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជាមានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីនេះ លើកលែងតែពាណិជ្ជករដែលមិនជាប់ពន្ធលើប្រាក់ចំណេញ។ សហគ្រាសឯកបុគ្គលដែលស្ថិតក្នុងចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមានកាតព្វកិច្ចចុះក្នុងបញ្ជីពាណិជ្ជកម្ម។ ក្នុងន័យនេះសហគ្រាសឯកបុគ្គលដែលមិនបានជាប់ពន្ធលើប្រាក់ចំណេញឬមិនស្ថិតក្នុងចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទេ អាចមិនបាច់ចុះបញ្ជីពាណិជ្ជកម្មបាន។ ប៉ុន្តែសហគ្រាសនោះ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម-សេវាកម្មពីមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត[6]។ លិខិតអនុញ្ញាតនេះ មានសុពលភាព ១ឆ្នាំ និងអាចបន្តជាថ្មីបាន។ ក្រោយការចុះបញ្ជី ឬក្រោយពីទទួលបានលិខិតអនុញ្ញាតធ្វើអាជីវកម្ម-សេវាកម្ម,សហគ្រាសឯកបុគ្គលត្រូវគោរពតាមបទប្បញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម-សេវាកម្ម ជាអាទិ៍ ពាក់ព័ន្ធនឹងរបបពន្ធ និងការស្នើសុំអាជ្ញាប័ណ្ណផ្សេងៗតាមការកំណត់របស់បទប្បញ្ញត្តិគតិយុត្តជាធរមាន។សហគ្រាសឯកបុគ្គលដែលបានចុះបញ្ជី ត្រូវដាក់ស្លាកបញ្ជាក់នូវអត្តសញ្ញាណខ្លួនថាជា "សហគ្រាសឯកបុគ្គល" នៅខាងចុង។

3. ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១២២/០០៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២។

4. នៅមុនពេលដែលច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ ត្រូវបានអនុម័ត, មាត្រា ១៧ នៃច្បាប់ស្តីពីវិធានពាណិជ្ជ និងបញ្ជីពាណិជ្ជកម្ម បានចែងថា "ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម គ្រប់ក្រុមហ៊ុនដែលមានសកម្មភាពពាណិជ្ជកម្ម ទោះបីបែបបទនៃការបង្កើត និងថេរវេលារបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ"។ ក្រុមហ៊ុនពាណិជ្ជកម្ម អាចមានទម្រង់ផ្សេងៗជាច្រើន ដែលក្រុមហ៊ុនខ្លះមានទម្រង់តាមលំនាំក្រុមហ៊ុនក្នុងប្រព័ន្ធច្បាប់បារាំង, ក្រុមហ៊ុនខ្លះមានទម្រង់តាមលំនាំក្រុមហ៊ុនក្នុងប្រព័ន្ធច្បាប់ Common Law។ ប៉ុន្តែ ក្រោយពេលដែលច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ ត្រូវបានអនុម័ត, ក្រុមហ៊ុនពាណិជ្ជកម្ម រួមមាន ក្រុមហ៊ុនមូលធន និង ក្រុមហ៊ុនសហកម្មសិទ្ធិ។

5. ក្រសួងពាណិជ្ជកម្ម, សៀវភៅណែនាំសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និងការប្រកបអាជីវកម្មអនុលោមតាមច្បាប់, ទំព័រ ៧-៨។

6. ប្រកាសលេខ ០៤៥ ពណ.កប.ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីនីតិវិធីគ្រប់គ្រងសកម្មភាពអាជីវកម្ម-សេវាកម្ម ពាណិជ្ជកម្មក្នុងប្រទេសរបស់នាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស។

ការកំណត់របបពន្ធសម្រាប់សហគ្រាសឯកបុគ្គលគឺអាស្រ័យទៅតាមប្រភេទសហគ្រាសឯកបុគ្គលនោះ ដែលអាចជាសហគ្រាសធុនមីក្រូ, សហគ្រាសធុនតូច, សហគ្រាសធុនមធ្យម ឬសហគ្រាសធុនធំ។ ការបែងចែកនេះ ត្រូវធ្វើឡើងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួន ២ គឺ៖ ចំនួនកម្មករ-និយោជិតដែលបម្រើការនៅក្នុងសហគ្រាស និង ផលរបរប្រចាំ ឬទំហំទ្រព្យសកម្មរបស់សហគ្រាស។ សហគ្រាសធុនមីក្រូ សំដៅដល់សហគ្រាសដែលមានផលរបរប្រចាំឆ្នាំក្រោម ២៥០លានរៀល ឬទ្រព្យសកម្មក្រោម ២០០លានរៀល ឬមានកម្មករ-និយោជិតចាប់ពី ១នាក់ ដល់ ៤ នាក់។ សហគ្រាសធុនតូច ជាសហគ្រាសដែលមានផលរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀល ដល់ ១០០០លានរៀល ឬមានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ២០០លានរៀល ដល់ ១០០០ លានរៀល ឬមានកម្មករ-និយោជិតចាប់ពី ៥នាក់ ទៅ ៤៩នាក់។ សហគ្រាសធុនតូចត្រូវចាត់ទុកជាអ្នកជាប់ពន្ធតូច។ដោយឡែកសហគ្រាសធុនមធ្យមជាសហគ្រាសដែលមានផលរបបប្រចាំឆ្នាំចាប់ពី ៧០០ លានរៀល ដល់ ៤០០០ លានរៀល ឬសហគ្រាសដទៃទៀតដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធមធ្យម ឬមានចំនួនកម្មករ-និយោជិតចាប់ពី ៥០ នាក់ ដល់ ១០០ នាក់។ សហគ្រាសធុនមធ្យម ត្រូវចាត់ទុកជាអ្នកជាប់ពន្ធមធ្យម។ សហគ្រាសធុនធំ ជាសហគ្រាសដែលមានផលរបរប្រចាំឆ្នាំចាប់ពី ៤០០០លានរៀល ឬមានកម្មករ-និយោជិតចាប់ពី ១០០នាក់ឡើងទៅ។

សហគ្រាសឯកបុគ្គលអាចត្រូវបានរំលាយទៅវិញដោយមូលហេតុការស្ម័គ្រចិត្តរំលាយ មរណភាពរបស់ម្ចាស់សហគ្រាស ឬដោយសេចក្តីសម្រេចរបស់តុលាការ។

II- ក្រុមហ៊ុនសហកម្មសិទ្ធិ

ក្រុមហ៊ុនសហកម្មសិទ្ធិ ជាប្រភេទក្រុមហ៊ុនដែលយកការរាប់អានបុគ្គលជាធំ[7] (intuitus personae) មានន័យថា ហានៈ ឬលក្ខណៈសម្បត្តិរបស់បុគ្គលដែលជាគូភាគីនៃកិច្ចសន្យាក្រុមហ៊ុនត្រូវបានគិតគូរយកចិត្តទុកដាក់ជាសំខាន់មុននឹងសម្រេចចុះកិច្ចសន្យាក្រុមហ៊ុន។ ក្រុមហ៊ុននេះ មិនផ្តោតសំខាន់ទៅលើមូលធននោះទេ (intuitus pecuniae) និងជាប្រភេទក្រុមហ៊ុនទទួលខុសត្រូវគ្មានកម្រិត។ ក្រុមហ៊ុនសហកម្មសិទ្ធិ តែងត្រូវបានបង្កើតឡើងសម្រាប់សកម្មភាពអាជីវកម្មដែលមានលក្ខណៈវិជ្ជាជីវៈ ឬជាការផ្តល់សេវាកម្ម ជាអាទិ៍ ក្រុមហ៊ុនមេធាវី, ក្រុមហ៊ុនគណនេយ្យករ ឬ

7. សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, សន្ធានុក្រមបារាំ-ខ្មែរនៃពាក្យច្បាប់, COLLECTION ETAT DE DROIT, PRESSES UNIVERSITAIRE DU CAMBODGE, ២០០៥, ទំព័រ ១៦១។

ក្រុមហ៊ុនសវនកម្មជាដើម។ ក្រុមហ៊ុនសហកម្មសិទ្ធិមាន ២ ទម្រង់គឺ៖ **(១)-ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ** និង **(២)-ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត**។

១- ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម បានឱ្យនិយមន័យ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅថាជា *"កិច្ចសន្យារវាងបុគ្គលពីរ ឬច្រើនដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬសកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបពាណិជ្ជកម្មរួមក្នុងគោលបំណងរកប្រាក់ចំណេញ"*។ និយមន័យនេះមិនបានឆ្លុះបញ្ចាំងឱ្យឃើញពីចរិតលក្ខណៈគតិយុត្តរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ប៉ុន្តែជានិយមន័យទូទៅនៃក្រុមហ៊ុនតែប៉ុណ្ណោះ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបង្កើតឡើងដោយកិច្ចសន្យាដែលអាចធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។ សមាជិកហ៊ុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវហៅថាជា *សហកម្មសិទ្ធិករទូទៅ*។ សហកម្មសិទ្ធិករទូទៅអាចដាក់ភាគទុនជាសាច់ប្រាក់ ជាវត្ថុ និងជាសេវា។ ភាគទុនជាសេវានេះ អាចជាសេវាពីមុនដែលបានផ្តល់រួចមកហើយយ៉ាងពិតប្រាកដ ឬជាសេវាដែលនឹងត្រូវផ្តល់នាពេលអនាគត។ ភាគទុនជាសេវានេះ អាចជាចំណេះដឹង ឬជាសកម្មភាពផ្សេងៗ ប៉ុន្តែ ភាគទុនជាសេវានេះ មិនត្រូវរាប់បញ្ចូលនូវការប្រើប្រាស់ឥទ្ធិពលដែលទទួលបានពីមុខងារជាមន្ត្រីសាធារណៈនោះឡើយ។ ការគណនាដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មិនត្រូវរាប់បញ្ចូលនូវភាគទុនជាសេវានោះទេ។ ចំពោះការដាក់ទុនជាសេវាសហកម្មសិទ្ធិករទូទៅនោះត្រូវជាប់កាតព្វកិច្ចរហូតដរាបណាបុគ្គលនោះនៅតែជាសហកម្មសិទ្ធិទូទៅ។ ជាតម្លៃតបស្នងនៃភាគទុនដែលបានដាក់ចូលក្នុងក្រុមហ៊ុន សហកម្មសិទ្ធិករទូទៅ ទទួលបានមកវិញនូវ ***"អត្ថប្រយោជន៍នៅក្នុងក្រុមហ៊ុន[8]"*** (ដូច ភាគហ៊ុន នៅក្នុងក្រុមហ៊ុនមូលធន ប៉ុន្តែសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិ ច្បាប់ហៅថាជា អត្ថប្រយោជន៍នៅក្នុងក្រុមហ៊ុន)។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ជាក្រុមហ៊ុនទទួលខុសត្រូវគ្មានកម្រិត។ សហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាដោយគ្មានកម្រិតចំពោះបំណុល និងកាតព្វកិច្ចទាំងអស់របស់ក្រុមហ៊ុន។ ប៉ុន្តែ ម្ចាស់បំណុលត្រូវទាមទារការអនុវត្តកាតព្វកិច្ចបំណុលពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅសិន មុននឹងទាមទារពីសហកម្មសិទ្ធិករទូទៅ[9]។ ក្នុងករណីដែលបុគ្គលណាបានចូលជាសហកម្មសិទ្ធិករទូទៅនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបាន

8. មាត្រា១៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥។
9. មាត្រា៤២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥។

កើតរួចហើយ, សហកម្មសិទ្ធិករថ្មីនេះ ត្រូវទទួលខុសត្រូវចំពោះបំណុលទាំងអស់របស់ក្រុមហ៊ុន ដែលកើតឡើងមុនពេលដែលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅដូចសហកម្មសិទ្ធិករទូទៅ នៅពេលដែលបំណុលនោះបានកើតឡើងដែរ។ ប៉ុន្តែ បំណុលទាំងឡាយដែលបានកើតឡើងមុនពេលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅ អាចត្រូវបានចេញសងដោយទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ហើយមិនត្រូវបានចេញសងដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់បុគ្គលនោះឡើយ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះជាលាយលក្ខណ៍អក្សរ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ជាប្រភេទក្រុមហ៊ុនដែលយកការរាប់អានបុគ្គលជាធំ។ ដោយសារការយកចិត្តទុកដាក់លើការរ៉ាប់អានបុគ្គល ឬលើលក្ខណៈសម្បត្តិ និងជំនឿទុកចិត្តលើបុគ្គលជាសហកម្មសិទ្ធិករទូទៅជាធំនេះ ទើបកិច្ចដំណើរការ និងការគ្រប់គ្រងក្រុមហ៊ុននេះ ត្រូវអនុវត្តតាមគោលការណ៍ ដូចខាងក្រោម៖

-គ្មានបុគ្គលណាម្នាក់អាចក្លាយជាសហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដោយគ្មានការយល់ព្រមជាឯកច្ឆន្ទពីគ្រប់សហកម្មសិទ្ធិករទូទៅនោះទេ។សហកម្មសិទ្ធិករទូទៅ មិនអាចផ្ទេរអត្ថប្រយោជន៍របស់ខ្លួននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទៅឱ្យបុគ្គលផ្សេងបានឡើយ ប្រសិនបើគ្មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់។

- ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនអាចបោះផ្សាយលក់មូលបត្រជាសាធារណៈបានឡើយ។ ការហាមឃាត់នេះមានលក្ខណៈដាច់ខាត ហើយការព្រមព្រៀងផ្សេងពីនេះត្រូវចាត់ទុកជាមោឃៈ[10]។

- ការបាត់បង់សិទ្ធិជាសហកម្មសិទ្ធិករទូទៅរបស់សមាជិកហ៊ុនណាម្នាក់ នាំឱ្យមានការរំលាយក្រុមហ៊ុនជាស្វ័យប្រវត្តិ លើកលែងតែមានការចែងផ្សេងនៅក្នុងកិច្ចសន្យា ឬមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅផ្សេងទៀតទាំងអស់។ ប៉ុន្តែ ចំពោះការដកខ្លួនចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបង្កើតឡើងដោយមានអាយុកាលមិនកំណត់ ឬករណីកិច្ចសន្យាមានចែងបម្រុងទុកនូវសិទ្ធិដកខ្លួន, ការដកខ្លួនចេញពីក្រុមហ៊ុនអាចធ្វើទៅបានតាមការជូនដំណឹងពីការដកខ្លួនដោយសុទ្ធចិត្ត ហើយមិនធ្វើឱ្យក្រុមហ៊ុនត្រូវរំលាយនោះទេ។ ដូចគ្នាផងដែរចំពោះករណីដែលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានបង្កើតឡើងដោយមានអាយុកាលកំណត់ ការដកខ្លួនចេញពីក្រុមហ៊ុន អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីមតិភាគច្រើនដាច់ខាតរបស់សហកម្មសិទ្ធិករទូទៅទាំងអស់ ឬលុះត្រាតែកិច្ចសន្យាក្រុមហ៊ុនចែងផ្សេងពីនេះ។

10. មាត្រា៤៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥។

- សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវបានចាត់ទុកថាមានសិទ្ធិគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុន[11] និងជាភ្នាក់ងារ[12] របស់ក្រុមហ៊ុននៅក្នុងទំនាក់ទំនងជាមួយតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយគ្នាដោយស្មោះត្រង់។ សហកម្មសិទ្ធិករទូទៅ មិនអាចទទួលបានប្រាក់បៀវត្សពីការធ្វើពាណិជ្ជកិច្ច ក្នុងក្រុមហ៊ុនបានឡើយ[13]។ រាល់សកម្មភាពដែលត្រូវបានធ្វើឡើងដោយសហកម្មសិទ្ធិករទូទៅណាម្នាក់ ដែលទាក់ទងនឹងសកម្មភាពរួមរបស់ក្រុមហ៊ុន មានន័យថាស្ថិតក្នុងវង្វង់អាជីវកម្មរបស់ក្រុមហ៊ុនត្រូវជាប់កាតព្វកិច្ចទៅនឹងសហកម្មសិទ្ធិករទូទៅផ្សេងទៀត។ សហកម្មសិទ្ធិករទូទៅទាំងឡាយ មិនអាចបដិសេធកាតព្វកិច្ចនេះបានឡើយ។ រាល់ការព្រមព្រៀងណាដែលផ្ទុយពីនេះត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាព។

- បុគ្គលណាម្នាក់ដែលធ្វើឱ្យបុគ្គលផ្សេងទៀតជឿទុកចិត្តដោយផ្ទាល់ឬដោយប្រយោលថាខ្លួនជាសហកម្មសិទ្ធិករទូទៅ ប៉ុន្តែ ការពិតបុគ្គលនោះមិនមែនជាសហកម្មសិទ្ធិករទូទៅទេ ត្រូវទទួលខុសត្រូវចំពោះតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយដោយស្មោះត្រង់ ដូចសហកម្មសិទ្ធិករទូទៅពិតៗដែរ[14] ។

- ជាផ្លូវនឹងការត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាសហកម្មសិទ្ធិករទូទៅទាំងអស់ ដោយគ្មានកម្រិតចំពោះបំណុល និងកាតព្វកិច្ចទាំងអស់របស់ក្រុមហ៊ុន, ជាគោលការណ៍សហកម្មសិទ្ធិករទូទៅមានសិទ្ធិស្មើគ្នាក្នុងការបោះឆ្នោត។ រាល់ការសម្រេចសេចក្តីត្រូវធ្វើឡើងដោយការបោះឆ្នោតតាមសំឡេងភាគច្រើនដោយប្រៀបរបស់សហកម្មសិទ្ធិករទូទៅដោយមិនគិតតម្លៃអត្ថប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅម្នាក់ៗនៅក្នុងក្រុមហ៊ុននោះទេ (សហកម្មសិទ្ធិករទូទៅម្នាក់មាន ១ សម្លេងដូចគ្នា)។ ទន្ទឹមនេះ សមាមាត្រនៃផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅម្នាក់ៗនៅក្នុងទ្រព្យ សម្បត្តិ ប្រាក់ចំណេញ និងការខាតបង់ *គឺស្មើគ្នា* លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យាក្រុមហ៊ុន។

២- ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

មាត្រា ៦៤ នៃច្បាប់សហគ្រាសពាណិជ្ជកម្ម បានកំណត់និយមន័យក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ថា *"ជាកិច្ចសន្យាដែលធ្វើឡើងរវាងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ដែលមាន*

11. មាត្រា៣៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥។
12. មាត្រា៤០ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥។
13. មាត្រា២៦ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥។
14. មាត្រា៤៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥។

ផ្ទេរអត្ថប្រយោជន៍របស់រួចហើយក៏នៅតែជាប់កាតព្វកិច្ចដែលកើតមានឡើងនៅពេលដែលខ្លួននៅជាសហកម្មសិទ្ធិករមានកម្រិតដដែល[16] ។

សហកម្មសិទ្ធិករមានកម្រិត អាចផ្ទេរអត្ថប្រយោជន៍របស់ខ្លួនបាន ដោយពុំចាំបាច់មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករដទៃទៀតឡើយ។ សហកម្មសិទ្ធិករមានកម្រិត អាចដកចំណែកណាមួយនៃភាគទុនរបស់ខ្លួនបាន បើមានការយល់ព្រមពីមតិភាគច្រើនដាច់ខាតនៃសហកម្មសិទ្ធិករទាំងអស់ក្នុងលក្ខខណ្ឌដែលក្រោយការដកនោះទ្រព្យសម្បត្តិដែលនៅសល់នៅក្នុងក្រុមហ៊ុនមានគ្រប់គ្រាន់ដើម្បីដោះបំណុលរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ។

III- ក្រុមហ៊ុនមូលធន

ក្រុមហ៊ុនមូលធន គឺជាប្រភេទក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត។ ក្រុមហ៊ុនមូលធនមានទីតិបុគ្គលិកលក្ខណៈ និងបេតិកភ័ណ្ឌរបស់ខ្លួនដាច់ដោយឡែកពីសមាជិកភាគហ៊ុនម្នាក់ៗ។ ក្រុមហ៊ុននេះ ទទួលខុសត្រូវត្រឹមកម្រិតនៃទ្រព្យសកម្មរបស់ក្រុមហ៊ុន ហើយម្ចាស់ភាគហ៊ុនម្នាក់ៗទទួលខុសត្រូវត្រឹមកម្រិតនៃភាគទុនដែលបានដាក់បញ្ចូលទៅក្នុងក្រុមហ៊ុនតែប៉ុណ្ណោះ លើកលែងតែម្ចាស់ភាគហ៊ុននោះជាអ្នកធានាបំណុលរបស់ក្រុមហ៊ុន។ ផ្អែកតាមច្បាប់ជាធរមាន, ក្រុមហ៊ុនមូលធនមាន ៣ ទម្រង់គឺ៖ **(១)-ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត, (២)-សហគ្រាសឯកបុគ្គលទទួលខុសត្រូវមាន កម្រិត** និង **(៣)-ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**។ វិធានគតិយុត្តដែលត្រូវអនុវត្តចំពោះក្រុមហ៊ុនមូលធននេះ មានកម្រិតខុសគ្នាទៅតាមទម្រង់នៃក្រុមហ៊ុនមូលធននីមួយៗ។ ជាគោលការណ៍ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវស្ថិតនៅក្រោមវិធានដែលមានលក្ខណៈតឹងរឹងជាងវិធានដែលត្រូវអនុវត្តចំពោះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត។

១ - ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុននេះ ជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលមានសមាជិកភាគហ៊ុនពី ២ នាក់ទៅ៣០នាក់ប៉ុណ្ណោះ។ ក្នុងករណីដែលសមាជិកភាគហ៊ុនមានចំនួនច្រើនជាង ៣០ នាក់, ក្រុមហ៊ុនត្រូវបន្តយចំនួនសមាជិកភាគហ៊ុន ឬត្រូវកែប្រែលក្ខន្តិកៈនិងបម្លែទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតវិញ។ច្បាប់ជាធរមានមិនបានកំណត់ពីពេលវេលាសម្រាប់ឱ្យក្រុមហ៊ុនត្រូវធ្វើការកែប្រែ

16. មាត្រា៨៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០០៥។

ទម្រង់ក្រុមហ៊ុនក្នុងករណីខាងលើនោះទេហើយក៏មិនបានកំណត់អំពីផលវិបាកគតិយុត្តក្នុងករណីដែលមិនមានការផ្លាស់ប្តូរទម្រង់ក្រុមហ៊ុននេះដែរ។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនអាចត្រូវបានបង្កើតឡើងសម្រាប់ធ្វើអាជីវកម្មធនាគារ ក្រុមហ៊ុនឥណទាន និងក្រុមហ៊ុនធានារ៉ាប់រងបានឡើយ។ ក្នុងការអនុវត្តជាក់ស្តែង ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនេះ គឺជាទម្រង់ក្រុមហ៊ុនដែលពេញនិយមបំផុត ជាពិសេសសម្រាប់សហគ្រាសធុនតូច និងមធ្យម។

នៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ម្ចាស់ភាគហ៊ុនអាចដាក់ភាគទុនជាប្រាក់ ភាគទុនជាទ្រព្យ និងភាគទុនជាសេវា។ មិនខុសពីក្រុមហ៊ុនសហកម្មសិទ្ធិ,ភាគទុនជាសេវាមិនត្រូវគិតសម្រាប់គណនាដើមទុនរបស់ក្រុមហ៊ុននោះទេ។ ផ្អែកតាមច្បាប់សហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥ ក្នុងករណីដែលលក្ខន្តិកៈមិនបានចែងនូវចំនួន និងតម្លៃនៃប័ណ្ណភាគហ៊ុន ក្រុមហ៊ុនត្រូវបោះលក់យ៉ាងតិចបំផុត១០០ភាគហ៊ុនដែលមានតម្លៃចារឹកលើប័ណ្ណមិនតិចជាងបួនពាន់រៀលក្នុងមួយហ៊ុន។ មានន័យថា ដើមទុនអប្បរមារបស់ក្រុមហ៊ុន គឺមានចំនួន ៤ លានរៀល។ ប៉ុន្តែ លក្ខខណ្ឌដើមទុនអប្បរមានេះ ត្រូវបានលុបចោលដោយច្បាប់វិសោធនកម្មឆ្នាំ ២០២២ ស្របតាមការវិវត្តជាសកល។ ការកំណត់ទំហំដើមទុនអប្បរមា អាចជាឧបសគ្គដល់ការចុះបញ្ជីបង្កើតក្រុមហ៊ុនជាផ្លូវការ ហើយការយកដើមទុនអប្បរមា ដើម្បីធ្វើជាទ្រព្យធានាបំណុលរបស់ក្រុមហ៊ុនក៏លែងសូវមានប្រសិទ្ធភាពដែរ ដោយហេតុថាលើការជាក់ស្តែង ចំពោះក្រុមហ៊ុនដែលមានសក្តានុពល ម្ចាស់បំណុលអាចផ្តល់ហិរញ្ញប្បទានដល់ក្រុមហ៊ុនដោយមិនគិតពីទំហំដើមទុនរបស់ក្រុមហ៊ុននោះទេ ហើយតម្លៃនៃដើមទុនក៏មិនអាចធន់ឈ្មមនឹងទំហំនៃបំណុលផងដែរ។

ជាតម្លៃតបស្នងនឹងភាគទុនដែលបានដាក់បញ្ចូលទៅក្នុងក្រុមហ៊ុន ម្ចាស់ភាគហ៊ុនទទួលបាននូវចំណែកភាគហ៊ុនដែលផ្តល់ឱ្យម្ចាស់ភាគហ៊ុននូវសិទ្ធិបោះឆ្នោត, សិទ្ធិទទួលបានភាគលាភទៅតាមសមាមាត្រនៃចំណែកភាគហ៊ុនរបស់ខ្លួនឬទៅតាមការព្រមព្រៀងផ្សេងពីនេះ,សិទ្ធិទទួលបានចំណែកទ្រព្យសកម្មនៅសល់ក្រោយការជម្រះបញ្ជី និងសិទ្ធិផ្សេងទៀត ជាអាទិ៍ សិទ្ធិទទួលបានព័ត៌មាន, សិទ្ធិដេញដោលពីការគ្រប់គ្រងក្រុមហ៊ុន។ ម្ចាស់ភាគហ៊ុនទទួលខុសត្រូវត្រឹមកម្រិតនៃភាគទុនដែលខ្លួនបានដាក់បញ្ចូលទៅក្នុងក្រុមហ៊ុនតែប៉ុណ្ណោះ។ ម្ចាស់ភាគហ៊ុន ដែលមិនមានបំណងបង្ហាញអត្តសញ្ញាណនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន អាចតែងតាំងអ្នកតំណាងឱ្យឈរឈ្មោះជំនួសបាន។ ការតែងតាំងអ្នកតំណាងត្រូវធ្វើឡើងតាមរយៈកិច្ចសន្យារវាងម្ចាស់ភាគហ៊ុននិងអ្នកតំណាងដែលជារូបវន្តបុគ្គល ឬនីតិបុគ្គល។ កិច្ចសន្យានេះ ហៅថាជា *កិច្ចសន្យាតំណាងម្ចាស់ភាគហ៊ុន*។ ព័ត៌មាន

អំពីអត្តសញ្ញាណរបស់ម្ចាស់ភាគហ៊ុន និងកិច្ចសន្យាតំណាងម្ចាស់ភាគហ៊ុន ត្រូវតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម។

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនត្រូវបានអនុញ្ញាតឱ្យលក់ភាគហ៊ុនជាសាធារណៈបានឡើយ ប៉ុន្តែអាចអនុញ្ញាតឱ្យធ្វើអនុប្បទានទៅសមាជិកភាគហ៊ុនសមាជិកគ្រួសារ និងអ្នកគ្រប់គ្រងបាន។ ទោះបីក្រុមហ៊ុននេះជាក្រុមហ៊ុនមូលធនក៏ដោយ ប៉ុន្តែ ក្រុមហ៊ុននេះនៅមានការយកចិត្តទុកដាក់ខ្ពស់លើការរាប់អានបុគ្គល(intuitus personiae)[17] មានន័យថាលើហានៈនិងលក្ខណៈសម្បត្តិរបស់បុគ្គលដែលជាម្ចាស់ភាគហ៊ុន ជាជាងទុនវិនិយោគរបស់បុគ្គលនោះ។ ជាគោលការណ៍ម្ចាស់ភាគហ៊ុនមិនមានសិទ្ធិក្នុងការធ្វើអនុប្បទានភាគហ៊ុនរបស់ខ្លួនឱ្យទៅតតិយជនបានដោយសេរីនោះទេ។ ការធ្វើអនុប្បទានភាគហ៊ុនឱ្យទៅតតិយជន ត្រូវបានការយល់ព្រមពីម្ចាស់ភាគហ៊ុនផ្សេងទៀតតាមសំឡេងភាគច្រើន។ ច្បាប់អនុញ្ញាតឱ្យក្រុមហ៊ុន ឬម្ចាស់ភាគហ៊ុនព្រមព្រៀងគ្នាលើការរឹតត្បិតការផ្ទេរភាគហ៊ុនទៅឱ្យតតិយជនបាន។ការរឹតត្បិតនេះអាចត្រូវបានកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬកិច្ចព្រមព្រៀងរបស់សមាជិកភាគហ៊ុន។ ប៉ុន្តែ ការរឹតត្បិតនេះមិនអាចឈានដល់ការហាមមិនឱ្យមានការធ្វើអនុប្បទានភាគហ៊ុននោះឡើយ។ ក្នុងករណីដែលក្រុមហ៊ុនឬម្ចាស់ភាគហ៊ុនផ្សេងទៀតមិនប្រើប្រាស់សិទ្ធិទិញមុនរបស់ខ្លួននោះទេម្ចាស់ភាគហ៊ុនដែលមានបំណងលក់ភាគហ៊ុន អាចលក់ភាគហ៊ុនរបស់ខ្លួនឱ្យទៅតតិយជនបាន។ ទោះបីជាក្រុមហ៊ុន មិនអាចបោះផ្សាយមូលបត្រជាភាគហ៊ុនបាន ប៉ុន្តែ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក៏អាចក្លាយជានីតិបុគ្គលប្រតិស្រុតដើម្បីបោះផ្សាយលក់មូលបត្រផ្សេងទៀតដូចជាមូលបត្របំណុលជាដើម ដោយអនុលោមតាមបទប្បញ្ញត្តិគតិយុត្តក្នុងវិស័យមូលបត្រមហាជន។

ក្រុមហ៊ុននេះ ត្រូវបង្កើតឡើងដោយការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងត្រូវមានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ព្រមទាំងភ្ជាប់ជាមួយបែបបទពន្ធដារ ឬបែបបទច្បាប់ការងារផងដែរ។ នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុន កើតមាននៅកាលបរិច្ឆេទនៃការចុះបញ្ជីពាណិជ្ជកម្មរួច។ តាមរយៈការចុះបញ្ជីពាណិជ្ជកម្មនេះ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតទទួលបានបុគ្គលភាពគតិយុត្ត ដោយអាចមាន នាមករណ៍ សញ្ជាតិ ទ្រព្យសម្បត្តិ ព្រមជាមួយនឹងសមត្ថភាព សិទ្ធិ កាតព្វកិច្ច និងបុព្វសិទ្ធិដូចរូបវន្តបុគ្គលផងដែរ ហើយអាចធ្វើសកម្មភាពអាជីវកម្មរបស់ខ្លួននៅទូទាំងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស ប្រសិនបើរដ្ឋនោះអនុញ្ញាត។

17. Dominique VIDAL, Droit des sociétés, LGDJ, Paris, 6e éd., 2008, p.449

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវគ្រប់គ្រងដោយអភិបាល ឬអ្នកគ្រប់គ្រងក្រុមហ៊ុន។ ក្រុមហ៊ុនត្រូវមានអភិបាលម្នាក់ ឬច្រើននាក់។ អភិបាលក្រុមហ៊ុន ឬអ្នកគ្រប់គ្រងក្រុមហ៊ុន មិនចាំបាច់ត្រូវជាម្ចាស់ភាគហ៊ុនទេ។ អភិបាលក្រុមហ៊ុន ត្រូវបោះឆ្នោតជ្រើសរើសដោយម្ចាស់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតដោយសេចក្តីសម្រេចសាមញ្ញមានន័យថាដោយសម្លេងភាគច្រើនដាច់ខាត។ អភិបាលអាចត្រូវបានដកហូតចេញពីមុខតំណែងបានដោយសំឡេងភាគច្រើនដាច់ខាតនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត ទោះជាមាន ឬគ្មានមូលហេតុក៏ដោយ។ អភិបាល ឬអ្នកគ្រប់គ្រងក្រុមហ៊ុន គឺជាអ្នកតំណាងស្របច្បាប់របស់ក្រុមហ៊ុន ហើយរាល់សកម្មភាពរបស់អភិបាល ឬអ្នក គ្រប់គ្រងក្រុមហ៊ុនដែលធ្វើឡើងក្នុងនាមក្រុមហ៊ុន មានអានុភាពចងជាកាតព្វកិច្ចចំពោះក្រុមហ៊ុន។ រាល់លិខិតស្នាម ឬកិច្ចសន្យាដែលបានធ្វើក្នុងនាមក្រុមហ៊ុនដោយអភិបាលម្នាក់ ឬអ្នកគ្រប់គ្រងម្នាក់ ឬលេខាធិការរបស់ក្រុមហ៊ុនម្នាក់ មានសុពលភាព ទោះបីជាគ្មានត្រាសម្គាល់របស់ក្រុមហ៊ុនបោះភ្ជាប់ទៅលើឯកសារទាំងនោះក៏ដោយ។ ក្រុមហ៊ុន ឬបុគ្គលដែលធានាកាតព្វកិច្ចរបស់ក្រុមហ៊ុនមិនអាចលើកយកករណីដែលអភិបាលមិនត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្តនិងប្រតិបត្តិភារកិច្ចដែលជាទម្លាប់ធ្វើពាណិជ្ជកម្មរបស់ក្រុមហ៊ុន ដើម្បីចៀសវាងពីកាតព្វកិច្ចចំពោះតតិយជនសុចរិតបានឡើយ។តតិយជនដែលមិនសុចរិតគឺជាតតិយជនដែលបានស្គាល់ឬបានដឹងនូវការរឹតត្បិតនោះ ដោយសារតួនាទីរបស់ខ្លួន ឬដោយសារទំនាក់ទំនងរបស់ខ្លួននៅក្នុងក្រុមហ៊ុន។

២ - សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត គឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលមានសមាជិកភាគហ៊ុនតែម្នាក់(ម្ចាស់ភាគហ៊ុនទោល)។ សហគ្រាសនេះអាចត្រូវបានបង្កើតឡើងពីដំបូងដោយពាណិជ្ជកម្មតែម្នាក់ឯងឬត្រូវបង្កើតឡើងតាមរយៈការប្តូរមកពីទម្រង់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនៅពេលដែលសមាជិកហ៊ុនរបស់ក្រុមហ៊ុននេះនៅសល់តែម្នាក់។ ខុសពីសហគ្រាសឯកបុគ្គលទូទៅ, សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតនេះ គឺជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ដែលមាននីតិបុគ្គលិកលក្ខណៈ និងបេតិកភ័ណ្ឌរបស់ខ្លួនដាច់ដោយឡែកពីម្ចាស់ភាគហ៊ុន។ សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតនេះអាចត្រូវបានបង្កើតឡើងដោយពាណិជ្ជករជារូបវន្តបុគ្គល ឬជានីតិបុគ្គល។ ការទទួលស្គាល់នូវសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតនេះ ថាជាក្រុមហ៊ុនមូលធន គឺបានធ្វើឱ្យប៉ះពាល់ដល់និយមន័យនៃក្រុមហ៊ុន ដែលតែងត្រូវបានកំណត់ថាជា កិច្ចសន្យារវាងបុគ្គលពីរនាក់ ឬច្រើននាក់

ដែលជាក់ទុនរួមគ្នា ដើម្បីប្រកបពាណិជ្ជកិច្ចរួម ក្នុងគោលបំណងរកប្រាក់ចំណេញ។ ក្រុមហ៊ុនគឺជាកិច្ចសន្យា ហើយទាមទារឱ្យមានការចូលរួមចំណែកក្នុងការចំណេញខាត។ តើសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតដែលបង្កើតឡើងដោយបុគ្គលតែម្នាក់អាចជាកិច្ចសន្យាបានដែរឬទេ?បើមានម្ចាស់ភាគហ៊ុនតែម្នាក់តើអាចមានការចូលរួមចំណែកក្នុងការចំណេញខាតរបស់ក្រុមហ៊ុនដែរឬទេ?

ការបង្កើតនូវទម្រង់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតនេះគឺជាបច្ចេកទេសគតិយុត្តមួយដែលអនុញ្ញាតឱ្យម្ចាស់សហគ្រាសអាចដំណើរការអាជីវកម្មសហគ្រាសរបស់ខ្លួនក្នុងទម្រង់ជាក្រុមហ៊ុន ដើម្បីកម្រិតការទទួលខុសត្រូវរបស់ម្ចាស់ហ៊ុនត្រឹមកម្រិតនៃដើមទុនរបស់ក្រុមហ៊ុន និងធានាបាននូវស្ថិរភាព និងនិរន្តរភាពរបស់សហគ្រាស។ ប៉ុន្តែ លើការជាក់ស្តែងម្ចាស់ភាគហ៊ុនទោល តែងត្រូវបានទាមទារឱ្យធ្វើជាអ្នកធានាបំណុលរបស់ក្រុមហ៊ុន ដែលធ្វើឱ្យម្ចាស់សហគ្រាសនៅតែត្រូវទទួលខុសត្រូវចំពោះបំណុលរបស់ក្រុមហ៊ុនដដែល។ដោយឡែកក្នុងករណីដែលម្ចាស់ភាគហ៊ុនទោលទទួលមរណភាព, សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតនឹងមិនត្រូវរំលាយ ដោយស្វ័យប្រវត្តិនោះទេ។ ភាគហ៊ុនរបស់ម្ចាស់ភាគហ៊ុនទោលអាចផ្ទេរទៅឱ្យទាយាទ ឬបុគ្គលផ្សេង ហើយនិរន្តរភាពរបស់ក្រុមហ៊ុនត្រូវបានធានា។ នៅពេលដែលអាជីវកម្មរបស់សហគ្រាសមានការរីកចម្រើន,ម្ចាស់ភាគហ៊ុនទោលក៏អាចពង្រីកក្រុមហ៊ុននិងបំប្លែងទៅជាក្រុមហ៊ុនឯកជនទទួលខុស ត្រូវមានកម្រិតវិញបាន ដោយម្ចាស់ភាគហ៊ុនទោលគ្រាន់តែផ្ទេរនូវចំណែកណាមួយនៃភាគហ៊ុនរបស់ខ្លួនទៅឱ្យបុគ្គលផ្សេងតែប៉ុណ្ណោះ។

ផ្អែកតាមមាត្រា ៨៦ នៃច្បាប់សហគ្រាសពាណិជ្ជកម្ម, សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត មានលក្ខខណ្ឌដូចគ្នាទៅនឹងលក្ខខណ្ឌទាំងឡាយរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែរ លើកលែងតែលក្ខខណ្ឌស្តីពីទំនាក់ទំនងរវាងសមាជិកភាគហ៊ុន។ តើលក្ខខណ្ឌដូចគ្នានេះចង់សំដៅដល់អ្វីខ្លះ? តើចង់សំដៅដល់លក្ខខណ្ឌក្នុងការបង្កើត, វិធានសម្រាប់គ្រប់គ្រងកិច្ចដំណើរការសហគ្រាស និងរបបពន្ធដារជាដើម? ការកំណត់បែបនេះ មិនទាន់មានភាពច្បាស់លាស់ទាំងស្រុងនោះទេ។ ជាក់ស្តែង ភាគទុនដែលអាចដាក់ចូលក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតអាចជាភាគហ៊ុនជាទ្រព្យ ភាគទុកជាប្រាក់ និងភាគទុកជាសេវា ប៉ុន្តែតើសហគ្រាសឯកបុគ្គលអាចមានភាគទុនជាសេវាបានដែរឬទេប្រសិនបើសហគ្រាសត្រូវមានដើមទុនហើយភាគទុនជាសេវាមិនត្រូវបានគណនា ដើម្បីកំណត់ពីដើមទុនរបស់ក្រុមហ៊ុននោះឡើយ? វិធានមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក៏មិនអាចត្រូវបានយកមកអនុវត្តដូចគ្នាចំពោះសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតបានដែរ។ជាឧទាហរណ៍ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចចុះកិច្ចសន្យាជាមួយម្ចាស់ភាគហ៊ុនក្នុងក្រុមហ៊ុននេះបាន។ ប៉ុន្តែ តើម្ចាស់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត អាចចុះកិច្ចសន្យាផ្តល់កម្ចី ឬខ្ចីប្រាក់ពីសហគ្រាសនេះបានដែរឬទេ? ជាទូទៅ ម្ចាស់ភាគហ៊ុនទោលដែលជាម្ចាស់សហគ្រាស គឺជាអភិបាល ឬអ្នកគ្រប់គ្រងក្រុមហ៊ុន។ ប៉ុន្តែ ការគ្រប់គ្រងក្រុមហ៊ុននេះ ក៏អាចត្រូវបានផ្តល់ឱ្យតតិយជនផងដែរ។ អំណាចរបស់មហាសន្និបាតម្ចាស់ភាគហ៊ុនគឺត្រូវអនុវត្តដោយស្រុងដោយម្ចាស់ភាគហ៊ុនទោល។ តើវិធានពាក់ព័ន្ធនឹងការកោះប្រជុំមហាសន្និបាតម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចយកមកអនុវត្តចំពោះសហគ្រាសឯកបុគ្គលនេះបានយ៉ាងដូចម្តេច? ជារួម ច្បាប់គួរតែកំណត់បន្ថែមអំពីរបបគតិយុត្តរបស់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតនេះឱ្យបានច្បាស់តែម្តង។

៣ - ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនេះជាទ្រង់ទ្រាយក្រុមហ៊ុនធំមានទុនវិនិយោគច្រើន និងផ្តោតសំខាន់លើទុនវិនិយោគ។ ក្រុមហ៊ុននេះ ជាក្រុមហ៊ុនមូលធនសុទ្ធសាធ ដោយមិនផ្តោតសំខាន់លើការរាប់អានបុគ្គលនោះទេ។ ដោយក្រុមហ៊ុននេះ បើកឱកាសឱ្យ “មហាជន ឬសាធារណជនទូទៅ” អាចចូលរួមដាក់ទុនវិនិយោគជាមួយក្រុមហ៊ុន ទើបច្បាប់កំណត់ថាក្រុមហ៊ុននេះ ជាប្រភេទក្រុមហ៊ុនមហាជន។ ដូច្នេះ ខុសពីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត រាល់ការរឹតត្បិតលើការធ្វើអនុប្បទានភាគហ៊ុននៅក្នុងក្រុមហ៊ុននេះ មិនត្រូវបានអនុញ្ញាតឡើយ ដោយសារការរឹតត្បិតនេះ គឺប៉ះពាល់ដល់សេរីភាពក្នុងការជួញដូរភាគហ៊ុននៅលើទីផ្សារភាគហ៊ុនឬផ្សារមូលបត្រ។ ជាទូទៅ នៅក្នុងច្បាប់នៃបណ្តាប្រទេសនានា ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនេះ គឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់ ដើម្បីបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ការបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវអនុលោមតាមតាមលក្ខខណ្ឌ និងនីតិវិធីដែលកំណត់ ដោយច្បាប់ស្តីពីការបោះផ្សាយលក់មូលបត្រមហាជន និងបទប្បញ្ញត្តិអនុវត្តច្បាប់នេះ[18]។ ចំពោះ វិស័យធនាគារ និងហិរញ្ញវត្ថុ មិនអាចដំណើរបានក្នុងទ្រង់ទ្រាយក្រុមហ៊ុនផ្សេងពីក្រុមហ៊ុនមហាជនទទួលខុស ត្រូវមានកម្រិតនេះបានឡើយ។

18. ញាន វណ្ណៈ, នីតិទីផ្សារមូលបត្រកម្ពុជា, វិស័យហិរញ្ញវត្ថុ, បោះពុម្ពលើកទី១ ឆ្នាំ២០១៥, ទំព័រ ១០៨-១៦៦។

ដោយក្រុមហ៊ុនមហាជននេះ ជាក្រុមហ៊ុនដែលផ្តោតសំខាន់លើទុនវិនិយោគ, ការដាក់ភាគទុនជាចំណេះដឹងនៅក្នុងក្រុមហ៊ុននេះ មិនត្រូវបានអនុញ្ញាតដោយច្បាប់នោះទេ[19]។ ច្បាប់ជាធរមានមិនបានកំណត់អំពីចំនួនអប្បរមានៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនោះទេ ដោយច្បាប់គ្រាន់តែបញ្ជាក់ថាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនត្រូវមានចំនួនសមាជិកហ៊ុនលើសពី ៣០ នាក់។ ប៉ុន្តែ នេះមិនមានន័យថា សមាជិកហ៊ុនអប្បរមារបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវមានយ៉ាងតិច ៣១ នាក់នោះទេ។ ជាគោលការណ៍ ក្រុមហ៊ុននេះមិនមានកំណត់ចំនួនអតិប្បរមានៃម្ចាស់ភាគហ៊ុននោះទេ។ ម្ចាស់ភាគហ៊ុន អាចជារូបវន្តបុគ្គល ឬជានីតិបុគ្គល។

ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត មានលក្ខណៈស្មុគស្មាញ ហើយវិធានច្បាប់ដែលគ្រប់គ្រងក្រុមហ៊ុននេះ ក៏មានភាពតឹងរឹងផងដែរ ដើម្បីការពារផលប្រយោជន៍របស់សាធារណជនដែលដាក់ទុនវិនិយោគចូលក្នុងក្រុមហ៊ុន និងការពារទំនុកចិត្តនៅលើទីផ្សារមូលបត្រ។ វិធានទាំងនេះផ្តោតជាពិសេសលើការធានាបាននូវអភិបាលកិច្ចល្អរបស់ក្រុមហ៊ុន តាមបែបអភិបាលកិច្ចសារជីវកម្ម និងការការពារសិទ្ធិរបស់ម្ចាស់ភាគហ៊ុន។ យោងតាមមាត្រា ៣៨ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ក្រុមហ៊ុនបោះផ្សាយមូលបត្រដែលបាន ឬមានបំណងចង់ធ្វើសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូងនៅកម្ពុជា ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវបទប្បញ្ញត្តិនានា និងរាល់លក្ខខណ្ឌទាំងឡាយស្តីពីអភិបាលកិច្ច ដើម្បីការពារផលប្រយោជន៍ដល់ការប្រព្រឹត្តទៅនៃទីផ្សារមូលបត្រ និងដើម្បីការពារផលប្រយោជន៍អ្នកវិនិយោគសាធារណៈ។ ស្តង់ដារអភិបាលកិច្ចនេះ ត្រូវបានកំណត់ថា *"អភិបាលកិច្ចសាជីវកម្ម"*[20]។ ក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ ត្រូវធានាឱ្យបាននូវអភិបាលកិច្ចសាជីវកម្មល្អតាមរយៈការបង្កើតយន្តការការពារសិទ្ធិរបស់ម្ចាស់ភាគហ៊ុន ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងអភិបាល កិច្ចរបស់ក្រុមហ៊ុន ការកំណត់សិទ្ធិអំណាច និងកាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាល ការបង្កើតប្រព័ន្ធ ត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព និងការការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធ។ ជារួមគោលបំណងចម្បងរបស់ប្រព័ន្ធអភិបាលកិច្ចសាជីវកម្ម គឺការធានាឱ្យបាននូវប្រសិទ្ធភាពតម្លាភាព

19. មាត្រា ១៤៦ កថាខ័ណ្ឌទី ៦ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

20. សូមអានលម្អិតៈ ១-OECD, G20/OECD Principles of Corporate Governance 2023, September 2023 (https://doi.org/10.1787/ed750b30-en), ២-ប្រកាសលេខ ០០២ គ.ម.ក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ, ៣-ប្រកាសលេខ ០១៣/១០ គ.ម.ក ប្រ.ក ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ។

និងគណនេយ្យភាពខ្ពស់ក្នុងការគ្រប់គ្រងចៀសវាងជម្លោះផលប្រយោជន៍រវាងអ្នកគ្រប់គ្រងនិងម្ចាស់ភាគហ៊ុន សំដៅធានាឱ្យបាននូវការរីកចម្រើនរបស់ក្រុមហ៊ុន និងការការពារសិទ្ធិរបស់ភាគហ៊ុនិក និងអ្នកវិនិយោគផ្សេងទៀតលើមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។ ម្ចាស់ភាគហ៊ុនដែលមានសម្លេងតិច បានទទួលការការពារ និងត្រូវបានអនុញ្ញាតឱ្យអនុវត្តសិទ្ធិរបស់ខ្លួនបានពេញលេញ។ គោលការណ៍អភិបាលកិច្ចសាជីវកម្មនេះ ត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជាធាតុដ៏សំខាន់ក្នុងការធានានូវទំនុកចិត្តរបស់អ្នកវិនិយោគសាធារណៈនៅលើទីផ្សារមូលបត្រ។

ភាគហ៊ុនរបស់ក្រុមហ៊ុន អាចមានច្រើនប្រភេទ និងច្រើនស៊េរី ជាអាទិ៍ ភាគហ៊ុនធម្មតា, ភាគហ៊ុនបុរិមា, ភាគហ៊ុនមានសិទ្ធិបោះឆ្នោត និងភាគហ៊ុនគ្មានសិទ្ធិបោះឆ្នោត, ភាគហ៊ុនដែលអាចផ្ទេរបាន ផ្លាស់ប្តូរបាន ឬលោះមកវិញបាន ជាដើម[21]។ ក្នុងករណីដែលលក្ខន្តិក:ក្រុមហ៊ុន មិនបានបញ្ជាក់នូវប្រភេទនៃភាគហ៊ុននោះទេ ក្រុមហ៊ុនត្រូវមានប្រភេទភាគហ៊ុនតែមួយប៉ុណ្ណោះ ដែលត្រូវតែជា *ភាគហ៊ុនធម្មតា* និងដែលផ្តល់សិទ្ធិដូចគ្នាដល់ម្ចាស់ភាគហ៊ុនទាំងអស់ទៅតាមសមាមាត្រនៃចំណែកភាគហ៊ុនរបស់ខ្លួនដែលរួមមានសិទ្ធិបោះឆ្នោតសិទ្ធិទទួលបានទួលភាគលាភសិទ្ធិទទួលបាននូវទ្រព្យដែលនៅសល់ក្រោយការរំលាយក្រុមហ៊ុននិងសិទ្ធិបេតិកភ័ណ្ឌផ្សេងទៀតដែលផ្សារភ្ជាប់នឹងភាគហ៊ុន ស្របតាមការកំណត់របស់ច្បាប់ជាធរមាន។ ក្នុងករណីដែលលក្ខន្តិក: អនុញ្ញាតឱ្យក្រុមហ៊ុនអាចមានភាគហ៊ុនច្រើនប្រភេទនោះ លក្ខន្តិក:ត្រូវកំណត់ឱ្យបានច្បាស់អំពីសិទ្ធិបុព្វសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទភាគហ៊ុននីមួយៗ។

ខុសពីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលអាចគ្រប់គ្រងដោយអភិបាលម្ចាស់ឬច្រើននាក់ ឬដោយក្រុមប្រឹក្សាភិបាល, ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវតែគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលមួយដែលមានអភិបាលយ៉ាងតិច ៣ រូប។ ចំនួនអភិបាលនេះត្រូវកើនដល់ ៥ រូប សម្រាប់ក្រុមហ៊ុនដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ។ អភិបាលមិនចាំបាច់ជាម្ចាស់ភាគហ៊ុន ឬមិនចាំបាច់តម្រូវឱ្យមានលក្ខណៈសម្បត្តិណាផ្សេងទៀតទេ លើកលែងតែលក្ខន្តិក:របស់ក្រុមហ៊ុនតម្រូវឱ្យមាន។ ក្នុងករណីដែលលក្ខន្តិក:ក្រុមហ៊ុនមិនចែងពីអាណត្តិទេ អភិបាលម្នាក់ៗត្រូវមានអាណត្តិ ២ ឆ្នាំ ហើយអាចត្រូវបោះឆ្នោតឱ្យសាជាថ្មីទៀតបាន។ អាណត្តិរបស់អភិបាលទាំងឡាយមិនអាចបញ្ចប់ក្នុងឆ្នាំជាមួយគ្នាបានឡើយ។ ក្រុមប្រឹក្សាភិបាល ត្រូវ

21. សូមអានលម្អិតៈ (១)-បៀន សាំង, មូលបត្រកម្មសិទ្ធិ និងតម្លៃ, បោះពុម្ពលើកទី១ ឆ្នាំ២០១២, (២)-បៀន សាំង, មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ, បោះពុម្ពលើកទី១ ឆ្នាំ២០១១ និង (៣)-ញាន វណ្ណៈ, ទីតិទីផ្សារមូលបត្រកម្ពុជា, វិស័យហិរញ្ញវត្ថុ, បោះពុម្ពលើកទី១ ឆ្នាំ២០១៥, ទំព័រ ៤៤-៦១។

ចាត់ចែងអាជីវកម្ម និងការងាររបស់ក្រុមហ៊ុន។ លក្ខន្តិកៈត្រូវចែងអំពីសិទ្ធិរបស់អភិបាល ឬក្រុមប្រឹក្សាភិបាល។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងដោយសម្លេងភាគច្រើន។ ការអនុវត្តនូវសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាភិបាល មិនប៉ះពាល់ដល់សិទ្ធិអំណាចផ្តាច់មុខរបស់ម្ចាស់ភាគហ៊ុន ដែលត្រូវសម្រេចដោយមហាសន្និបាតម្ចាស់ភាគហ៊ុននោះទេ។ មហាសន្និបាតម្ចាស់ភាគហ៊ុនត្រូវសម្រេចលើកិច្ចការដែលប៉ះពាល់ដល់ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ជាអាទិ៍ការបង្កើនឬបន្ថយដើមទុន, ការបោះផ្សាយលក់មូលបត្រថ្មីដែលមិនមានកំណត់ក្នុងលក្ខន្តិកៈ, ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការបង្រួមចូលគ្នាជាក្រុមហ៊ុនថ្មីមួយទៀត, ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន, ការរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត និងជម្រះបញ្ជីក្រុមហ៊ុន, ការលក់ និងការកែប្រែលក្ខន្តិកៈផ្សេងទៀត។

សេចក្តីសន្និដ្ឋាន

ជារួម សហគ្រាសពាណិជ្ជកម្ម អាចជាសហគ្រាសឯកបុគ្គល និងជាក្រុមហ៊ុនពាណិជ្ជកម្ម ដែលមានច្រើនទម្រង់។ ជាទូទៅ ចរិកលក្ខណៈគតិយុត្តនៃក្រុមហ៊ុនដែលបង្ហាញអំពីភាពខុសគ្នារវាងអត្ថប្រយោជន៍ និងគុណវិបត្តិរបស់ទម្រង់ក្រុមហ៊ុននីមួយៗ គឺជាកត្តាកំណត់មួយសម្រាប់ពាណិជ្ជករក្នុងការសម្រេចជ្រើសរើសយកទម្រង់ក្រុមហ៊ុនណាមួយក្នុងចំណោមទម្រង់នានាដែលកំណត់ដោយច្បាប់។ ជាក់ស្តែងការសម្រេចជ្រើសរើសយកទម្រង់ក្រុមហ៊ុនណាមួយគឺអាស្រ័យទៅលើប្រភេទអាជីវកម្ម ទំហំអាជីវកម្ម ការទទួលខុសត្រូវរបស់ម្ចាស់ភាគហ៊ុន ការគ្រប់គ្រងក្រុមហ៊ុន និងរបបពន្ធដារ។ ចំពោះអាជីវកម្មមានទំហំតូចដែលជាអាជីកម្មលក្ខណៈគ្រួសារ គឺមិនត្រូវបានបង្កើតក្នុងទម្រង់ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនោះទេ គឺអាចបង្កើតត្រឹមទម្រង់ជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ឬជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត។ លើការជាក់ស្តែងក្រុមហ៊ុនភាគច្រើនត្រូវបានបង្កើតឡើងក្នុងទម្រង់ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ជាពិសេស សហគ្រាសធុនតូច និងមធ្យម ដោយសារតែវិធានអនុវត្តសម្រាប់ក្រុមហ៊ុននេះ មានលក្ខណៈធូរស្រាលជាងវិធានអនុវត្តសម្រាប់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតហើយការទទួលខុសត្រូវរបស់ម្ចាស់ភាគហ៊ុនជាការទទួលខុសត្រូវមានកម្រិតពោលគឺត្រឹមកម្រិតនៃភាគទុនដែលបានដាក់បញ្ចូលជាដើមទុនរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ចំពោះក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយលក់មូលបត្រជាធារណៈ ដើម្បីកៀរគរទុនវិនិយោគពីអ្នកវិនិយោគសាធារណៈនៅលើទីផ្សារភាគហ៊ុនឬទីផ្សារមូលបត្រចាំបាច់ត្រូវបង្កើតក្នុងទម្រង់ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :...០២៧.ក.ស.ក/៦៤

សេចក្តីសម្រេច
ស្តីពី
ការបង្កើតក្រុមការងាររៀបចំព្រឹត្តិបត្រវិស័យច្បាប់ និងយុត្តិធម៌

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌

សម្រេច

ប្រការ១ ..

បង្កើត **ក្រុមការងាររៀបចំព្រឹត្តិបត្រវិស័យច្បាប់ និងយុត្តិធម៌** ដែលមានសមាសភាព ដូចខាងក្រោម៖

១-ឯកឧត្តម	**ញ៉ាន ឥណ្ណៈ**	រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌	ប្រធាន
២-ឯកឧត្តម	**តាន់ហ៊ាង ជាវ័ណ្ណ**	រដ្ឋលេខាធិការក្រសួងយុត្តិធម៌	អនុប្រធាន
៣-ឯកឧត្តម	**សេង ឌីណា**	រដ្ឋលេខាធិការក្រសួងយុត្តិធម៌	សមាជិក
៤-ឯកឧត្តម	**ង្វៃ ច័ន្ទមករា**	រដ្ឋលេខាធិការក្រសួងយុត្តិធម៌	សមាជិក
៥-ឯកឧត្តម	**សន សោភ័ណ**	អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌	សមាជិក
៦-ឯកឧត្តម	**ខាត់ ឆវ័ន្ត**	ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌	សមាជិក

មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

៧-ឯកឧត្តម	**តាំង ត្រី**	ជំនួយការ និងជានាយករងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌	សមាជិក
៨-លោកស្រី	**នៅ សុជាតា**	នាយករងសាលាភូមិន្នសារការី នៃបណ្ឌិត្យសភា ភូមិន្នយុត្តិធម៌កម្ពុជា	សមាជិក
៩-លោកស្រី	**ឈួន មករត**	នាយករងសាលាច្បាប់ នៃបណ្ឌិត្យសភា ភូមិន្នយុត្តិធម៌កម្ពុជា	សមាជិក
១០-លោក	**ភូ ភក្តី**	ជំនួយការក្រសួងយុត្តិធម៌	សមាជិក។

ប្រការ២ ..

ក្រុមការងារនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំព្រឹត្តិបត្រវិស័យច្បាប់ និងយុត្តិធម៌ សម្រាប់ផ្សព្វផ្សាយព័ត៌មានពីវិស័យច្បាប់ និងយុត្តិធម៌ និងលើកកម្ពស់ចំណេះដឹងពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌
- ទំនាក់ទំនងជាមួយឥស្សរជន មន្ត្រីរាជការ សាស្ត្រាចារ្យ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា សារការី មេធាវី និងអ្នកវិជ្ជាជីវៈនិងអ្នកដំនាញផ្សេងទៀតក្នុងវិស័យច្បាប់ និងយុត្តិធម៌ ដើម្បីចូលរួមក្នុងការរៀបចំ និងផ្តល់នូវអត្ថបទនានាសម្រាប់ចុះផ្សាយក្នុងព្រឹត្តិបត្រវិស័យច្បាប់ និងយុត្តិធម៌
- ពិនិត្យលើខ្លឹមសារអត្ថបទដែលត្រូវចុះផ្សាយក្នុងព្រឹត្តិបត្រវិស័យច្បាប់ និងយុត្តិធម៌
- ចាត់ចែងរៀបចំបោះពុម្ព និងផ្សព្វផ្សាយព្រឹត្តិបត្រវិស័យច្បាប់ និងយុត្តិធម៌ ដែលបានរៀបចំរួចរាល់
- រៀបចំផែនការសកម្មភាព និងផែនការថវិកាសម្រាប់ការងាររៀបចំ បោះពុម្ព និងផ្សព្វផ្សាយព្រឹត្តិបត្រវិស័យច្បាប់ និងយុត្តិធម៌
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ប្រការ៣ ..

អនុប្រធាន និងសមាជិកនៃក្រុមការងារនេះ ត្រូវចូលរួមក្នុងកិច្ចប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធាន អាចកោះប្រជុំ និង/ឬ ដឹកនាំកិច្ចប្រជុំជំនួសតាមការប្រគល់សិទ្ធិពីប្រធាន។

ប្រការ៤ ..

ក្រុមការងារនេះ ប្រើប្រាស់កញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌ ដើម្បីអនុវត្តការងាររបស់ខ្លួន។

ក្រុមការងារនេះមានសិទ្ធិទទួល គ្រប់គ្រង និងចាត់ចែងនូវមូលនិធិ អំណោយ ធនធាន និងថវិកាដែលទទួលបានពីប្រភពស្របច្បាប់ផ្សេងទៀត។

ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមការងារនេះ ព្រមទាំងបុគ្គលិកដែលបានរៀបចំនូវខ្លឹមសារនៃអត្ថបទសម្រាប់ការចុះផ្សាយនៅក្នុងព្រឹត្តិបត្រវិស័យច្បាប់ និងយុត្តិធម៌ អាចទទួលប្រាក់រង្វាន់លើកទឹកចិត្ត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ប្រការ៥ ...

នាយកខុទ្ធកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមការកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២កើត ខែ ផាល ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ចុម្ភៈ ឆ្នាំ២០២៤

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កើត រិទ្ធ

កន្លែងទទួលៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ធកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ធកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ